# ការរីកចម្រើននៃដំណើររបស់ពួកបរិសុទ្ធ

*ពីពិភពលោកនេះទៅកាន់ការដែលនឹងត្រូវមក*

**ផ្នែកទី១ [Volume I - 3]**



ត្រូវបានសរសេរមកនៅក្រោមភាពស្រដៀងគ្នាទៅនឹងការយល់សប្តិដោយ

លោក John Bunyan

Recommendation, White Young Jeon

Translator Sreyleak Kohn

CRFI

# អារម្ភកថា

 គោលបំណងដែលខ្ញុំបានអធិស្ឋានសុំអោយព័ន្ធកិច្ចសម្រាប់ការសរសេរនេះនឹងត្រូវបានបង្កើតឡើងនៅក្នុងក្រុមជំនុំក្នុងប្រទេសកម្ពុជាជាយូរយារណាស់មកហើយ ហើយវាត្រូវបានជោគជ័យដោយផែនការណ៍របស់ព្រះ។ ខ្ញុំមានអារម្មណ៍រីករាយដែលបានបោះពុម្ពសៀវភៅចំនួន ៣ ក្បាលក្នុងប្រភេទកំរិតខ្ពស់ ហើយជាផលដំបូងសម្រាប់ការសេរនៃព័ន្ធកិច្ចរបស់ CEMFយើង។
ជាបឋម ខ្ញុំសូមសរសើរតម្កើងដល់ព្រះអម្ចាស់ដោយអស់ពីចិត្តចំពោះការបោះពុម្ពផ្សាយទាំងនេះដែលនិពន្ធដោយ John Bunyan ដែលបានបម្រើព្រះអម្ចាស់ជាគ្រូអធិប្បាយដ៏បរិសុទ្ធនៅឆ្នាំ ១៦៧៨ ទៅជាភាសាខ្មែរសំរាប់បេសកកម្មនៅប្រទេសកម្ពុជា។ នៅក្នុងប្រវត្តិសាស្រ្តពួកជំនុំ សៀវភៅនេះត្រូវបានអានជាសៀវភៅបន្ទាប់ពីបទគម្ពីរ។
 ដោយសារភាសាខ្មែរពិបាកខ្លាំងពេក ខ្ញុំមិនហ៊ានធ្វើទេ ប៉ុន្តែព្រះបានរៀបចំក្រុមបកប្រែ CEMF សម្រាប់បេសកកម្មនេះ ហើយទីបំផុតតាមរយៈការលះបង់របស់គេ សៀវភៅនេះត្រូវបានបោះពុម្ពក្នុងឆ្នាំនេះ ក្នុងការរំលឹកខួប ១០០ ឆ្នាំចាប់តាំងពីក្រុមជំនុំកម្ពុជាបានទទួលដំណឹងល្អ ( ១៩២៣) ជាពិសេស កញ្ញា ស្រីល័ក្ខ ខន ដែលបម្រើការងារជាគ្រូបង្រៀនភាសាអង់គ្លេសនៃអនុវិទ្យាល័យ និងជាបុគ្គលិក CEMF ហើយនាងបានបញ្ចប់ការបកប្រែសៀវភៅដោយស្ម័គ្រចិត្តទោះបីគាត់កំពុងសំរាកព្យាបាលរបួសដោយគ្រោះថ្នាក់របស់គាត់ក៏ដោយ។ ខ្ញុំកោតសរសើរនាងចំពោះទឹកចិត្តស្មោះត្រង់របស់នាងដែលស្រឡាញ់ព្រះអម្ចាស់និងដំណឹងល្អ។

ជាទូទៅផ្នែកមួយមានចំនួនច្រើន (៣៦៣ ទំព័រ); ខ្ញុំចែកវាជាបីភាគសម្រាប់ជួយអ្នកអានខ្មែរយើង។ សូមឱ្យព្រះគុណរបស់ព្រះនៅជាមួយពួកគេរហូតទៅ។

នៅក្នុងព្រះគ្រីស្ទ

ថ្ងៃទី ២២ ខែតុលាឆ្នាំ ២០២១

ដោយ: លោកគ្រូបណ្ឌិត វ៉ាយ យ៉ុងចុន  ( ប្រធាន CRFI & CEMF)

Sequence

ភ្នំដែលគួរគាប់ចិត្ត /6
ភាពល្ងង់ខ្លៅចេញពីអំណួត /14
អ្នកបញ្ជោរ /34
មនុស្សមិនជឿថាមានព្រះ /40
ល្ងង់ខ្លៅបង្ហាញភាពល្ងង់ខ្លៅរបស់ខ្លួន /71
សេចក្តីកោតខ្លាចដែលត្រឹមត្រូវ /85
ប្រទេសនៃអ្នកដែលមានប្តី /96
ស្វាគមន៍ /108
សេចក្តីសរុប /118

## ភ្នំដែលគួរគាប់ចិត្ត

ពួកគេទៅរហូតដល់ "ភ្នំដែលគួរគាប់ចិត្ត" ដែលជាកម្មសិទ្ធិរបស់ព្រះអម្ចាស់នៃភ្នំនោះ ដែលយើងដែលបាននិយាយពីទ្រង់ពីមុនមក។ ដូច្នេះពួកគេឡើងទៅលើភ្នំ ដើម្បីសម្លឹងមើលសួនច្បារនិងដើមឈើ ចម្ការទំពាំងបាយជូរ និងប្រភពទឹកហូរ ជាកន្លែងដែលគេបានផឹក និងសម្អាតខ្លួនពួកគេ ហើយបរិភោគពីចម្ការទំពាំងបាយជូរដោយសេរី។ នៅពេលដែលពួកគេនៅលើកំពូលភ្នំទាំងនេះ អ្នកគង្វាលកំពុងឱ្យចំណីដល់ហ្វូងសត្វ ហើយពួកគេឈរនៅក្បែរផ្លូវធំ។ ដូច្នេះអ្នកធ្វើធម្មយាត្រាបានទៅកាន់ឯពួកគេ ហើយបានរៀនពីដំបងរបស់ពួកគេ (ដែលជាធម្មតាដល់អ្នកធ្វើធម្មយាត្រាដែលហាត់នឿយនៅពេលដែលពួកគេនិយាយជាមួយអ្នកណាម្នាក់តាមផ្លូវ) ពួកគេសួរថា "តើភ្នំដែលគួរគាត់ចិត្តទាំងនេះជារបស់អ្នកណា? ហើយតើសត្វចៀមទាំងនេះជារបស់អ្នកណាដែលស៊ីចំណីនោះ?

អ្នកគង្វាល៖ ភ្នំទាំងនេះជាទឹកដីរបស់ព្រះអេម៉ាញ៉ូអែល ហើយភ្នំទាំងនេះនៅមើលឃើញទីក្រុងរបស់ទ្រង់ផង ហើយចៀមទាំងនេះជារបស់ទ្រង់ ហើយទ្រង់បានលះបង់ព្រះជន្មទ្រង់សម្រាប់ពួកគេផង។

**"ខ្ញុំជាអ្នកគង្វាលល្អ ឯគង្វាលល្អ ក៏ស៊ូតែប្តូរជីវិតជំនួសចៀម។" យ៉ូហាន 10:11**

គ្រីស្ទាន៖ តើនេះជាផ្លូវទៅកាន់ទីក្រុងស្ថានសួគ៌មែនទេ?

អ្នកគង្វាល៖ អ្នកកំពុងនៅលើផ្លូវហ្នឹងតែម្តង។

គ្រីស្ទាន៖ តើវាឆ្ងាយប៉ុន្មានដែរទៅដល់ទីនោះ?

គង្វាល៖ វាពិតជាឆ្ងាយខ្លាំងណាស់សម្រាប់អ្នកនឹងទៅទីនោះ។

គ្រីស្ទាន៖ តើផ្លូវមានសុវត្ថិភាព ឬគ្រោះថ្នាក់ទៅ?

គង្វាល៖ សុវត្ថិភាពសម្រាប់អ្នកដែលនឹងមានសុវត្ថិភាព តែសម្រាប់អ្នកបះបោរវិញនឹងត្រូវដួលនៅទីនោះហើយ។

**"តើមានអ្នកណាដែលមានប្រាជ្ញា ឱ្យយល់សេចក្ដីទាំងនេះបាន ឬមានគំនិតវាងវៃឱ្យបានស្គាល់សេចក្ដីទាំងនេះផង ដ្បិតអស់ទាំងផ្លូវរបស់ព្រះយេហូវ៉ាសុទ្ធតែទៀងត្រង់ ពួកអ្នកសុចរិតនឹងដើរក្នុងផ្លូវនោះ តែមនុស្សទុច្ចរិតនឹងជំពប់ដួលក្នុងផ្លូវនោះវិញ។" ហូសេ 14:9**

គ្រីស្ទាន៖ តើនៅកន្លែងនេះមានការបន្ធូរស្បើយដល់អ្នកធ្វើធម្មយាត្រាដែលនឿយហត់និងដួលតាមផ្លូវទេ?

គង្វាល៖ ព្រះអម្ចាស់នៃភ្នំនេះបានឱ្យយើងធ្វើការចាត់ចែង មិនឱ្យពូកែភ្លេចនិងកំសាន្តចិត្តដល់អ្នកប្លែកមុខទេ។

**"ចូរមានសេចក្ដីស្រឡាញ់គ្នា ជាបងប្អូនជានិច្ច។ កុំភ្លេចសេចក្ដីថៅរ៉ៅឡើយ ដ្បិតមនុស្សខ្លះបានទទួលទាំងទេវតា ឱ្យសំណាក់នៅឥតដឹងផង ដោយមាន**

**សេចក្ដីនោះឯង។″ ហេព្រើរ 13:1, 2**

ដូច្នេះសេចក្ដីល្អនៃកន្លែងនេះគឺនៅខាងអ្នកហ្នឹងហើយ។

ខ្ញុំបានឃើញនៅក្នុងសុបិនរបស់ខ្ញុំផងដែរថា នៅពេលដែលអ្នកគង្វាលយល់ឃើញថាពួកគេជាអ្នកធ្វើដំណើរ ពួកគេក៏បានសួរសំណួរដល់ពួកគេ (ដែលពួកគេបានឆ្លើយសំណួរដូចនៅកន្លែងផ្សេងទៀតដែរ) ដូចជា "តើអ្នកមកពីណា?″ ហើយ "បានមកតាមផ្លូវនេះដោយរបៀបណា?″ ហើយ "ដោយវិធីអ្វីដែលអ្នកស៊ូទ្រាំមកដល់ទីនេះ?″ ដោយសារមនុស្សមិនច្រើនទេដែលបានមកដល់ទីនេះបង្ហាញមុខរបស់ពួកគេនៅលើភ្នំទាំងនេះ" តែនៅពេលដែលអ្នកគង្វាលឮចម្លើយរបស់ពួកគេ ក៏ពេញចិត្ត ក៏មើលទៅកាន់ពួកគេដោយក្ដីស្រឡាញ់ ហើយនិយាយថា "សូមស្វាគមន៍មកកាន់ភ្នំដែលគួរគាប់ចិត្ត!″

អ្នកគង្វាលដែលខ្ញុំនិយាយនោះមានឈ្មោះថា ចំណេះដឹង បទពិសោធន៍ ប្រុងប្រយ័ត្ន និងស្មោះត្រង់ បានដឹកដៃនាំពួកគេ ទៅនៅក្នុងតង់សំណាក់របស់ពួកគេ ហើយឱ្យពួកគេបានចូលរួមជាមួយនឹងអ្វីដែលរួចរាល់នាពេលបច្ចុប្បន្ននេះ។ ពួកគេនិយាយថែមទៀតថា "យើងចង់ឱ្យពួកអ្នកនៅស្នាក់ទីនេះមួយរយៈ ដើម្បីឱ្យបានស្គាល់ពួកយើង ហើយក្រៅពីនោះទៀតដើម្បីនឹងកំសាន្តចិត្តដល់ខ្លួនអ្នកជាមួយរបស់ល្អៗនៃភ្នំគួរគាប់ចិត្តនេះ។″ បន្ទាប់មកពួកគេប្រាប់ថា ពួកគេស្កប់ចិត្តនឹងស្នាក់នៅ ហើយពួកគេក៏ទៅកន្លែងសម្រាករបស់ពួកគេនៅពេលយប់ទៅ ដោយសារវាយប់ជ្រៅដែរហើយ។

បន្ទាប់មកខ្ញុំឃើញនៅក្នុងសុបិនរបស់ខ្ញុំថា ពេលព្រឹកឡើងអ្នកគង្វាលបានហៅទៅកាន់គ្រីស្ទាននិងពេញដោយសង្ឃឹម ឱ្យមកដើរជាមួយពួកគេនៅលើ

ភ្នំ។ ដូច្នេះពួកគេក៏ទៅជាមួយពួកគាត់ ហើយដើរមួយសន្ទុះ ដោយបាន ឃើញរូបភាពស្រស់ស្អាតពីគ្រប់ជ្រុង។ បន្ទាប់មកអ្នកគង្វាលនិយាយទៅ កាន់គ្នាទៅវិញទៅមកថា "តើយើងគួរតែបង្ហាញការអស្ចារ្យដល់អ្នកធ្វើធម្ម យាត្រាទាំងនេះទេ?" ដូច្នេះនៅពេលដែលគេសម្រេចថានឹងធ្វើ ក៏យកពួកគេ ទៅលើកំពូលភ្នំជាមុនសិនហៅថា "កំហុស" ដែលមានភាពទេរខ្លាំងនៅម្ខាង ទៀតដែលឆ្ងាយ ហើយប្រាប់ពួកគេឱ្យមើលទៅខាងក្រោមទៅកាន់បាតវា។ ដូច្នេះគ្រីស្ទាននិងពេញដោយសង្ឃឹមបានមើលទៅក្រោម ហើយបានឃើញ នៅបាតនោះមានបុរសពីរបីនាក់ត្រូវបានកិនទៅជាបំណែកៗដោយសារត្រូវ បានធ្លាក់ពីលើកំពូលភ្នំមក។ បន្ទាប់មកគ្រីស្ទាននិយាយថា "តើវាមានន័យ យ៉ាងម៉េច?" អ្នកគង្វាលឆ្លើយថា "តើអ្នកមិនដែលឮពីពួកគេ ដែលត្រូវបាន ឱ្យធ្វើខុស ដោយបានស្តាប់តាមហ៊ីមីនុស និងហ្វីលេថឹស ពីសេចក្តីជំនឿនៃ ការរស់ពីស្លាប់ឡើងវិញនៃរូបកាយនោះ?"

**"ហើយសម្តីគេនឹងស៊ីរូងដូចជាដំបៅក្លាយ ក្នុងពួកនោះមានឈ្មោះហ៊ីមេនាស និងភីលេត។ ដែលបានជ្រុលហួសចេញពីសេចក្តីពិត ទាំងនិយាយថា សេច ក្តីរស់ឡើងវិញ បានកន្លងទៅហើយ គេក៏បង្ខូចសេចក្តីជំនឿរបស់អ្នកខ្លះដែរ។" ធីម៉ូថេទី២ 2:17, 18**

ពួកគេបានឆ្លើយថា "បាទបាន។" បន្ទាប់មកអ្នកគង្វាលនិយាយថា "ពួកគេជា អ្នកដែលអ្នកបានឃើញត្រូវវាយបែកជាបំណែកៗនៅបាតភ្នំនេះហើយ ហើយពួកគេនៅរហូតដល់សព្វថ្ងៃនេះដោយមិនបានកប់ (ដូចដែលអ្នក

ឃើញហ្នឹង) ទុកជាគម្រូដល់អ្នកផ្សេងទៀតឱ្យគេឮថាពួកគេបានឡើងខ្ពស់ពេក ឬការដែលគេមកជិតមាត់ភ្នំនេះខ្លាំងពេក។"

បន្ទាប់មកខ្ញុំបានឃើញថាពួកគេត្រូវបាននាំទៅលើកំពូលភ្នំផ្សេងទៀត ហើយភ្នំនោះមានឈ្មោះថា "ការដាស់តឿន" ហើយប្រាប់ពួកគេឱ្យមើលទៅទីឆ្ងាយ។ ដែលពេលពួកគេមើលទៅ ពួកគេឃើញថា តាមដែលពួកគេគិតទៅ មានមនុស្សបីបួននាក់កំពុងដើរចុះឡើងនៅក្នុងផ្នូរដែលនៅទីនោះ។ ដែលពួកគេសង្កេតឃើញថាមនុស្សទាំងនោះខ្វាក់ភ្នែក ដោយសារជួនកាលពួកគេជំពប់ដួលនៅលើផ្នូរ ហើយដោយសារតែពួកគេមិនអាចចេញរួចពីទីនោះផង។ បន្ទាប់មកគ្រីស្ទាននិយាយថា "តើនេះមិនន័យយ៉ាងណា?"

អ្នកគង្វាលក៏ឆ្លើយថា "តើអ្នកមិនបានឃើញថា នៅខាងក្រោមភ្នំទាំងនេះបន្តិច មានជណ្ដើរដែលនាំចូលទៅកាន់វាលស្មៅដែលនៅខាងឆ្វេងដៃ។" ចេញពីជណ្ដើរនោះមានផ្លូវដែលនាំតម្រង់ទៅវិមាននៃការសង្ស័យ ដែលត្រូវរក្សាដោយយក្សនៃសេចក្ដីអស់សង្ឃឹម ហើយមនុស្សទាំងនេះ (ចង្អុលទៅកាន់ពួកគេដែលនៅក្នុងកន្លែងផ្នូរ) ម្ដងនោះបានមកធ្វើធម្មយាត្រាដូចជាអ្នកធ្វើនេះដែរ រហូតមកដល់ជណ្ដើរនោះផង គឺដោយសារតែផ្លូវត្រូវនោះវាពិបាកនៅទីនោះ ពួកគេក៏ជ្រើសដើរចេញពីវាទៅកាន់វាលស្មៅ ហើយនៅទីនោះត្រូវយក្សនៃសេចក្ដីអស់សង្ឃឹមចាប់ ហើយបោះចូលទៅក្នុងវិមាននៃសេចក្ដីសង្ស័យ ជាកន្លែងដែលពួកគេត្រូវឃុំមួយរយៈនៅក្នុងគុកងងឹត យក្សក៏បានយកភ្នែករបស់ពួកគេចេញ ហើយឱ្យពួកគេដើរនៅក្នុងចំណោមផ្នូរខ្មោច ជាកន្លែងដែលគេទុកពួកនោះចោលឱ្យវង្វេងរហូតមកដល់សព្វថ្ងៃនេះ ដែល

ពាក្យរបស់អ្នកប្រាជ្ញមួយនឹងត្រូវសម្រេចបំពេញគឺ "អ្នកដែលវង្វេងចេញពីផ្លូវនៃការយល់ដឹង នឹងត្រូវនៅក្នុងក្រុមជំនុំរបស់មនុស្សស្លាប់។"

**"មនុស្សណាដែលវង្វេងចេញពីផ្លូវនៃប្រាជ្ញា នោះនឹងសម្រាកនៅក្នុងចំណោមមនុស្សស្លាប់ហើយ។" សុភាសិត 21:16**

បន្ទាប់មកគ្រីស្ទាននិងពេញដោយសង្ឃឹមសម្លឹងមើលគ្នាទៅវិញទៅមកជាមួយនឹងទឹកភ្នែកហូរចេញមកក្រៅ តែមិនបាននិយាយអ្វីទៅកាន់អ្នកគង្វាលឡើយ។

បន្ទាប់មកខ្ញុំឃើញនៅក្នុងសុបិនរបស់ខ្ញុំថា អ្នកគង្វាលនាំពួកគេទៅកន្លែងមួយទៀត នៅក្នុងបាត ដែលមានទ្វារមួយនៅម្ខាងនៃភ្នំ ហើយពួកគេបានបើកទ្វារ ហើយឱ្យពួកគេមើលទៅខាងក្នុង។ ដូច្នោះ ពួកគេបានមើលទៅក្នុងឃើញថាវាងងឹតនិងពេញដោយផ្សែងយ៉ាងខ្លាំង។ ហើយពួកគេគិតថាពួកគេបានឮសម្លេងនោះដូចជាសូរសន្ធឹកលាន់ដូចភ្លើង ហើយសម្លេងយំរបស់មនុស្សមួយចំនួនត្រូវធ្វើទារុណកម្ម ហើយពួកគេក៏ធំក្លិនស្អាន់ធម៌។ បន្ទាប់មកគ្រីស្ទាននិយាយថា "តើនេះមានន័យយ៉ាងណា?" បន្ទាប់មកអ្នកគង្វាលប្រាប់ពួកគេថា "នេះជាផ្លូវនៅក្បែរទៅកាន់ស្ថាននរក ជាផ្លូវដែលមនុស្សកំពុតដើរ និយាយទៅកាលដែលពួកគេលក់សិទ្ធិជាកូនច្បងរបស់ពួកគេជាមួយអេសាវ ដូចដែលលក់ម្ចាស់របស់ពួកគេដែរជាមួយនឹងយូដាស ដូចជាការអង្គាប់ដល់ដំណឹងល្អជាមួយលោកអាឡិចសាន់ដឺ និងការកុហកនិងការលាក់បាំងជាមួយនឹងអាណានាសនិងសាហ្វីរ៉ាប្រពន្ធរបស់គាត់។

សង្ឃឹមៈ បន្ទាប់មកពេញដោយសង្ឃឹមនិយាយទៅកាន់អ្នកគង្វាលថា "ខ្ញុំយល់ឃើញថាការទាំងនេះកើតមានដល់ពួកគេ ដល់គ្រប់គ្នា ជាការបង្ហាញពីអ្នកធ្វើធម្មយាត្រា ដូចដែលយើងមានពេលនេះ តើពិតមែនទេ?"

គង្វាលៈ បាទ ហើយរក្សាវាទុកឱ្យបានយូរផង។

សង្ឃឹមៈ តើពួកគេនឹងទៅឆ្ងាយប៉ុណ្ណានៅក្នុងធម្មយាត្រានៅក្នុងគ្រារបស់ពួកគេនោះ ក្នុងកាលដែល ពួកគេត្រូវបានបោះចោលដោយវេទនាបែបនេះ?

គង្វាលៈ អ្នកខ្លះបានទៅឆ្ងាយទៀត ហើយខ្លះទៀតមិនបានមកដល់ភ្នំនេះផង។

បន្ទាប់មកអ្នកធ្វើធម្មយាត្រានិយាយគ្នាថា "យើងត្រូវការស្រែកឱ្យខ្លាំងរកកម្លាំងថែមទៀត។"

គង្វាលៈ អេ ហើយអ្នកនឹងត្រូវប្រើវានៅពេលដែលអ្នកមានវាដែរ។

មកដល់ពេលនេះអ្នកធ្វើធម្មយាត្រាមានបំណងចង់ទៅមុខ ហើយអ្នកគង្វាលចង់ឱ្យពួកគេទៅដែរ។ ដូច្នេះពួកគេបានដើរជាមួយគ្នាទៅកាន់ទីបំផុតនៃភ្នំ។ បន្ទាប់មកអ្នកគង្វាលនិយាយគ្នាថា "ចូរយើងបង្ហាញដល់អ្នកធ្វើធម្មយាត្រាពីទ្វារទៅកាន់ទីក្រុងស្ថានសួគ៌ ប្រសិនបើពួកគេចេះមើលផ្លុះកញ្ចក់នៃទស្សនៈនេះ។" អ្នកធ្វើធម្មយាត្រាបានទទួលយកទង្វើនោះដោយសេចក្តីស្រឡាញ់ ដូច្នេះពួកគេត្រូវបាននាំទៅទៅកាន់កំពូលភ្នំមួយហៅថា "ច្បាស់លាស់" ហើយបានឱ្យកែវដល់ពួកគេមើល។ បន្ទាប់មកពួកគេសាកល្បងមើល តែ

ការចង់ចាំនៃរឿងចុងក្រោយដែលអ្នកគង្វាលបានបង្ហាញដល់ពួកគេ ធ្វើឱ្យដៃរបស់ពួកគេញ័រ ដោយសារសេចក្តីកំសោយ ពួកគេមិនអាចមើលតាមកែវនោះឱ្យនឹងនរបានឡើយ។ តែពួកគេបានគិតថា ពួកគេបានឃើញអ្វីមួយដូចជាឃ្លោងទ្វារ ហើយសិរីល្អខ្លះនៃទីនោះ។ បន្ទាប់មកពួកគេក៏ចេញទៅ ហើយច្រៀងបទនេះថា

"ដូច្នេះដោយអាថ៌កំបាំងរបស់អ្នកគង្វាលត្រូវបានបង្ហាញមក ដែលជារឿងត្រូវបានរក្សាទុកមិនឲ្យមនុស្សផ្សេងទៀតដឹង។ ចូរមករកអ្នកគង្វាលមក ប្រសិនបើអ្នកអាចឃើញការដែលជ្រៅ ការដែលលាក់កំបាំង ហើយការដែលសម្ងាត់ផង។"

នៅពេលដែលពួកគេជិតចាកចេញទៅ មានអ្នកគង្វាលម្នាក់បានឱ្យក្រដាស់កំណត់ផ្លូវដល់ពួកគេ ម្នាក់ទៀតប្រាប់ពួកគេឱ្យប្រយ័ត្ននឹងអ្នកដែលនិយាយបញ្ចោរ អ្នកទីបីប្រាប់ពួកគេឱ្យប្រយ័ត្នថាពួកគេនឹងមិនដេកនៅលើដីដែលត្រូវបានដាក់ស្នេហ៍ ហើយអ្នកទីបួនប្រាប់ពួកគេទៅរកព្រះ។ ដូច្នេះខ្ញុំក៏ភ្ញាក់ពីការយល់សប្តរបស់ខ្ញុំ។

## ភាពល្ងង់ខ្លៅចេញពីអំណួត

ហើយខ្ញុំបានដេកលក់ ហើយយប់សប្តម្តងទៀត ហើយបានឃើញអ្នកធ្វើធម្មយាត្រាពីរនាក់នោះម្តងទៀតកំពុងតែចុះពីភ្នំ នៅខាងឆ្វេងដៃ មានប្រទេស "អំណួត" មួយ មានផ្លូវមួយចេញពីនោះមកដែលអ្នកធ្វើធម្មយាត្រាបានដើរវាងពិបាកបន្តិច។ ដូច្នេះនៅទីនេះ ពួកគេបានជួបនឹងក្មេងប្រុសឆ្លាតវាងវៃម្នាក់ដែលចេញមកពីប្រទេសនោះ ហើយឈ្មោះរបស់វាគឺ ភាពល្ងង់ខ្លៅ។ ដូច្នេះគ្រីស្ទានបានសួរគាត់ថា "តើអ្នកមកពីម្តុំណាដែរ? ហើយតើឯងកំពុងទៅណា?"

ល្ងង់៖ លោកម្ចាស់អើយ ខ្ញុំបានកើតនៅក្នុងប្រទេសដែលនៅត្រង់នោះ នៅខាងស្តាំដៃបន្តិច ហើយខ្ញុំកំពុងទៅកាន់ទីក្រុងស្ថានសួគ៌។

គ្រីស្ទាន៖ តែតើអ្នកគិតថាអាចទៅដល់ឃ្លោងទ្វារយ៉ាងណាបាន ដោយសារអ្នកនឹងជួបការលំបាកមួយចំនួននៅទីនោះ?

ល្ងង់៖ "ដូចមនុស្សល្អផ្សេងទៀតធ្វើដែរ" គាត់បាននិយាយ

គ្រីស្ទាន៖ តើឯងមានអ្វីដែលបង្ហាញនៅទ្រង់ឃ្លោងទ្វារនោះ ដើម្បីឱ្យទ្វារនោះបើកឱ្យអ្នកចូល?

ល្ងង់៖ ខ្ញុំស្គាល់បំណងព្រះហឫទ័យរបស់ព្រះអម្ចាស់របស់ខ្ញុំ ហើយខ្ញុំបានរស់នៅក្នុងជីវិតដ៏ល្អ។ ខ្ញុំសងអ្វីដែលជារបស់គេដល់គេវិញ ខ្ញុំអធិស្ឋាន តម

អាហារ ថ្វាយដង្វាយមួយភាគក្នុងដប់ និងធ្វើទាន ហើយបានចាកចេញពីប្រទេសរបស់ខ្ញុំដើម្បីទៅទីនោះ។

គ្រីស្ទាន៖ តែអ្នកមិនបានមកតាមទ្វារទុច្ចរិតដែលនៅក្បាលផ្លូវនេះទេ អ្នកបានមកតាមទីនេះដែលជាផ្លូវមិនល្អ ហើយដូច្នេះខ្ញុំខ្លាចថា មិនថាអ្នកគិតចំពោះខ្លួនយ៉ាងណានោះទេ នៅពេលដែលបានកំណត់ទុកមកដល់ អ្នកនឹងត្រូវបង្ហាញពីសេចក្តីចោទប្រកាន់របស់អ្នក ដែលថាអ្នកជាចោរនិងចោរប្លន់ជាងការដែលនឹងអនុញ្ញាតឱ្យចូលទៅក្នុងទីក្រុង។

ល្ងង់៖ សុភាពបុរសអើយ អ្នកជាមនុស្សប្លែកមុខសម្រាប់ខ្ញុំ ខ្ញុំមិនស្គាល់អ្នកទេ។ ចូរស្កប់ចិត្តនឹងដើរតាមសាសនាពីប្រទេសរបស់អ្នកទៅ ហើយខ្ញុំនឹងដើរតាមសាសនាដែលជារបស់ខ្ញុំ។ ខ្ញុំសង្ឃឹមថាគ្រប់យ៉ាងនឹងបានល្អ។ ហើយសម្រាប់ឃ្លោងទ្វារដែលអ្នកនិយាយនោះ មនុស្សពេញពិភពលោកដឹងថាវាជាផ្លូវដ៏ធំជាផ្លូវនៅប្រទេសរបស់ពួកយើងឆ្ងាយណាស់។ ខ្ញុំមិនអាចគិតបានថាមនុស្សណានៅក្នុងគ្រប់ផ្នែកទាំងអស់ដឹងពីផ្លូវទៅកាន់វានោះឡើយ ហើយវាក៏មិនជាបញ្ហាដល់ពួកគេទោះពួកគេទៅ ឬមិនទៅនោះឡើយ ក្នុងកាលដែលពួកគេមានផ្លូវដ៏ខៀវខ្ចីគួរឱ្យពេញចិត្តបែបនេះដូចដែលអ្នកឃើញនោះ ដែលវាចេញមកពីប្រទេសរបស់យើងដែលជាផ្លូវបន្ទាប់នោះ។

នៅពេលដែលគ្រីស្ទានឃើញថាបុរសនេះឆ្លាតនៅក្នុងអំណួតរបស់គាត់ គាត់ក៏និយាយទៅកាន់ពេញដោយសង្ឃឹមដោយខ្សឹបៗថា "មានសង្ឃឹមសម្រាប់មនុស្សល្ងីល្ងើជាដែលបុរសនេះមាន។"

**"ឯងដែលឃើញមនុស្សដែលប្រកាន់ថា ខ្លួនមានប្រាជ្ញាឬទេ មានសង្ឃឹមចំពោះមនុស្សល្ងីល្ងើជាជាងអ្នកនោះទៅទៀត។" សុភាសិត 26:12**

ហើយនិយាយទៀតថា "នៅពេលដែលមនុស្សល្ងីល្ងើដើរតាមផ្លូវនេះ ប្រាជ្ញារបស់គាត់ធ្វើឱ្យគាត់លំបាក ហើយគាត់និយាយទៅកាន់គ្រប់គ្នាថាគាត់ជាមនុស្សល្ងង់។"

**"អើ នេះ១ទៀត កាលណាមនុស្សល្ងីល្ងើដើរតាមផ្លូវ នោះប្រាជ្ញាលះបង់ចោលវាបាត់ ហើយវាប្រាប់ដល់គ្រប់គ្នាថាជាមនុស្សល្ងីល្ងើទេ" សាស្តា 10:3**

អ្វីហ្នឹង! តើយើងគួរតែនិយាយជាមួយគាត់ទៀតដែរទេ? ឬចាកចេញពីគាត់ទុកគាត់ឱ្យគិតនូវអ្វីដែលគាត់បានឮរួចមកហើយចុះ ហើយបន្ទាប់មកឈប់ចាំគាត់ម្តងទៀត ហើយចាំមើលថាយើងនឹងអាចធ្វើអ្វីល្អចេញពីគាត់ខ្លះ?" បន្ទាប់មកពេញដោយសង្ឃឹមនិយាយ

"ចូរឱ្យល្ងង់ខ្លៅបានគិតអ្វីដែលបាននិយាយបន្តិចសិនទៅ ហើយកុំឱ្យគាត់បដិសេធនឹងទទួលដំបូន្មានល្អនោះឡើយ មិនដូច្នោះគាត់នឹងនៅតែល្ងង់ពីថាអ្វីដែលជាផងចំណេញដ៏ធំបំផុតហើយ។ ព្រះទ្រង់មានបន្ទូលថា "អ្នកមិនមានចំណេះដឹង (បើទោះជាគាត់បានធ្វើវាក៏ដោយ) គាត់ក៏មិនអាចរក្សារបស់ទាំងនោះបានឡើយ។""

សង្ស័យ៖ គាត់បន្ថែមទៀតថា "ខ្ញុំគិតថាវាមិនល្អទេ ដែលត្រូវនិយាយជាទៅគាត់តែម្តងនោះ ចូរយើងទៅហួសគាត់វិញ ហើយនិយាយជាមួយគាត់បន្តិចក្រោយមកវិញ មិនថាគាត់អាចទទួលវាបានឬអត់ទេ។"

ដូច្នេះពួកគេទាំងពីរបានបន្តទៅទៀត ហើយល្ងង់ខ្លៅបានមកតាមក្រោយ។ ពេលនេះបន្ទាប់ពីពួកគេបានទៅផុតឆ្ងាយបន្តិចមក ពួកគេបានចូលទៅក្នុងផ្លូវមួយយ៉ាងងងឹត ជាកន្លែងដែលពួកគេបានជួបបុរសម្នាក់ដែលមានអារក្សប្រាំពីរចងដោយខ្សែរមាំប្រាំពីរ ហើយត្រូវបាននាំទៅកាន់មាត់ទ្វារដែលពួកគេបានឃើញនៅក្បែរភ្នំ។

**"នោះវាចេញទៅនាំយកអារក្ស៧ទៀត ដែលកាចៗជាងវា មកជាមួយផង ក៏នាំគ្នាចូលទៅនៅទីនោះ ហើយសណ្ឋានក្រោយរបស់មនុស្សនោះ បានអាក្រក់ជាងមុនទៅទៀត ឯមនុស្សជំនាន់អាក្រក់នេះ គេនឹងបានដូច្នោះដែរ។" ម៉ាថាយ 12:45**

**"អស់ទាំងអំពើទុច្ចរិតរបស់មនុស្សអាក្រក់នឹងចាប់យកអ្នកនោះឯង ហើយអ្នកនោះនឹងត្រូវចងជាប់ ដោយចំណងនៃអំពើបាបរបស់ខ្លួន" សុភាសិត 5:22**

នៅពេលនេះគ្រីស្ទានល្អចាប់ផ្តើមភ័យញ័រ ហើយពេញដោយសង្ស័យក៏ដូចគ្នា តែនៅពេលដែលអារក្សបាននាំបុរសនោះទៅ គ្រីស្ទានបានមើលថាគាត់បានស្គាល់បុរសនោះទេ ហើយគាត់គិតថាប្រាកដជាម្នាក់ដែលមានឈ្មោះថា ត្រឡប់ទៅវិញហើយ ដែលបានរស់នៅក្នុងក្រុងនៃការបោះបង់សាសនា។ តែ

គាត់មិនបានមើលឃើញមុខរបស់បុរសនោះច្បាស់ទេ ដោយសារគាត់មិនបានព្យួរក្បាលរបស់គាត់ដូចជាចោរដែលត្រូវគេរកឃើញឡើយ តែពេលដែលបានទៅផុតទៅ ពេញដោយសង្ឃឹមមើលពីក្រោយគាត់ ហើយឃើញថានៅខ្នងរបស់គាត់នោះមានក្រដាស់មួយដែលសរសេរថា "សាស្រ្តាចារ្យល្មោភ និងជាអ្នកបោះបង់សាសនាដែលត្រូវបណ្តាសា។"

រឿងរបស់អ្នកមានជំនឿតិច

បន្ទាប់មកគ្រីស្ទានបាននិយាយទៅកាន់សំឡាញ់របស់គាត់ថា "ពេលនេះខ្ញុំចង់ចាំ ពីរឿងមួយដែលបានប្រាប់ដល់ខ្ញុំ ពីការដែលបានកើតឡើងដល់មនុស្សល្អនៅទីនេះ។ ឈ្មោះរបស់បុរសនោះគឺ ជំនឿតិច តែជាមនុស្សល្អម្នាក់ ហើយគាត់រស់នៅក្នុងទីក្រុងស្មោះត្រង់។ ការនោះគឺបែបនេះ ក្នុងការដែលចូលទៅក្នុងអត្ថបទមួយនេះ មានផ្លូវមួយដែលចេញមកពីផ្លូវធំនៃឃ្លោងទ្វារដែលហៅថា ផ្លូវរបស់មនុស្សស្លាប់ ហៅដូច្នោះដោយសារជាធម្មតាមានការស្លាប់កើតឡើងនៅទីនោះ។ ហើយជំនឿតិចធ្វើដំណើរធម្មយាត្រាដូចដែលយើងធ្វើនេះដែរ ក៏បានអង្គុយនៅទីនោះ ហើយបានដេកលក់ទៅ។ ពេលនេះក៏បានកើតឡើងនៅទីនោះ នៅពេលនោះ ដើម្បីចុះពីផ្លូវនោះពីឃ្លោងទ្វារផ្លូវធំមកមានមនុស្សពាលខ្លាំងពូកែបីនាក់ ហើយឈ្មោះរបស់ពួកគេគឺ ចិត្តធ្លាក់ខ្សោយ មិនទុកចិត្ត និងកំហុស (បងប្អូនបីនាក់)។ ហើយពួកគេបានមើលឃើញជំនឿតិចត្រង់កន្លែងដែលគាត់នៅ បានស្ទុះមករកគាត់យ៉ាងលឿន។ ពេលនេះមនុស្សល្អទើបតែភ្ញាក់ពីដំណេក ហើយក្រោកឡើងដើម្បីបន្តដំណើររបស់គាត់។ ដូច្នេះពួកគេមកដល់គាត់ ហើយដោយភាសាដែលគំរាមកំហែង ប្រាប់គាត់ឱ្យឈរ។ ដូច្នេះជំនឿតិចមើលទៅឈរស្លាំងដូចជា

ពពក ហើយគ្មានអំណាចនឹងវាយតបឬហោះនោះឡើយ។ បន្ទាប់មកចិត្តចុះខ្សោយបាននិយាយថា "ប្រគល់កាបូបរបស់អ្នកមក" តែគាត់មិនបានប្រញាប់ប្រញាល់ធ្វើឡើយ (ដោយសារគាត់មិនចូលចិត្តនឹងបាត់លុយរបស់គាត់ឡើយ) មិនទុកចិត្តក៏បានរត់មករកគាត់ ហើយបានលូកដៃរបស់គេចូលក្នុងហោប៉ៅរបស់គាត់ ហើយបានទាញស្បោងលុយមួយចេញមក។ បន្ទាប់មកគាត់យំថា "ចោរ! ចោរ!" ដូច្នេះកំហុសដោយមានរំពាត់នៅក្នុងដៃរបស់គាត់ផងនោះ បានវាយជំនឿតិចត្រង់ក្បាល ហើយដោយការវាយដំនោះបានធ្វើឱ្យគាត់ដួលទៅនឹងដីទៅ គាត់បានដេលដួលដោយមានឈាមហូរមកប្រៀបដូចជាម្នាក់ត្រូវហូរឈាមជិតស្លាប់។ ហើយចោរនៅតែឈរក្បែរនោះតែចុងក្រោយ ពួកគេបានឮមានមនុស្សមកតាមផ្លូវ ហើយខ្លាចថាវាអាចជាលោក ព្រះគុណអស្ចារ្យ ដែលរស់នៅក្នុងទីក្រុង ទំនុកចិត្តល្អនោះ ពួកគេរត់យ៉ាងលឿន ហើយទុកឱ្យបុរសល្អនេះនៅតែខ្លួនគាត់ម្នាក់ឯង។ ពេលនេះបន្តិចក្រោយមក ជំនឿតិចបានដឹងខ្លួនវិញ ហើយបានប្រមូលកម្លាំងមកវិញ ហើយរៀបចំនឹងចេញទៅតាមផ្លូវរបស់គាត់វិញ។ នេះគឺជាសាច់រឿងហើយ។"

សង្ឃឹម៖ តែតើពួកគេបានយកអ្វីទាំងអស់ដែលគាត់មានដែរទេ?

គ្រីស្ទាន៖ ទេ កន្លែងដែលគ្រឿងអលង្ការរបស់គាត់ដែលគេលួចប្លន់មិនបានទេ ដូច្នេះរបស់ទាំងនោះត្រូវបានរក្សាទុកដដែល។ តែមានគេប្រាប់ថាមនុស្សល្អនោះត្រូវបានគេធ្វើបាបយ៉ាងខ្លាំងជាការខូចខាតរបស់គាត់ ដោយសារចោរបានយកលុយដែលត្រូវចំណាយរបស់គាត់ស្ទើរតែទាំងអស់។ អ្វីដែលគេមិនបានយកនោះ (ដូចដែលខ្ញុំនិយាយ) គឺគ្រឿងអលង្ការ

ហើយគាត់មានលុយចម្លែកបន្តិចមួយនៅសល់ តែភ័យខ្លាចថានឹងមិនអាចនាំគាត់ដល់ទីបំផុតនៃការធ្វើដំណើរបាន។

**"តែមុនដំបូងបង្អស់ ត្រូវឱ្យអ្នករាល់គ្នាមានសេចក្ដីស្រឡាញ់គ្នា ឱ្យអស់ពីចិត្ត ដ្បិតសេចក្ដីស្រឡាញ់នឹងគ្របបាំងអំពើបាបជាអនេកអនន្ត" ពេត្រុសទី១ 4:8**

ទេ (ប្រសិនបើគេប្រាប់ខ្ញុំមិនខុសទេ) គាត់ត្រូវគេបង្ខំឱ្យសុំទានក្នុងកាលដែលគាត់ទៅ ដើម្បីឱ្យមានជីវិតរស់ (ដោយសារគាត់នឹងមិនលក់គ្រឿងអលង្ការរបស់គាត់ឡើយ)។ តែបានសុំទាន និងធ្វើអ្វីដែលគាត់អាចធ្វើបាន គាត់បានទៅ (ដូចដែលយើងនិយាយ) "ដោយសារពោះឃ្លានខ្លាំង" ភាគច្រើននៃផ្លូវគាត់ធ្វើដំណើរ។

សង្ឃឹម៖ តែតើវាមិនគួរឱ្យឆ្ងល់ទេថាពួកគេមិនបានយកសញ្ញាបត្រពីគាត់ ជារបស់ដែលគាត់នឹងទទួលបានការអនុញ្ញាតចូលតាមឃ្លោងទ្វារស្ថានសួគ៌នោះ?

គ្រីស្ទាន៖ "វាជាការអស្ចារ្យដែលដែលពួកគេមិនបានយកវានោះ បើទោះជាពួកគេមិនបានភ្លេចនឹងប្រើកលល្បិចល្អណាមួយរបស់ពួកគេក៏ដោយ ដោយសារគាត់ត្រូវបានស្រងាកចិត្តដោយសារពួកគេសម្រុកមករកគាត់ ហើយមិនមានអំណាចឬជំនាញលាក់របស់អ្វីណាមួយឡើយ។ ដូច្នេះវាជាផែនការល្អមួយមកពីព្រះជាជាងការខិតខំប្រឹងប្រែងរបស់គាត់ ដែលធ្វើឱ្យបាត់បង់របស់ល្អនោះ។"

**"ចូររក្សាបញ្ញើល្អដែលផ្ញើទុកនឹងអ្នក ដោយសារព្រះវិញ្ញាណបរិសុទ្ធ ដែលសណ្ឋិតនៅក្នុងយើង។" ធីម៉ូថេទី២ 1:14**

**"បើដូច្នេះឃើញថា ព្រះអម្ចាស់ទ្រង់ចេះប្រោសមនុស្សដែលគោរពប្រតិបត្តិដល់ទ្រង់ ឱ្យរួចពីសេចក្តីល្បួង ហើយនិងឃុំទុកមនុស្សទុច្ចរិត សម្រាប់នឹងធ្វើទោសក្នុងថ្ងៃជំនុំជម្រះវិញ" ពេត្រុសទី២ 2:9**

សង្ឃឹម៖ តែវាជាការកំសាន្តចិត្តដល់គាត់ពិតណាស់ ដែលពួកគេមិនបានយកគ្រឿងអលង្ការពីគាត់បាននោះ។

គ្រីស្ទាន៖ វាត្រូវតែជាការកំសាន្តចិត្តដ៏ធំដល់គាត់ហើយ ដែលគាត់បានប្រើវាតាមដែលគាត់ត្រូវប្រើនោះ តែអ្នកប្រាប់ខ្ញុំពីរឿងនេះនិយាយថា គាត់មិនសូវចេះប្រើប្រាស់វាទេតាមផ្លូវរហូតទៅ ហើយការនោះដោយសារតែការស្រងាកចិត្តដែលគាត់មានក្នុងកាលដែលលុយរបស់គាត់ត្រូវគេយកទៅ។ ពិតណាស់ គាត់បានភ្លេចពីផ្នែកដ៏ធំតាមផ្លូវធ្វើដំណើរបន្តទៅទៀត។ ហើយក្រៅពីនោះ ពេលណាដែលវាលេចមកនៅក្នុងគំនិតរបស់គាត់ ហើយគាត់បានទទួលការកំសាន្តចិត្តដោយការនោះ បន្ទាប់មកមានគំនិតពីការបាត់បង់របស់គាត់មករកគាត់ជាថ្មីម្តងទៀត។ ហើយគំនិតទាំងនោះត្រូវបានលេបត្របាក់ទៅទាំងអស់។

សង្ឃឹម៖ ព្រះអើយ បុរសកំសត់អើយ ការនេះពិតជាការដែលគួរសោកសង្រេងខ្លាំងណាស់សម្រាប់គាត់។

គ្រីស្ទានៈសេចក្តីទុក្ខសោក! អេ វាជាសេចក្តីទុក្ខសោកមែន។ តើវានឹងមិនកើតឡើងដូច្នេះទេដល់យើងដែរទេឬ ប្រសិនបើអ្នកណាម្នាក់នៃពួកយើងត្រូវបានជួបដូចគាត់ ដែលត្រូវគេប្លន់និងធ្វើឱ្យមានរបួសផង ហើយទាំងនៅកន្លែងមួយដែលប្លែក ដូចជាគាត់ដែរនោះ? វាជាការអស្ចារ្យដែលគាត់មិនស្លាប់ដោយសេចក្តីសោកសង្រេង ចិត្តក៏កំសត់អើយ! មានគេប្រាប់ខ្ញុំថា គាត់ត្រូវបានបង្ហាញមកស្ទើតែតាមផ្លូវរហូតបែបដូចជាក្រៀមក្រំនិងមានការរអ៊ូរទាំយ៉ាងល្វីងជូរចត់។ ក៏បានប្រាប់ដល់អ្នកដែលមកតាមទាន់គាត់ផង ឬអ្នកដែលតាមទាន់គាត់ក្នុងកាលដែលគាត់ធ្វើដំណើរតាមផ្លូវ នៅត្រង់កន្លែងដែលគាត់ត្រូវគេប្លន់ និងពីរបៀបដែលគាត់បានត្រូវគេប្លន់ ពីអ្នកដែលបានធ្វើដូច្នេះមកកាន់គាត់ ហើយពីអ្វីដែលគាត់បានបាត់បង់ ថាគាត់ត្រូវរបួសប៉ុណ្ណា ហើយថាគាត់មិនងាយនឹងគេចផុតរួចខ្លួនយ៉ាងណា។

សង្ឃឹមៈ តែវាជាការអស្ចារ្យដែលភាពចាំបាច់របស់គាត់ មិនបានធ្វើឱ្យគាត់លក់ឬបញ្ចាំគ្រឿងអលង្ការរបស់គាត់សោះ ដែលគាត់នឹងអាចមានវាដើម្បីនឹងបន្ទូរដល់ខ្លួននៅក្នុងការធ្វើដំណើររបស់គាត់។

គ្រីស្ទានៈ អ្នកនិយាយដូចជាក្បាលខ្លួនជាស្នូកអីចឹងនៅថ្ងៃនេះ តើគួរឱ្យគាត់បញ្ចាំរបស់ទាំងនោះដើម្បីអ្វី? ឬថា តើគាត់នឹងលក់របស់ទាំងនោះទៅដល់អ្នកណា? នៅពេញមួយប្រទេស ដែលជាកន្លែងគាត់ត្រូវគេប្លន់យកគ្រឿងអលង្ការរបស់គាត់ មិនត្រូវបានគេរាយការណ៍ឡើយ គាត់ក៏មិនចង់បានការកម្សាន្តចិត្តពីនោះមកជួយគាត់ផង។ ក្រៅពីនោះ គ្រឿងអលង្ការរបស់គាត់ត្រូវបានបាត់នៅឃ្លោងទ្វារនៅទីក្រុងស្ថានសួគ៌ គាត់ត្រូវបាន (ហើយគាត់បានដឹងច្បាស់ផង) រាប់ចេញពីមរតកមួយពីទីនោះ។ ហើយអាចនឹងអាក្រក់

ជាងនោះសម្រាប់គាត់ជារូបរាងខាងក្រៅ និងសេចក្តីកំសោយនៃចោរមួយម៉ឺនទៅទៀត។

សង្ឃឹម៖ បងប្រុសខ្ញុំអើយ ហេតុអ្វីបានជាបងមុតមាំម្ល៉េះ? អេសាវបានលក់សិទ្ធិជាកូនច្បងរបស់គាត់ ហើយដោយសារតែស៊ុបមួយចានប៉ុណ្ណោះ។ ហើយសិទ្ធិជាកូនច្បងនោះជាគ្រឿងអលង្ការដ៏ធំរបស់គាត់។

**“ក្រែងមានអ្នកកំផិត ឬមនុស្សទមិឡ្មណា ដូចជាអេសាវ ដែលលក់ច្បាប់បងច្បងរបស់ខ្លួន សង្វាតឱ្យបានតែម្ហូប១មុខប៉ុណ្ណោះដែរ” ហេព្រើរ 12:16**

ហើយប្រសិនបើគាត់អីចឹង ម្តេចបានជាជំនឿតិចមិនបានធ្វើអីចឹងដែរទៅ?

គ្រីស្ទាន៖ អេសាវបានលក់សិទ្ធិជាកូនច្បងរបស់គាត់ពិតមែន ហើយអ្នកក្រៅពីនោះផ្សេងទៀតក៏ធ្វើអីចឹងដែរ។ ហើយដោយធ្វើអីចឹង បានដកខ្លួនរបស់ពួកគេចេញពីព្រះពរធំបំផុត ដូចជាមនុស្សកំផិតនោះបានធ្វើដែរ។ តែអ្នកត្រូវតែដាក់ភាពខុសគ្នារវាងអេសាវនិងជំនឿតិច។ ហើយរវាងសម្បត្តិរបស់ពួកគេដែរ។ សិទ្ធិជាកូនច្បងរបស់អេសាវវាម្យ៉ាងទៅ តែគ្រឿងអលង្ការរបស់ជំនឿតិចមិនអីចឹងទេ។ ពោះរបស់អេសាវជាព្រះរបស់គាត់ តែពោះរបស់ជំនឿតិចមិនដូច្នោះទេ។

**“នោះអេសាវឆ្លើយថា បងស្លាប់ឥឡូវហើយ ដូច្នេះ តើអំណាចនោះមានប្រយោជន៍អ្វីដល់បងទៀត” លោកុប្បត្តិ 25:32**

ការចង់បានរបស់អេសាវគឺនៅក្នុងចំណង់ខាងសាច់ឈាម។ ការចង់បានរបស់ជំនឿតិចវិញមិនបានធ្វើដូច្នោះទេ។ ក្រៅពីនេះអេសាវមិនអាចមើលឃើញអ្វីដែលហួសពីការបំពេញតាមតណ្ហារបស់គាត់ឡើយ ដោយនិយាយថា "ដ្បិតខ្ញុំជិតស្លាប់ហើយ"។ "តើសិទ្ធិបងច្បងនេះមានអ្វីល្អដល់ខ្ញុំទៅ?" ប៉ុន្តែ ជំនឿតិចវិញ ទោះបីជាចំណែកមិនមានច្រើន ក្រៅពីជំនឿតិចតួចក៏ដោយ គឺដោយសារជំនឿតិចតួចរបស់គាត់ ដែលបានការពារគាត់ពីការខ្វះខ្ជាយបែបនេះ។ ហើយបានធ្វើឱ្យមើលឃើញនិងផ្តល់តម្លៃដល់គ្រឿងអលង្ការរបស់គាត់ច្រើនជាង ការលក់ឱ្យពួកគេដូចជាអេសាវបានលក់សិទ្ធិពីកំណើតរបស់គាត់។ អ្នកមិនធ្លាប់អាននៅកន្លែងណាដែលអេសាវមានជំនឿទេ មិនមានបន្តិចបន្តួចផង។ ដូច្នេះមិនគួរឱ្យងឿងឆ្ងល់ទេ ប្រសិនបើកន្លែងណាដែលសាច់មិនចេះរង្គោះរង្គើ (ដូចជាបុរសដែលគ្មានជំនឿនឹងតស៊ូ) ប្រសិនបើគាត់លក់សិទ្ធិច្បងរបស់គាត់ និងព្រលឹងរបស់គាត់និងទាំងអស់ទៅអារក្សនៃនរក ដ្បិតវាប្រៀបបាននឹងសត្វលាដែលគេពុំអាចបែរចេញមិនមើលបាន។

**"ជាលាព្រៃក្រមុំដែលធ្លាប់នៅទីរហោស្ថាន ក៏ស្រេងក្លិនខ្យល់ដោយមានសម្រើប លុះរដូវកំណាត់របស់វា នោះតើអ្នកណានឹងបំបែរចេញបាន អ្នកណាដែលរកចាប់វា នោះមិនបាច់នឿយហត់នឹងទៅតាមទេ ដ្បិតដល់រដូវកំណាត់នោះនឹងបានប្រទះហើយ" យេរេមា 2:24**

នៅពេលដែលគំនិតរបស់ពួកគេត្រូវបានដាក់ទៅលើតណ្ហារបស់ពួកគេ ពួកគេនឹងបានវាមក ទោះបីពួកគេចំណាយអ្វីក៏ដោយ។ ប៉ុន្តែ ជំនឿតិច ជាមនុស្សដែលមានកំហឹងមួយផ្សេងទៀត គឺគំនិតរបស់គាត់គឺផ្តោតលើអ្វីៗ

ដែលជារបស់ព្រះវិញ។ ជីវិតរស់នៅរបស់គាត់ពឹងផ្អែកលើអ្វីៗខាងវិញ្ញាណ និងមកពីខាងលើវិញ ដូច្នេះតើមនុស្សដែលមានកំហឹងបែបនេះគួរលក់គ្រឿងអលង្ការរបស់គាត់ (តើមានអ្នកណាដែលចង់ទិញរបស់ទាំងនោះ) ដើម្បីបំពេញចិត្តរបស់គាត់ជាមួយរបស់របរទទេឬ? តើមនុស្សនឹងយកកាក់ដើម្បីបំពេញក្រពះជាមួយនឹងចំបើងឬ? ឬ តើអ្នកអាចបញ្ចុះបញ្ចូលអណ្តើកអោយរស់នៅលើសាកសពរលួយដូចជាសត្វក្អែកបាន? ទោះបីជាមនុស្សដែលមិនមានជំនឿអាចធ្វើបាន សម្រាប់តណ្ហាខាងសាច់ឈាម ការបញ្ចាំ ប្តូរ ឬលក់អ្វីដែលពួកគេមានហើយពួកគេត្រូវចាប់ផ្តើមដោយខ្លួនឯង។ តែពួកគេមានជំនឿ ជាជំនឿបានសេចក្តីសង្គ្រោះ បើទោះជាជំនឿបន្តិចបន្តួចក៏ដោយ ក៏ពុំអាចធ្វើការនោះបានដែរ។ ដូច្នេះនៅទីនេះ បងប្អូនរបស់ខ្ញុំអើយ គឺជាកំហុសរបស់អ្នកហើយ។

សង្ឃឹម៖ ខ្ញុំទទួលស្គាល់ការនោះ តែការឆ្លុះបញ្ចាំងយ៉ាងមុតមាំរបស់អ្នកស្ទើរតែធ្វើឱ្យខ្ញុំខឹងហើយ។

គ្រីស្ទាន៖ ហេតុអ្វី ខ្ញុំគ្រាន់តែប្រៀបធៀបអ្នកទៅបក្សីខ្លះ ដែលខ្ជិលច្រអូសនោះ ដែលវារត់ទៅរត់មកនៅក្នុងផ្លូវដានជើងគេមានស្នូកនៅលើក្បាលរបស់ពួកគេ តែឆ្លងកាត់ការនោះ ហើយពិចារណានូវបញ្ហាក្នុងការជជែកវែកញែក ហើយការទាំងអស់នឹងបានល្អឡើងវិញរវាងអ្នកនិងខ្ញុំ។

សង្ឃឹម៖ តែ គ្រីស្ទានអើយ មនុស្សបីនាក់នេះ ខ្ញុំគិតនៅក្នុងចិត្តថា ជាគ្នារបស់មនុស្សកំសាក។ តើអ្នកគិតថា ពួកគេបានរត់ដូចដែលពួកគេបានធ្វើនោះ ដែលមានសម្លេងដែលឮដើរមកតាមផ្លូវនោះ? ហេតុអ្វីបានជាជំនឿតិចមិនទាញយកចិត្តដែលធំជាងនេះចេញមក? ខ្ញុំគិតថា គាត់អាចនឹងបានឈរនៅក្នុងចំណោមរបស់ពួកគេដែរហើយ ហើយបានធ្វើតាមពួកគេនៅពេលវិធីសាស្រ្តអ្វីនោះ។

គ្រីស្ទាន៖ មនុស្សជាច្រើននិយាយថាពួកគេជាមនុស្សកំសាកមែន តែមនុស្សតិចទេគិតបែបនោះនៅក្នុងពេលដែលមានទុក្ខវេទនា។ សម្រាប់ចិត្តធំនោះវិញ ជំនឿតិចមិនមានទេ ហើយខ្ញុំឃើញថាដោយសារអ្នកបងប្អូនខ្ញុំអើយ អ្នកជាមនុស្សគួរឱ្យ ខ្វល់ខ្វាយមែន ដែលអ្នកគ្រាន់តែជាជក់មួយ ហើយបន្ទាប់មកក៏ត្រូវធ្វើឱ្យ ទន់ចិត្ត។ ហើយពិតណាស់ ក្នុងកាលដែលនេះជាកំពស់នៃក្រពះរបស់អ្នក វាស្ថិតនៅចម្ងាយមួយពីយើង ពួកគេគួរតែលេចមកដល់អ្នកដូចដែលពួកគេបង្ហាញដល់គាត់នោះ ពួកគេនឹងធ្វើឱ្យ អ្នកគិតដល់គំនិតទីពីរ។

ប៉ុន្តែពិចារណាម្តងទៀត ពួកគេគ្រាន់តែជាចោរដល់អ្នកដំណើរប៉ុណ្ណោះ ពួកគេបម្រើដល់ស្តេចនៃរណ្តៅដែលគ្មានបាត ជាអ្នកប្រសិនបើត្រូវការនឹងមកជាជំនួយដល់ពួកគេខ្លួនឯងតែម្តង ហើយសម្លេងរបស់គាត់ប្រៀបដូចនឹងសត្វតោគ្រហឹម។

**"ចូរឱ្យ ដឹងខ្លួន ហើយចាំយាមចុះ ព្រោះអារក្សដែលជាខ្មាំងសត្រូវរបស់អ្នករាល់គ្នា វាតែងដើរក្រវែល ទាំងគ្រហឹមដូចជាសិង្ហ ដើម្បីនឹងរកអ្នកណាដែលវា**

នឹងត្របាក់លេបបាន” ពេត្រុសទី១ 5:8

ខ្លួនខ្ញុំផ្ទាល់ត្រូវបានជួបដូចជាជំនឿតិចដែរ។ ហើយខ្ញុំបានរកឃើញថា វាជារឿងដ៏គួរឱ្យភ័យខ្លាច។ ជនទុច្ចរិតទាំងបីនេះដាក់មកលើខ្ញុំ ហើយខ្ញុំចាប់ផ្ដើមដូចជាគ្រីស្ទានម្នាក់ ក៏បានតស៊ូនឹង ពួកគេគ្រាន់តែស្រែករកប៉ុណ្ណោះ ហើយម្ចាស់របស់ពួកគេក៏មក។ ខ្ញុំអាចនឹងអោយជីវិតខ្ញុំត្រឹមតែមួយសេន ប៉ុន្តែឱ្យតែវាដូចអ្វីដែលព្រះសព្វព្រះហឫទ័យចុះ ខ្ញុំមានបំពាក់ដោយអាវុធជាភស្តុតាង។ អេ តែខ្ញុំបានគិតថាទោះបីខ្ញុំខំប្រឹងយ៉ាងខ្លាំងក៏ដោយ ក៏ខ្ញុំពិបាកនឹងបោះបង់ចោលដូចជាបុរសនោះណាស់។ គ្មានអ្នកណាម្នាក់អាចប្រាប់ពីអ្វីនឹងកើតមានឡើងនៅក្នុងការប្រយុទ្ធនោះឡើយ ដែលថាម្នាក់ដែលជា ព្រះគុណអស្ចារ្យ បាននៅក្នុងការប្រយុទ្ធដោយផ្ទាល់។

សង្ឃឹម៖ ពិតណាស់ តែពួកគេបានរត់ ដូចអ្នកឃើញហើយ នៅពេលដែលពួកគេគិតថា ព្រះអង្គព្រះគុណអស្ចារ្យកំពុងតែមកតាមផ្លូវនោះ។

គ្រីស្ទាន៖ ពិតណាស់ពួកគេបានភៀសខ្លួនជាញឹកញាប់ទាំងពួកគេនិងម្ចាស់របស់ពួកគេ នៅពេលព្រះគុណអស្ចារ្យគ្រាន់តែបង្ហាញខ្លួនមក ហើយមិនមានចម្ងល់ទេ ដោយសារទ្រង់ជាម្ចាស់ជើងឯករបស់ស្ដេច ប៉ុន្តែខ្ញុំចង់ឱ្យ អ្នកដាក់ភាពខុសគ្នាខ្លះរវាងជំនឿតិចនិងជើងឯងរបស់ស្ដេច។ អ្នកបម្រើរបស់ស្ដេចមិនមែនជាម្ចាស់ជើងឯកឡើយ ពួកគេក៏មិនអាចធ្វើសង្គ្រាមបានដូចគាត់ដែរ។ តើវាសមទេដែលនឹងគិតថាក្មេងតូចមួយអាចចាត់ការកូលីយ៉ាតដូចដាវីឌបានធ្វើដែរនោះ? ឬថា តើគួរតែមានកម្លាំងរបស់គោនៅក្នុងការ

កន្ត្រាក់ទេ? អ្នកខ្លះខ្លាំង អ្នកខ្លះខ្សោយ អ្នកខ្លះមានជំនឿធំ អ្នកខ្លះមានតិចតួច។ បុរសនេះជាមនុស្សទន់ខ្សោយម្នាក់។ ដូច្នេះគាត់ក៏ទៅកាន់ឯជញ្ជាំង។

សង្ឃឹមៈ ខ្ញុំចង់ឱ្យ នោះជាព្រះគុណអស្ចារ្យមកធ្វើសម្រាប់ពួកគេ។

គ្រីស្ទានៈប្រសិនបើវាជាគាត់វិញ គាត់ប្រហែលជាមានដៃពេញ។ ដោយសារខ្ញុំត្រូវតែប្រាប់អ្នកថា ទោះបីជាព្រះគុណអស្ចារ្យពូកែប្រើអាវុធរបស់គាត់ ហើយគាត់បានធ្វើសម្រេច ហើយអាចធ្វើបានក៏ដោយ ដរាបណាគាត់រក្សាពួកគេនៅដាវ - បានល្អគ្រប់គ្រាន់ជាមួយពួកគេ តែប្រសិនបើពួកគេចូលក្បែរគាត់វិញ សូម្បីតែ បាក់ទឹកចិត្ត មិនទុកចិត្ត ឬអ្នកផ្សេងទៀត វានឹងពិបាក ប៉ុន្តែពួកគេនឹងបោះចោលនៅកែងជើងរបស់គាត់។ ហើយនៅពេលបុរសធ្លាក់ចុះ ដូចដែលអ្នកដឹងហើយ - តើគាត់អាចធ្វើអ្វីបាន?

អ្នកដែលក្រឡេកមើលមុខរបស់មុខរបស់ព្រះគុណអស្ចារ្យ នឹងឃើញស្នាម និងស្នាមកាត់ទាំងនោះ ដែលងាយនឹងបង្ហាញអ្វីដែលខ្ញុំបាននិយាយមក (ហើយនៅពេលគាត់នៅក្នុងសមរភូមិ) "យើងអស់សង្ឃឹមសូម្បីតែជីវិតរស់នៅ"។ តើមេទ័ពដ៏មុតមាំនិងក្រុមកូនចៅរបស់ពួកគេទាំងនេះបានធ្វើឱ្យដាវីឌថ្ងូរ ទួញយំ និងស្រែករោទ៍យ៉ាងដូចម្ដេច? មែន ហេម៉ាននិងហេសេគាផងដែរ បើទោះជាពួកគេជាម្ចាស់ជើងឯកក្នុងជំនាន់របស់ពួកគេក៏ដោយ ក៏ត្រូវបានបង្ខំឱ្យចាប់ពួកគេផ្ដើមធ្វើឡើយ នៅពេលដែលមានការរំលោភបំពាន ទោះយ៉ាងណាពួកគេមានអាវធំរបស់ពួកគេដុសខាត់យ៉ាងល្អ។ នៅពេលមួយ ពេត្រុសព្យាយាមធ្វើអ្វីដែលគាត់អាចធ្វើបាន ប៉ុន្តែទោះបីជាមានអ្នកខ្លះនិយាយអំពីគាត់ថាគាត់ជាព្រះរាជ្យបុត្រនៃពួកសាវកក៏ដោយ ការទាំងនោះ

បានធ្វើឱ្យ ចុងក្រោយភ័យក្លាចដល់ក្មេងស្រីកំសត់ម្នាក់។

ក្រៅពីនេះ ស្តេចរបស់ពួកគេកំពុងតែឱ្យ សញ្ញាដល់ពួកគេ ហើយប្រសិនបើ នៅពេលណាដែលពួកគេត្រូវគេធ្វើបាបបំផុតនោះ បើសិនជាអាចគាត់នឹង មកដើម្បីជួយពួកគេ។ មានគេនិយាយពីគាត់ថា៖ "ដាវរបស់ដែលផ្តេកនៅ ក្បែរមនុស្សម្នាក់ដែលមិនអាចកាន់បាន គឺលំពែង ព្រួញ និងជាងឈើ។ គាត់ ចាត់ទុកដែកដូចជាចំបើង ហើយលង្ហិនដូចជាឈើរលួយ។ ព្រួញមិនអាចធ្វើ ឱ្យគាត់រត់គេចបានឡើយ។ គ្រាប់ជំពាមនឹងត្រូវគេរាប់ដូចជាចំបើង គាត់ សើចនឹងការគ្រវីរបស់លំពែង"។

**"បើអ្នកណានឹងយកដាវទៅកាប់វា ក៏មិនឈ្នះ ហើយលំពែង ដែកពួយ ឬស្នក៏ ឥតប្រយោជន៍។ វារាប់ដែកដូចជាចំបើង ហើយលង្ហិនដូចជាឈើពុក។ ព្រួញ នឹងធ្វើឱ្យ វារត់មិនបាន ហើយថ្មបាញ់ក៏ត្រឡប់ដូចជាជញ្ជ្រាំងដល់វា។ វារាប់ មោងដូចជាចំបើង ហើយក៏សើចឡកដល់ដែកដែលគេពួយមក" យ៉ូប 41:26-29**

តើមនុស្សម្នាក់អាចធ្វើអ្វីបានក្នុងករណីនេះ? ជាការពិត ប្រសិនបើបុរសម្នាក់ អាចមានសេះរបស់យ៉ូប ហើយមានជំនាញ និងភាពក្លាហានក្នុងការជិះវា នោះ គាត់អាចធ្វើអ្វីដែលគួរឱ្យកត់សម្គាល់។ ត្បិត ករបស់គាត់មានបំពាក់ ដោយផ្គរលាន់ ហើយគាត់នឹងមិនខ្លាចដូចកណ្តូបទេ សិរីរុងរឿងនៃច្រមុះ របស់គាត់គឺគួរអោយខ្លាចណាស់។ វាមិនរង្គោះរង្គើឡើយ ហើយក៏មិនងាក ចេញពីដាវដែរ។ ព្រួញលោតទៅរកគាត់ លំពែងភ្លឺរលោងនិងខែលផង។

គាត់លេបដីសន្ទប់នឹងកំហឹងយ៉ាងខ្លាំង ហើយក៏មិនជឿថាគាត់ជាសំឡេងត្រែនោះដែរ។ ក្នុងចំណោមសំឡេងត្រែ ហាស ហាស ហើយគាត់ធុំក្លិនសមរភូមិពីចម្ងាយ ផ្លេកបន្ទោរនៃពួកមេទ័ព និងសម្លេងស្រែក"។

"តើឯងឬអី ដែលឱ្យ សេះមានកម្លាំង តើឯងឬអីដែលតាក់តែងឱ្យ សេះមានសក់ដែលរលាស់ដោយខ្យល់។ តើឯងឬអី ដែលធ្វើឱ្យ វាអាចលោតដូចជាកណ្តូប ឯអាការៈកំញើញរបស់វា នោះគួរស្ញែងខ្លាច។ វាកាយប្ញូលដីនៅវាលច្រកភ្នំ ហើយក៏អរសប្បាយដោយកម្លាំងវា ក៏ចេញទៅប្រទល់នឹងមនុស្សដែលពាក់គ្រឿងសស្ត្រាវុធ។ វាមើលងាយសេចក្តីភិតភ័យ ហើយមិនចេះរុញរាឡើយ ក៏មិនដែលគេចចេញពីដាវដែរ។ បំពង់ព្រួញក៏ឮក្រុកក្រាក់នៅលើវាព្រមទាំងលំពែងដែលភ្លឺផ្លេកៗ និងដែកពួយផង។ វាកញ្ជ្រោលអន្ទះសាទាំងតន្ត្រំដី ហើយកាលឮសូរត្រែ នោះទប់វាមិនបានឡើយ។ វេលាណាដែលវាឮសូរត្រែ នោះវាស្រែកថា ហេះហេ វាស្រងក្លិនចម្បាំងពីចម្ងាយ ក៏ស្គាល់សម្រែកនៃពួកមេទ័ព និងសូរទ្រហឹងអឺងអាប់។" យ៉ូប 39:19-25

ប៉ុន្តែចំពោះអ្នកដើរជើងដូចអ្នកនិងខ្ញុំ សូមកុំអោយយើងមានចិត្តចង់ជួបជាមួយខ្មាំងសត្រូវ ឬអួតខ្លួនដូចជាយើងអាចធ្វើបានប្រសើរជាងនោះឡើយ នៅពេលយើងឮគេនិយាយពីអ្នកដទៃដែលត្រូវបានគេធ្វើបាបនោះ ហើយក៏មិនត្រូវសើចសប្បាយដោយគំនិតខ្លួនថាដូចជាមនុស្សប្រុសនោះឡើយ ពីព្រោះរឿងបែបនេះច្រើនតែអាក្រក់បំផុតនៅពេលដែលត្រូវគេសាកល្បង។ សាក្សីពេត្រុស ជាអ្នកដែលខ្ញុំបានលើកឡើងពីមុន។ គាត់នឹងប្តូរវេន ទៅគាត់នឹងធ្វើដូចជាគំនិតឥតប្រយោជន៍របស់គាត់បានជំរុញឱ្យគាត់និយាយថា ចូរ

ធ្វើឱ្យ បានល្អជាងហើយឈរនៅសម្រាប់ម្ចាស់របស់គាត់ច្រើនជាងគេ ប៉ុន្តែ តើអ្នកណាដែលត្រូវបានគេបំភិតបំភ័យ ហើយត្រូវរត់ចុះដោយមនុស្ស អាក្រក់ទាំងនេះដូចជាគាត់ដែរនោះ?

ដូច្នេះ កាលណាយើងឮគេនិយាយថាមានចោរប្លន់បែបនេះកើតឡើងនៅលើ ផ្លូវស្តេច មានរឿងពីរដែលយើងត្រូវធ្វើ។ មុនដំបូង ត្រូវចេញទៅក្រៅដោយ ប្រដាប់ខ្លួនរួចរាល់ ហើយត្រូវប្រាកដថាយើងមានខែលការពារទៅជាមួយ។ ដោយសារតែវាចង់បានរបស់នោះហើយ ដែលវាបានលាតត្រដាងយ៉ាង លោភលន់នៅលេវៀថាន់  ពុំអាចបង្កើតផលបានទេ។ ត្បិតបើ ការនោះគេ ចង់បាន គាត់មិនខ្លាចយើងទាល់តែសោះ។ ដូច្នេះ អ្នកដែលមានជំនាញបាន និយាយថា "សំខាន់បំផុតនោះ ចូរយកខែលនៃសេចក្តីជំនឿដែលអ្នកនឹង អាចពន្លត់ព្រួញភ្លើងទាំងប៉ុន្មានរបស់មនុស្សអាក្រក់"។

**"ថែមទាំងយកសេចក្តីជំនឿទុកជាខែលផង ដែលអ្នករាល់គ្នានឹងអាចរំលត់ អស់ទាំងព្រួញឆេះរបស់មេកំណាច ដោយសារខែលនោះបាន" អេភេសូ 6:16**

ជាការប្រសើរណាស់ដែលយើងចង់អោយក្បួនដង្ហែស្តេច ដើម្បីឱ្យ ទ្រង់បាន ទៅជាមួយយើងផ្ទាល់។ នេះបានធ្វើអោយដាវីឌមានអំណរ នៅពេលដែល នៅក្នុងជ្រលងភ្នំនៃស្រមោលនៃសេចក្តីស្លាប់។ ហើយលោកម៉ូសេអាចជា ត្រូវស្លាប់នៅកន្លែងដែលគាត់ឈរ ជាងការបោះជំហានមួយជំហានដោយ គ្មានព្រះរបស់គាត់។

"ម៉ូសេក៏ទូលថា បើសិនណាជាព្រះវិញ្ញាណនៃទ្រង់មិនយាងទៅជាមួយទេ នោះសូមកុំនាំយើងខ្ញុំរាល់គ្នាឡើងចេញពីទីនេះទៅឡើយ" **និក្ខមនំ 33:15**

អូ! បងប្អូនអើយប្រសិនបើទ្រង់ព្រមទៅជាមួយពួកយើង តើមានអ្វីដែលយើងត្រូវខ្លាចដល់មនុស្សរាប់ម៉ឺននាក់ដែលនឹងលើកទ័ពមកទាស់នឹងយើងនោះ? តែបើគ្មានទ្រង់ទេ នោះអ្នកជំនួយដែលមានអំនួតនឹងត្រូវគេសម្លាប់ហើយ។

"ខ្ញុំបានដេកលក់ទៅ ហើយក៏ភ្ញាក់ឡើងវិញ ដ្បិតព្រះយេហូវ៉ាទ្រង់ទប់ទល់ខ្ញុំ។ ខ្ញុំមិនខ្លាចដល់មនុស្សទាំងសល់សែន ដែលបានតាំងខ្លួនព័ទ្ធជុំវិញទាស់នឹងខ្ញុំឡើយ។ ឱព្រះយេហូវ៉ាអើយ សូមទ្រង់ក្រោកឡើង ឱព្រះនៃទូលបង្គំអើយ សូមទ្រង់ជួយសង្គ្រោះទូលបង្គំផង ដ្បិតគឺទ្រង់ដែលទះកំផ្លៀងអស់ទាំងខ្មាំងសត្រូវនៃទូលបង្គំ ទ្រង់បំបាក់ធ្មេញរបស់ពួកមនុស្សអាក្រក់ដែរ។ ឯសេចក្ដីសង្គ្រោះ នោះស្រេចនៅព្រះយេហូវ៉ា សូមឱ្យ ព្រះពរទ្រង់បាននៅលើរាស្ត្រទ្រង់ចុះ។ " **ទំនុកដំកើង 3:5-8**

"ព្រះយេហូវ៉ាទ្រង់ជាពន្លឺ ហើយជាសេចក្ដី សង្គ្រោះរបស់ខ្ញុំ តើខ្ញុំនឹងត្រូវខ្លាចចំពោះអ្នកណា ព្រះយេហូវ៉ាទ្រង់ជាទីពឹងពំនាក់នៃជីវិតខ្ញុំ តើត្រូវឱ្យ ខ្ញុំភ័យចំពោះអ្នកណា។ កាលមនុស្សអាក្រក់ គឺជាពួកទាស់ទទឹង ហើយជាខ្មាំងសត្រូវនៃខ្ញុំបានសង្ឃកមកលើខ្ញុំ ដើម្បីនឹងស៊ីសាច់ខ្ញុំ នោះគេបានជំពប់ដួលទាំងអស់គ្នា។ ទោះបើមានពួកពលមកបោះទ័ពច្បាំងនឹងខ្ញុំ គង់តែចិត្តខ្ញុំមិនភ័យឡើយ ទោះបើកើតមានចម្បាំងទាស់នឹងខ្ញុំ គង់តែខ្ញុំនឹងមានចិត្តសង្ឃឹមបានដែរ" **ទំនុកដំកើង 27:1-3**

**"នៅគ្រានោះ ឯងនឹងបានតែកន្លែងឱនចុះ នៅកណ្ដាលពួកឈ្លើយប៉ុណ្ណោះ ហើយនិងត្រូវដួល នៅក្រោមខ្មោចនៃពួកអ្នកដែលត្រូវគេសម្លាប់ ទោះបើធ្វើទោសជាច្រើនដល់ម្ល៉េះក៏ដោយ គង់តែសេចក្ដីខ្ញាល់របស់ទ្រង់មិនទាន់បែរចេញនៅឡើយ គឺព្រះហស្តទ្រង់នៅតែលូកមកទៀត។" អេសាយ 10:4**

សម្រាប់ខ្ញុំ ខ្ញុំបានស្ថិតនៅក្នុងភាពស្រពេចស្រពិលពីមុនហើយ (ដោយសារសេចក្ដីសម្បុរសរបស់ទ្រង់ដែលល្អបំផុតនោះ) ខ្ញុំដូចអ្វីដែលអ្នកបានឃើញហើយ បានរស់រានមានជីវិត តែខ្ញុំនៅតែមិនអាចអួតខ្លួនអំពីភាពជាបុរសរបស់ខ្ញុំបានឡើយ។ ខ្ញុំពិតជារីករាយណាស់ប្រសិនបើខ្ញុំមិនបានជួបជាមួយស្នាមជាំទៀតនោះ ទោះបីជាខ្ញុំខ្លាចថាយើងមិនអាចយកឈ្នះលើគ្រោះថ្នាក់ទាំងអស់ក៏ដោយ។ ទោះយ៉ាងណា គោនិងខ្លាឃ្មុំពុំទាន់បានលេបត្របាក់ខ្ញុំនៅឡើយ នោះខ្ញុំសង្ឃឹមថាព្រះជាម្ចាស់ក៏នឹងរំដោះយើងអោយរួចផុតពីពួកភីលីស្ទីនដែលមិនមានការកាត់ស្បែកក្រោយនេះទៀត។

បន្ទាប់មកគ្រីស្ទានបានច្រៀងថា៖

"ជំនឿតិចដ៏កំសត់អើយ! អ្នកស្ថិតក្នុងចំណោមពួកចោរ?ត្រូវគេប្លន់យ៉ាងសាហាវ? ចូរចងចាំរឿងនេះថា អ្នកណាជឿនិងទទួលបានសេចក្ដីជំនឿកាន់តែច្រើនថែមទៀត បន្ទាប់មកនឹងក្លាយជាអ្នកមានជ័យជំនះលើមនុស្សមួយម៉ឺននាក់ផង មិនដូច្នោះនឹងត្រូវភ័យក្លាចដោយសារមនុស្សបីនាក់នេះហើយ។"

# អ្នកបញ្ឆោរ

ដូច្នេះ ពួកគេបន្តទៅមុនទៀត ហើយល្ងង់ខ្លៅក៏បានដើរតាម។ ពួកគេទៅរហូតដល់កន្លែងមួយ ដែលពួកគេបានឃើញផ្លូវមួយដែលកាត់តាមផ្លូវរបស់ពួកគេ ហើយមើលទៅផ្លូវនោះដេកត្រង់ដូចជាផ្លូវដែលពួកគេគួរទៅណាស់ ហើយនៅទីនេះពួកគេមិនដឹងថាត្រូវជ្រើសរើសផ្លូវមួយណាទេ ដោយសារផ្លូវទាំងពីរមើលទៅសុទ្ធតែត្រង់នៅចំពោះពួកគេ។ ដូច្នេះនៅទីនេះ ពួកគេឈរស្ងៀមដើម្បីធ្វើការពិចារណាមើលសិន។ ហើយកាលដែលពួកគេកំពុងតែគិតអំពីផ្លូវនោះ មានបុរសម្នាក់ មានសាច់ខ្មៅ តែគ្របបាំងដោយសំលៀកបំពាក់យ៉ាងស មករកពួកគេហើយសួរថា "ហេតុអ្វីបានជាអ្នកឈរនៅទីនោះអីចឹង?" ពួកគេឆ្លើយថា "ពួកគេឆ្លើយថាពួកគេកំពុងតែទៅកាន់ទីក្រុងស្ថានសួគ៌ តែមិនដឹងថាត្រូវរើសផ្លូវមួយណា។" "មកតាមខ្ញុំមក" បុរសនោះនិយាយ "ខ្ញុំក៏កំពុងទៅទីនោះដូចគ្នា។" ដូច្នេះពួកគេបានដើរតាមគាត់តាមផ្លូវនោះ តែពេលនេះមកដល់ផ្លូវនោះ ដែលវាបានបែរចេញហើយបែរចេញទៀតពីទីក្រុងដែលពួកគេប្រាថ្នាចង់ទៅ មិនយូរប៉ុន្មានមុខរបស់ពួកគេត្រូវបានបែរចេញពីទីក្រុងនោះ តែពួកគេបានដើរតាមបុរសនោះវិញ។ ប៉ុន្តែយូរៗទៅមុនពេលដែលពួកគេភ្ញាក់ខ្លួន បុរសនោះបាននាំពួកគេចូលទៅក្នុងត្រីវិស័យនៃសំណាញ់ ដែលពួកគេទៅជាប់ប្រទាក់នឹង ហើយពួកគេមិនដឹងថាត្រូវធ្វើយ៉ាងណា ហើយដូច្នោះសំលៀកបំពាក់សក៏ត្រូវបានធ្លាក់ចេញពីខ្នងរបស់បុរសខ្មៅនោះ។ បន្ទាប់មកពួកគេបានឃើញពីកន្លែងដែលពួកគេកំពុងនៅនោះ។ ដូច្នេះ នៅទីនោះពួកគេដេកឃំអស់មួយរយៈពេល ដោយសារពួកគេមិនអាចចេញរួចបាន។

គ្រីស្ទានៈ បន្ទាប់មកគ្រីស្ទាននិយាយទៅកាន់គ្នាគាត់ថា "ពេលនេះខ្ញុំឃើញថាខ្ញុំបានធ្វើកំហុសហើយ។ តើពួកអ្នកគង្វាលមិនបានប្រាប់យើងឱ្យប្រយ័ត្ននឹងមនុស្សបញ្ជោរទេឬអី? ដូចជាពាក្យរបស់អ្នកប្រាជ្ញានិយាយ ដូច្នេះយើងបានរកឃើញវាហើយនៅថ្ងៃនេះ។ មនុស្សដែលបញ្ជោរអ្នកជិតខាងរបស់គាត់ គឺវាយសំណាញ់ដាក់ជើងគាត់ទេ។"

**"អ្នកណាដែលបញ្ជើចដល់អ្នកជិតខាង នោះឈ្មោះថា ដាក់លប់សម្រាប់ចាប់ជើងគេទេ។" សុភាសិត 29:5**

សង្ឃឹមៈ ពួកគេក៏បានឱ្យក្រដាស់ពីទិសដៅនៃផ្លូវ សម្រាប់ឱ្យយើងបានរកទីនោះបានច្បាស់លាស់ តែយើងភ្លេចអាន ហើយមិនបានរក្សាខ្លួនយើងចេញពីផ្លូវរបស់អាមនុស្សបំផ្លាញ។ ទីនេះ ដាវីដបានឆ្លាតជាងពួកយើង ដោយគាត់បានិយាយថា "ពិចារណាពីកិច្ចការរបស់មនុស្សយើង ដោយសារពាក្យសម្ដីពីបបូរមាត់របស់អ្នក វាបានរក្សាខ្ញុំចេញពីផ្លូវរបស់មនុស្សបំផ្លាញ។"

**"ឯត្រង់ការប្រព្រឹត្តរបស់មនុស្ស នោះទូលបង្គំបានរវាំងខ្លួន ឱ្យរួចពីផ្លូវនៃមនុស្សច្រឡោត ដោយសារព្រះបន្ទូល ពីព្រះឱស្ឋទ្រង់" ទំនុកដំកើង 17:4**

ដូច្នេះពួកគេដេកនៅដោយយំទួញសោកដាក់ខ្លួនរបស់ពួកគេនៅក្នុងសំណាញ់នោះ។ ជាចុងក្រោយពួកគេឃើញម្នាក់ដែលមានពន្លឺចែងចាំងមករកពួកគេ មានរំពាត់ខ្សែរតីមួយនៅដៃរបស់គាត់។

នៅពេលដែលគាត់កំពុងមកកន្លែងដែលពួកគេនៅនោះ គាត់បានសួរពួកគេថា តើពួកគេមកពីណា? ហើយតើពួកគេធ្វើអ្វីនៅទីនោះ? ពួកគេបានប្រាប់គាត់ថា "ពួកគេជាអ្នកធ្វើធម្មយាត្រាដ៏កំសត់ធ្វើដំណើរទៅកាន់ស៊ីយ៉ូន តែត្រូវបាននាំចេញពីផ្លូវរបស់ពួកគេដោយបុរសខ្មៅម្នាក់ដែលពាក់ស ដែលបុរសនោះបានប្រាប់យើងថា "ឱ្យមកតាមគាត់ ដោយសារគាត់កំពុងតែទៅកាន់ទីនោះដែរ។" បន្ទាប់មកគាត់និយាយដោយវាយនឹងរំពាត់ថា "វាជាអ្នកបញ្ឆោរជាសាវកក្លែងក្លាយដែលបានប្រែខ្លួនទៅជាទេវតានៃពន្លឺ។""

**"អ្នកណាដែលបញ្ចើចដល់អ្នកជិតខាង នោះឈ្មោះថា ដាក់លប់សម្រាប់ចាប់ជើងគេទេ។" សុភាសិត 29:5**

**"ឯពួកអ្នកដែលប្រព្រឹត្តអាក្រក់ទាស់នឹងសេចក្តីសញ្ញា នោះវានឹងនាំបង្ខូចចិត្តគេ ដោយពាក្យបញ្ចើច តែចំណែកពួកអ្នកទាំងប៉ុន្មានដែលស្គាល់ព្រះនៃខ្លួន គេនឹងមានចិត្តរឹងប៉ឹង ហើយនិងប្រតិបត្តិតទៅ" ដានីយ៉ែល 11:32**
**"ដ្បិតមនុស្សយ៉ាងនោះជាសាវកក្លែងក្លាយ ជាអ្នកឆបោក ដែលក្លែងខ្លួនធ្វើជាសាវកនៃព្រះគ្រីស្ទទេ។ ហើយសេចក្តីនោះមិនជាអស្ចារ្យឡើយ ព្រោះអារក្សសាតាំងក៏ក្លែងខ្លួនធ្វើជាទេវតានៃពន្លឺដែរ" កូរិនថូសទី២ 11:13, 14**

ដូច្នេះគាត់បានស្រាយសំណាញ់ ហើយឱ្យបុរសទាំងពីរចេញទៅ។ បន្ទាប់មកគាត់និយាយទៅកាន់ពួកគេថា "មកតាមខ្ញុំ នោះខ្ញុំនឹងនាំពួកឯងទៅកាន់ផ្លូវរបស់ពួកឯងម្តងទៀត។" ដូច្នេះគាត់ក៏បាននាំពួកគេទៅកាន់ផ្លូវដែលពួកគេបែរចេញដើម្បីដើរតាមមនុស្សបញ្ឆោរមកនោះ។ បន្ទាប់មកគាត់បានសួរ

ពួកគេថា "តើអ្នកដេកនៅទីណាពីយប់មិញ?" ពួកគេនិយាយថា "ដេកជាមួយពួកគង្វាលនៅភ្នំនៃសេចក្តីសម្រាក។" បន្ទាប់មកគាត់សួរពួកគេថា "តើពួកគេមិនបានទទួលក្រដាស់កត់ចំណាំទិសដៅពីពួកគង្វាលទាំងនោះទេឬយ៉ាងណា?" ពួកគេឆ្លើយថា "មាន" "តែតើអ្នកបានអានទេ?" គាត់និយាយ។ ពួកគេឆ្លើយថា "ទេ" គាត់សួរពួកគេថាហេតុអ្វី? ពួកគេឆ្លើយថាពួកគេភ្លេច។ គាត់បានសួរថែមទៀតថា "ថាតើអ្នកគង្វាលមិនបានប្រាប់ពួកគេឱ្យប្រយ័ត្ននឹងមនុស្សបញ្ឆោរទេឬអ្វី?" ពួកគេបានឆ្លើយថា "បានប្រាប់ តែពួកយើងមិនបានគិតស្រម៉ៃដល់សោះ ថាមនុស្សដែលពូកែនិយាយនោះគឺជាវាម្នាក់នោះ។"

**"ដ្បិតមនុស្សបែបយ៉ាងនោះ មិនមែនគោរពប្រតិបត្តិដល់ព្រះគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នាទេ គេបម្រើតែពោះខ្លួនគេវិញ ទាំងបញ្ឆោតចិត្តមនុស្សស្លូតត្រង់ ដោយពាក្យផ្អែមពីរោះ និងពាក្យបញ្ចើចផង" រ៉ូម 16:18**

បន្ទាប់មកខ្ញុំឃើញនៅក្នុងសុបិនរបស់ខ្ញុំថា គាត់បង្គាប់ពួកគេឱ្យដេកចុះ។

**"បើអ្នកមានទោសនោះគួរឱ្យវាយ នោះចៅក្រមត្រូវឱ្យដេកទៅ ហើយឱ្យគេវាយនៅចំពោះមុខ ត្រូវវាយឱ្យគ្រប់ចំនួន ល្មមនឹងទោសអ្នកនោះ" ចោទិយកថា 25:2**

នៅពេលដែលពួកគេធ្វើតាម គាត់បានធ្វើទណ្ឌកម្មពួកគេយ៉ាងឈឺដើម្បីបង្រៀនពួកគេពីផ្លូវល្អដែលពួកគេត្រូវដើរ។

“បើកាលណាមេឃរាំងភ្លៀង ដោយព្រោះគេបានធ្វើបាបនឹងទ្រង់ នោះបើគេអធិស្ឋានតម្រង់មកឯទីនេះ ព្រមទាំងគោរពដល់ព្រះនាមទ្រង់ ហើយលះបង់ចោលអំពើបាបរបស់គេចេញ ដោយព្រោះទ្រង់បានផ្ចាញ់ផ្ចាលគេ។ នោះសូមទ្រង់ប្រោសស្តាប់ពីលើស្ថានសួគ៌ ហើយអត់ទោសចំពោះអំពើបាប របស់ពួកអ្នកបម្រើទ្រង់ គឺជាពួកអ៊ីស្រាអែលជារាស្ត្រទ្រង់ ដោយបង្រៀនឱ្យគេដឹងផ្លូវល្អណាដែលត្រូវដើរ រួចសូមបង្អុរភ្លៀង ឱ្យមកលើស្រុករបស់ទ្រង់ ដែលបានប្រទានមករាស្ត្រទ្រង់ទុកជាមរដកផង។” **របាក្សត្រទី២ 6:26, 27**

ហើយកាលដែលគាត់ធ្វើទណ្ឌកម្មដល់ពួកគេ គាត់បាននិយាយថា "កាលបើខ្ញុំស្រឡាញ់ប៉ុណ្ណា ខ្ញុំស្តីបន្ទោសនិងវាយប្រដៅប៉ុណ្ណោះដែរ ចូរជឿខ្ជាប់ខ្ជួនឡើង ហើយប្រែចិត្តចុះ។"

“អញបន្ទោស ហើយផ្ចាញ់ផ្ចាល ដល់អស់អ្នកណាដែលអញស្រឡាញ់ ដូច្នេះចូរមានចិត្តឧស្សាហ៍ ហើយប្រែចិត្តចុះ” **វិវរណៈ 3:19**

បន្ទាប់ពីការនេះចប់មក គាត់បានប្រាប់ពួកគេឱ្យទៅតាមផ្លូវរបស់ពួកគេ ហើយឱ្យស្តាប់តាមទៅកាន់ទិសដៅមួយទៀតរបស់ពួកគង្វាល។ ដូច្នេះពួកគេបានអរគុណដល់គាត់ដោយសេចក្តីសប្បុរសរបស់គាត់ ហើយចេញទៅដោយទន់ភ្លន់តាមបណ្តោយផ្លូវត្រូវទាំងច្រៀងថា

"មកទីនេះ អ្នកដែលដើរតាមផ្លូវនោះ មកមើលថាអ្នកធ្វើធម្មយាត្រាបានបែរទាសចេញទៅ! ពួកគេត្រូវចាប់ជាប់នឹងសំណាញ់ ដោយសារពួកគេបានភ្លេចពីយោបល់ល្អៗ។ នេះជាអ្នកដែលមករំដោះពួកគេពិត តែអ្នកឃើញហើយថាពួកគេត្រូវវាយប្រដៅឱ្យឈប់។ ចូរឱ្យការនេះបានជាបំរាមដល់អ្នកចុះ!"

## មនុស្សមិនជឿថាមានព្រះ

ពេលនេះបន្តិចក្រោយមក ពួកគេសម្លឹងមើលទៅឃើញពីចម្ងាយឃើញម្នាក់កំពុងដើរមកថ្មមៗតែម្នាក់ឯងតាមផ្លូវធំមកជួបពួកគេ។ បន្ទាប់មកគ្រីស្ទាននិយាយទៅកាន់គ្នាគាត់ថា "ខាងមុននោះជាបុរសម្នាក់ដែលបែរខ្នងដាក់ស៊ីយ៉ូន ហើយគាត់កំពុងតែមកជួបយើងហើយ។"

សង្ឃឹមៈ ខ្ញុំហើយគាត់ហើយ ចូរយើងប្រយ័ត្នខ្លួនយើងវិញនៅពេលនេះ មិនអីចឹងគាត់នឹងដូចជាមនុស្សបញ្ឆោរដែរហើយ។

ដូច្នេះគាត់បានខិតមកជិតហើយជិតទៀត ហើយចុងក្រោយបានមកដល់ពួកគេ។ ឈ្មោះរបស់គាត់គឺ មិនមានព្រះ។ ហើយគាត់បានសួរពួកគេថាទៅណា?

គ្រីស្ទានៈ យើងកំពុងតែទៅកាន់ភ្នំស៊ីយ៉ូន។

បន្ទាបមកគ្មានព្រះបានសើចយ៉ាងខ្លាំង

គ្រីស្ទានៈ តើអ្វីទៅជាអត្ថន័យនៃសំណើចរបស់អ្នកនោះ?

គ្មានព្រះៈ ខ្ញុំសើចដោយសារបានឃើញមនុស្សល្ងង់ដូចជាពួកឯងហ្នឹងហើយដែលត្រូវយកខ្លួនមកធ្វើដំណើរស្មើស្លាប់ស្មើរស់នេះ ហើយមិនបានអ្វីទាំងអស់ក្រៅពីការធ្វើដំណើរបានតែការឈឺចាប់ហ្នឹង។

គ្រីស្ទានៈ ហេតុអ្វីបានជាអ្នកគិតថាយើងនឹងបានទទួលអ្វីនោះ?

គ្មានព្រះ៖ បានទទួល! វាគ្មានកន្លែងណាដូចដែលឯងស្រម៉ៃនៅក្នុងលោកិយនេះឡើយ។

គ្រីស្ទាន៖ តែវាមាននៅពេលដែលលោកិយថ្មីនឹងមកដល់។

គ្មានព្រះ៖ នៅពេលដែលខ្ញុំនៅផ្ទះនៅក្នុងប្រទេសខ្ញុំ ខ្ញុំបានឮដូចដែលឯងបានអះអាងដែរ ហើយបន្ទាប់ពីបានឮហើយក៏បានចេញទៅមើល ហើយបានស្វែងរកទីក្រុងនោះអស់រយៈពេលម្ភៃឆ្នាំហើយ តែមិនបានឃើញអ្វីច្រើនក្រៅពីអ្វីដែលខ្ញុំបានឃើញពេលចេញមកដំបូងនោះទេ។

**"មើលគេសួរទូលបង្គំថា តើព្រះបន្ទូលនៃព្រះយេហូវ៉ានៅឯណា ឱ្យការនោះមកឥឡូវចុះ។" យេរេមា 17:15**
**"ការដែលមនុស្សល្ងីល្ងើខំធ្វើ នោះធ្វើឱ្យខ្លួននឿយហត់គ្រប់គ្នា ពីព្រោះគេមិនដឹង ទៅឯទីក្រុងតាមផ្លូវណាទេ។" សាស្ដា 10:15**

គ្រីស្ទាន៖ យើងទាំងបានឮនិងជឿថាមានទីកន្លែងបែបដូច្នោះមែន។

គ្មានព្រះ៖ តើខ្ញុំមិនបានជឿកាលខ្ញុំនៅផ្ទះ ហើយបានមកឆ្ងាយបែបនេះដើម្បីស្វែងរកទេឬអី តែរកមិនឃើញអ្វីសោះ (ហើយខ្ញុំគួរតែបានរកឃើញកន្លែងនោះរួចទៅហើយ ដោយសារខ្ញុំបានចេញមកស្វែងរកវាឆ្ងាយជាងអ្នក) ខ្ញុំត្រឡប់ទៅក្រោយវិញហើយ ហើយខ្ញុំនឹងរកការដែលធ្វើឱ្យខ្ញុំស្រស់ស្រាយឡើងវិញ គឺការទាំងឡាយដែលខ្ញុំបានបោះបង់ចោលដោយសារសង្ឃឹមថានឹងបានឃើញអ្វីដែលខ្ញុំរកមិនឃើញនេះ។

គ្រីស្ទាន៖ បន្ទាប់មកគ្រីស្ទាននិយាយទៅកាន់សង្ឃឹមជាគ្នាគាត់ថា "តើអ្វីដែលអ្នកនេះនិយាយពិតដែរទេ?"

សង្ឃឹម៖ "សូមប្រយ័ត្ន គាត់ជាម្នាក់ក្នុងចំណោមមនុស្សបញ្ឆោត ចូរចាំពីអ្វីដែលបានកើតឡើងដល់យើងដោយសារបានស្តាប់តាមមនុស្សបែបនេះ។ អ្វីទៅ! មិនមានភ្នំស៊ីយ៉ូន! តើយើងមិនបានសម្លឹងឃើញពីភ្នំនៃសេចក្តីសម្រាកឃើញឃ្លោងទ្វារទីក្រុងនោះទេឬអី? ហើយថាតើយើងមិនត្រូវដើរដោយសេចក្តីជំនឿទេឬអីពេលនេះ? ចូរយើងបន្តដំណើរទៀត" សង្ឃឹមនិយាយ "មិនដូច្នោះទេបុរសដែលមានរំពាត់ខ្សែរតីនឹងមកទាន់យើងម្តងទៀត។ អ្នកគួរតែបានបង្រៀនខ្ញុំនូវមេរៀននោះ ដែលខ្ញុំនឹងព័ទ្ធវាជុំវិញត្រចៀករបស់អ្នកថា កូនអញអើយ ចូរចាកចេញទៅកុំស្តាប់តាមការណែនាំដែលធ្វើឱ្យអ្នកធ្វើខុសឡើយចេញពីពាក្យនៃចំណេះដឹង។ ខ្ញុំនិយាយថាបងអើយ កុំព្រមស្តាប់តាមគាត់អី ហើយចូរយើងជឿដល់ការសង្គ្រោះព្រលឹងវិញ។"

**"កូនអើយ ចូរលែងស្តាប់តាមដំបូន្មាន ដែលនាំឱ្យវង្វេងពីផ្លូវនៃដំរិះចេញ។" សុភាសិត 19:27**

**"តែយើងរាល់គ្នាមិនមែនជា ពួកអ្នកដែលថយទៅវិញ ឱ្យត្រូវវិនាសនោះឡើយ គឺជាពួកអ្នកដែលមានសេចក្តីជំនឿ សម្រាប់ឱ្យព្រលឹងបានសង្គ្រោះវិញ។" ហេព្រើរ 10:39**

គ្រីស្ទាន៖ បងប្អូនខ្ញុំអើយ ខ្ញុំមិនបានសួរអ្នកទេ ដោយសារតែខ្ញុំសង្ស័យពីសេ

ចក្តីពិតចេញពីសេចក្តីជំនឿរបស់យើងដោយខ្លួនខ្ញុំទេ។ តែដើម្បីនឹងអះអាងអ្នក ហើយដើម្បីនឹងទាញបានផលផ្លែចេញពីអ្នកនូវភាពស្មោះត្រង់ចេញពីចិត្តរបស់អ្នកវិញ។ សម្រាប់បុរសម្នាក់នេះវិញ ខ្ញុំដឹងថាគាត់ត្រូវបានព្រះនៃលោកិយនេះធ្វើឱ្យខ្វាក់ភ្នែកហើយ។ ចូរអ្នកនិងខ្ញុំបន្តទៅមុខទៀត ដោយដឹងថាយើងមានជំនឿលើសេចក្តីពិត ហើយ "មិនការកុហកនៅក្នុងសេចក្តីពិតទេ។"

**"ខ្ញុំសរសេរផ្ញើមកមិនមែនដោយព្រោះអ្នករាល់គ្នា មិនស្គាល់សេចក្តីពិតទេ គឺដោយព្រោះបានស្គាល់ ហើយក៏ដឹងថា គ្មានសេចក្តីភូតភរណាកើតពីសេចក្តីពិតនោះឡើយ។" យ៉ូហានទី១ 2:21**

សង្ឃឹម៖ ពេលនេះខ្ញុំពិតជាមានអំណរនៅក្នុងសង្ឃឹមនៃសិរីល្អរបស់ព្រះមែន!

ដូច្នេះពួកគេបានបែរចេញពីបុរសម្នាក់នោះ ហើយគាត់បានសើចដាក់ពួកគេរួចទៅតាមផ្លូវរបស់គាត់ទៅ។

ទឹកដីវេទមន្ត

ខ្ញុំបានឃើញនៅក្នុងសុបិនរបស់ខ្ញុំថា ពួកគេបានទៅរហូតដល់ប្រទេសមួយដែលខ្យល់នៅទីនោះអាចធ្វើឱ្យមនុស្សទៅជាងោកងុយបាន ប្រសិនបើមានមនុស្សប្លែកណាមកទីនោះ។ ហើយនៅទីនេះ ពេញដោយសង្ឃឹមបានក្លាយទៅជាកម្រើមិនសូវបានហើយងងុយដេកយ៉ាងខ្លាំង។ ដូច្នេះគាត់បា

ននិយាយទៅកាន់គ្រីស្ទានថា "ខ្ញុំចាប់ផ្ដើមងោកងុយយ៉ាងខ្លាំង ដែលខ្ញុំពិបាកនឹងទប់ភ្នែករបស់ខ្ញុំណាស់ ចូរយើងផ្ដេកខ្លួនទៅទីនេះ ហើយដេកមួយគ្រាប់ទៅ។"

គ្រីស្ទាន៖ "មិនអាចទេ" ម្នាក់ទៀតក៏បាននិយាយថា "ក្រែងថាដេកហើយយើងនឹងមិនភ្ញាក់ឡើងម្ដងទៀត។"

សង្ឃឹម៖ ហេតុអ្វីទៅបង ការដេកជាការល្អសម្រាប់មនុស្សដែលធ្វើការអស់កម្លាំង។ យើងនឹងបានស្រស់បស់ឡើងប្រសិនបើយើងបានដេកបន្ដិចនោះ។

គ្រីស្ទាន៖ តើអ្នកមិនបានចងចាំថា មានអ្នកគង្វាលម្នាក់បានប្រាប់យើងឱ្យប្រយ័ត្ននឹងទឹកដីមានវេទមន្តទេឬអី? គាត់មានន័យថា យើងត្រូវតែប្រុងប្រយ័ត្ននឹងការដេកលក់។ ដូច្នេះចូរយើងកុំដេកដូចអ្នកផ្សេងអី តែចូរយើងប្រុងប្រយ័ត្ននិងភ្ញាក់ជានិច្ចវិញ។

**"ដូច្នេះត្រូវឱ្យយើងចាំយាម ហើយដឹងខ្លួន មិនត្រូវឱ្យដេកលក់ដូចជាមនុស្សឯទៀតទេ។" ថែស្សាឡូនិចទី១ 5:6**

សង្ឃឹម៖ ខ្ញុំទទួលស្គាល់ថាខ្ញុំជាអ្នកខុសហើយ។ ហើយបើខ្ញុំនៅទីនេះតែម្នាក់ឯង ដោយការដេកលក់នោះខ្ញុំនឹងធ្វើឱ្យខ្លួនមានគ្រោះថ្នាក់ស្លាប់តែម្នាក់ឯងមិនខាន។

**"មានគ្នាពីរនាក់នោះវិសេសជាងនៅតែឯង ពីព្រោះគេមានរង្វាន់យ៉ាងល្អ កើតពីការនឿយហត់របស់ខ្លួន។" សាស្តា 4:9**

មានអ្នកជាគ្នានៅទីនេះជាសេចក្ដីមេត្តាដល់ខ្ញុំហើយ ហើយអ្នកនឹងទទួលបានរង្វាន់ដ៏ល្អមួយដោយសារការខិតខំរបស់អ្នក។

គ្រីស្ទានៈ "ពេលនេះ" បន្ទាប់មកគ្រីស្ទានបាននិយាយថា "ដើម្បីគេចផុតពីភាពងោកងុយនៅទីនេះ ចូរយើងចាប់ផ្ដើមជជែកគ្នាវិញ។"

សង្ឃឹមៈ "អស់ពីចិត្តរបស់ខ្ញុំ" ម្នាក់ទៀតនិយាយ

គ្រីស្ទានៈ តើយើងគួរតែចាប់ផ្ដើមពីត្រង់ណា?

សង្ឃឹមៈ ពីកន្លែងដែលព្រះបានចាប់ផ្ដើមជាមួយយើង។ តែអ្នកចង់ចាប់ផ្ដើមទេ ប្រសិនបើអ្នកចង់នោះ។

គ្រីស្ទានៈ ខ្ញុំនឹងច្រៀងចម្រៀងនេះដល់អ្នកជាមុនសិន។

"នៅពេលដែលពួកបរិសុទ្ធចាប់ផ្ដើមងងុយដេក ចូរឱ្យពួកគេមកទីនេះ ហើយមកស្ដាប់អ្នកធ្វើធម្មយាត្រាពីរនាក់នេះជជែកគ្នាចុះ។ ពិតណាស់ ចូរមករៀនពីពួកគេចុះ ឱ្យបានមានប្រាជ្ញាឡើយ ដើម្បីនឹងការពារពីភាពងោកងុយ ភ្នែកងោកងុយ។ ការប្រកបរបស់ពួកបរិសុទ្ធ ប្រសិនបើរៀបចំបានល្អវិញ ក៏នឹងធ្វើឱ្យពួកគេភ្ញាក់ឡើង ជំនួសឱ្យស្ថាននរក។"

គ្រីស្ទាន៖ បន្ទាប់មកគ្រីស្ទានចាប់ផ្តើមនិយាយថា "ខ្ញុំនឹងសួរសំណួរមួយដល់អ្នក។ ហេតុអ្វីបានជាអ្នកគិតពីដំបូងថានឹងធ្វើការដែលអ្នកកំពុងធ្វើនេះ?"

សង្ឃឹម៖ តើអ្នកមានន័យថា ខ្ញុំអាចមើលឃើញពីសេចក្តីល្អខាងព្រលឹងរបស់ខ្ញុំពីដំបូងមកបានដោយរបៀបណាមែនទេ?

គ្រីស្ទាន៖ បាទ ន័យបែបហ្នឹងហើយ។

សង្ឃឹម៖ ខ្ញុំបានបន្តរីករាយមួយរយៈធំនឹងការទាំងនោះដែលបានឃើញនិងលក់នៅជំនួញរបស់យើងនោះ។ ជាការខ្ញុំពេលនេះខ្ញុំជឿថា (ប្រសិនបើខ្ញុំនៅតែបន្តធ្វើវាទៀត) នឹងបានធ្វើឱ្យខ្ញុំលិចលង់នៅក្នុងស្ថាននរក និងសេចក្តីវិនាសអន្តរាយហើយ។

គ្រីស្ទាន៖ តើការទាំងនោះជាអ្វីខ្លះ?

សង្ឃឹម៖ គ្រប់ទាំងទ្រព្យសម្បត្តិនិងភាពសម្បូរសប្បាយនៃលោកិយនេះ។ ខ្ញុំក៏បានរីករាយយ៉ាងខ្លាំងនឹងការបង្ការការរឹករវ ការបេះបោរ ការផឹក ការស្បថ ការកុហក ភាពស្មោគគ្រោក ការបំពានលើថ្ងៃសប្ប័ថ ហើយអ្វីផ្សេងទៀតដែលរកតែបំផ្លាញព្រលឹង។ តែចុងក្រោយខ្ញុំរកឃើញថា ដោយបានស្តាប់និងពិចារណាពីការដែលមកពីព្រះវិញ ដែលតាមការពិតទៅខ្ញុំបានឮពីអ្នក ក៏ដូចជាឮពីលោកស្មោះត្រង់ជាទីស្រឡាញ់ ដែលគាត់ត្រូវបានសម្លាប់ដោយសារសេចក្តីជំនឿរបស់គាត់និងការរស់នៅល្អនៅត្រង់ជំនួញដែលឥតប្រយោជន៍នោះ ដែលចុងក្រោយនៃការទាំងនោះជាសេចក្តីស្លាប់ ហើយ

ដោយសារទាំងនោះបានធ្វើឱ្យសេចក្តីក្រោធរបស់ព្រះធ្លាក់មកលើកូនចៅនៃការមិនស្តាប់បង្គាប់។

**"កាលនោះតើអ្នករាល់គ្នាបានផលអ្វីខ្លះក្នុងអំពើដែលឥលូវអ្នករាល់គ្នាអៀមខ្មាសវិញ ដ្បិតទីបំផុតនៃអំពើទាំងនោះជាសេចក្តីស្លាប់។ តែឥលូវនេះ ដែលព្រះបានប្រោសឱ្យរួចពីបាប ហើយអ្នករាល់គ្នាបានត្រឡប់ជាបាវបម្រើដល់ទ្រង់ នោះអ្នករាល់គ្នាបានផលខាងឯសេចក្តីបរិសុទ្ធវិញ ហើយទីបំផុតនៃអំពើទាំងនោះ គឺជាជីវិតអស់កល្បជានិច្ចផង។ ដ្បិតឈ្នួលរបស់អំពើបាប នោះជាសេចក្តីស្លាប់ តែអំណោយទាននៃព្រះវិញ គឺជាជីវិតដ៏នៅអស់កល្បជានិច្ច ដោយព្រះគ្រីស្ទយេស៊ូវជាព្រះអម្ចាស់នៃយើងរាល់គ្នា។" រ៉ូម 6:21-23**

**"កុំឱ្យអ្នកណាបញ្ឆោតអ្នករាល់គ្នា ដោយពាក្យសម្តីឥតប្រយោជន៍ឡើយ ដ្បិតគឺដោយព្រោះសេចក្តីទាំងនោះ បានជាសេចក្តីក្រោធរបស់ព្រះបានមកលើមនុស្សរឹងចចេស។" អេភេសូ 5:6**

គ្រីស្ទាន៖ ហើយតើអ្នកពេលនេះបានធ្លាក់ចុះនៅក្រោមអំណាចនៃជំនឿនេះទៀតដែរទេ?

សង្ឃឹម៖ ទេ។ ខ្ញុំមិនមានបំណងចង់ដឹងសេចក្តីទុច្ចរិតនៃអំពើបាបឡើយពេលនេះ ឬការដាក់ទោសដែលនឹងមកតាមក្រោយបន្ទាប់ពីបានប្រព្រឹត្តវានោះឡើយ ដំបូងពេលដែលគំនិតរបស់ខ្ញុំចាប់ផ្តើមរង្គើរដោយសារពាក្យនោះដើម្បីបិទភ្នែករបស់ខ្ញុំទាស់នឹងពន្លឺនោះ។

គ្រីស្ទាន៖ តែអ្វីទៅជាហេតុដែលអ្នកនាំវាមករហូតដល់កិច្ចការដំបូងរបស់ព្រះវិញ្ញាណដែលពេញដោយព្រះពររបស់ព្រះមកលើអ្នកនោះ?

សង្ឃឹម៖ ហេតុផលនោះគឺ 1. ខ្ញុំមិនដឹងថានេះជាកិច្ចការរបស់ព្រះនៅនឹងខ្ញុំ។ ខ្ញុំមិនដែលគិតថា ដោយការភ្ញាក់ដឹងខ្លួនដោយអំពើបាប ថាពីដំបូងព្រះបានចាប់ផ្ដើមនៃការប្រែចិត្តនោះទេ។ 2. អំពើបាបនៅតែផ្អែមខ្លាំងដល់ខាងរូបកាយរបស់ខ្ញុំ។ វត្តមានរបស់បាបនិងកិច្ចការទាំងនោះជាសេចក្ដីប្រាថ្នាមកដល់ខ្ញុំ។ 3. ខ្ញុំមិនប្រាប់បានពីរបៀបបែងចែងចេញពីក្រុមចាស់ៗរបស់ខ្ញុំបានវត្តមាននិងទង្វើរបស់ពួកគេជាសេចក្ដីប្រាថ្នារបស់ខ្ញុំ។ 4. ម៉ោងដែលការប្រែចិត្តមកដល់ខ្ញុំជាពេលពេញដោយបញ្ហាបំផុត ហើយដែលធ្វើឱ្យចិត្តភ័យញ័រយ៉ាងខ្លាំង ដែលខ្ញុំមិនអាចទ្រាំទ្របាន ទេ តែខ្ញុំមិនសូវជាចាំការទាំងនោះនៅក្នុងចិត្តខ្ញុំប៉ុន្មានទេ។

គ្រីស្ទាន៖ អីចឹង មើលទៅ ជួនកាលអ្នកដកបញ្ហារបស់អ្នកចេញបាន។

សង្ឃឹម៖ បាទ ពិតមែន។ តែវានៅតែមកកាន់គំនិតរបស់ខ្ញុំម្ដងទៀត ហើយបន្ទាប់មកខ្ញុំនៅតែអាក្រក់ដដែល កាន់តែអាក្រក់ថែមជាមុនទៀតផង។

គ្រីស្ទាន៖ ហេតុអ្វីទៅ? តើអ្វីដែលនាំអំពើបាបមកកាន់គំនិតរបស់អ្នកម្ដងទៀតនោះ?

សង្ឃឹម៖ មានការជាច្រើនដូចជា

1.ប្រសិនបើខ្ញុំបានជួបនឹងមនុស្សល្អណាម្នាក់នៅតាមផ្លូវ ឬ

2. ប្រសិនបើខ្ញុំបានឮនរណាម្នាក់អានព្រះគម្ពីរ ឬ

3. ប្រសិនបើក្បាលរបស់ខ្ញុំចាប់ផ្តើមឈឺ ឬ
4. ប្រសិនបើមានគេប្រាប់ខ្ញុំថា អ្នកជិតខាងខ្លះឈឺ ឬ
5. ប្រសិនបើខ្ញុំបានឮសម្លេងកន្តឹងដែលថាអ្នកខ្លះត្រូវស្លាប់ ឬ
6. ប្រសិនបើខ្ញុំបានគិតពីការស្លាប់របស់ខ្ញុំ ឬ
7. ប្រសិនបើខ្ញុំបានឮថា សេចក្តីស្លាប់តន់ហាន់បានកើតឡើងដលអ្នកដទៃទៀត។
8. តែជាពិសេសនោះ នៅពេលដែលខ្ញុំបានគិតពីខ្លួនខ្ញុំថា ខ្ញុំនឹងត្រូវទទួលការជំនុំជំរះភ្លាមៗនោះ។

គ្រីស្ទាន៖ ហើយតើមានពេលណាដែលអ្នកអាចដោះបាបចេញដោយស្រួលទេ នៅពេលដែលផ្លូវណាមួយទាំងនេះបានមកដល់អ្នកនោះ?

សង្ឃឹម៖ ទេ មិនយូរប៉ុន្មានទេ ដោយសារបន្ទាប់មក ការទាំងនោះបានកាន់ជាប់នៅក្នុងសតិរបស់ខ្ញុំ។ ហើយបន្ទាប់មក ប្រសិនបើខ្ញុំបានគិតថាត្រឡប់ទៅអំពើបាបវិញ (បើទោះជាគំនិតរបស់ខ្ញុំត្រូវបែរទាស់នឹងវាក៏ដោយ) វានឹងធ្វើទុក្ខបុកម្នេញដល់ខ្ញុំទ្វេរដង។

គ្រីស្ទាន៖ ហើយតើអ្នកធ្វើរបៀបម៉េចទៅ?

សង្ឃឹម៖ ខ្ញុំបានគិតថាខ្ញុំត្រូវតែខិតខំពត់ជីវិតរបស់ខ្ញុំ មិនដូច្នោះទេ ខ្ញុំគិតថាខ្ញុំនឹងត្រូវវិនាសមិនខាន។

គ្រីស្ទាន៖ ហើយតើអ្នកបានខិតខំពត់ដែរទេ?

សង្ឃឹម៖ បាទបាន ហើយបានរត់គេចពីវា មិនត្រឹមតែបានរបស់ខ្ញុំប៉ុណ្ណោះ តែពីពួកដែលធ្វើបាបដែរ។ ហើយបាននាំខ្ញុំទៅតួនាទីខាងសាសនាវិញដូចជា ការអធិស្ឋាន ការអាន ការយំសោកដោយអំពើបាប ការនិយាយសេចក្ដីពិតទៅកាន់អ្នកជិតខាង និងការផ្សេងទៀត។ ការដែលខ្ញុំបានធ្វើទាំងនេះមានទំនាក់ទំនងនឹងការជាច្រើននៅទីនេះណាស់។
គ្រីស្ទាន៖ ហើយតើអ្នកបានគិតត្រឹមត្រូវដោយខ្លួនឯងដែរទេ?

សង្ឃឹម៖ បាទ បានមួយរយៈដែរ តែចុងក្រោយបញ្ហារបស់ខ្ញុំបានមកសង្កត់លើខ្ញុំម្ដងទៀត ហើយមកលើកនៃការផ្លាស់ប្រែរបស់ខ្ញុំ។

គ្រីស្ទាន៖ តើវាកើតឡើងម្ដេចទៅ កាលដែលអ្នកបានផ្លាស់ប្រែរួចហើយពេលនេះ?

សង្ឃឹម៖ មានការបីបួនដែលមកលើខ្ញុំនោះ ជាពិសេសការនិយាយដូចនេះ "គ្រប់ទាំងសេចក្ដីសុចរិតរបស់យើងដូចជាកន្ទបកខ្វក់អីចឹង។" "ដោយកិច្ចការខាងក្រឹត្យវិន័យគ្មានសាច់ឈាមណាត្រូវបានសុចរិតបានឡើយ។" "នៅពេលដែលអ្នកធ្វើគ្រប់ការទាំងអស់ស្រេចហើយ និយាយថា យើងគ្មានប្រយោជន៍អ្វីឡើយ។"

**"ដ្បិតយើងទាំងអស់គ្នាបានត្រឡប់ទៅដូចជាមនុស្ស ដែលមិនស្អាត ហើយអស់ទាំងអំពើសុចរិតរបស់យើងខ្ញុំ ក៏ដូចជាអាវកខ្វក់ហើយ យើងខ្ញុំរាល់គ្នាស្វិតក្រៀមទៅដូចជាស្លឹកឈើ ហើយអំពើទុច្ចរិតរបស់យើងខ្ញុំ ក៏ផាត់យកយើងទៅដូចជាខ្យល់។" អេសាយ 64:6**

**"យើងដឹងថា មនុស្សមិនបានរាប់ជាសុចរិត ដោយប្រព្រឹត្តតាមក្រិត្យវិន័យនោះឡើយ គឺដោយសេចក្តីជំនឿ ជឿដល់ព្រះយេស៊ូវគ្រីស្ទវិញ ហេតុនោះបានជាយើងជឿដល់ព្រះយេស៊ូវគ្រីស្ទ ដើម្បីឱ្យបានរាប់ជាសុចរិត ដោយសារសេចក្តីជំនឿដល់ព្រះគ្រីស្ទ នោះមិនមែនដោយការប្រព្រឹត្តតាមក្រិត្យវិន័យទេ ពីព្រោះគ្មានមនុស្សណាបានរាប់ជាសុចរិតដោយប្រព្រឹត្យតាមក្រិត្យវិន័យឡើយ។" កាឡាទី 2:16**

**"អ្នករាល់គ្នាក៏ដូច្នោះដែរ កាលណាអ្នករាល់គ្នា បានធ្វើតាមបង្គាប់គ្រប់ជំពូកហើយ នោះត្រូវរាប់ថា យើងជាបាវបម្រើឥតកម្រៃដល់ម្ចាស់ទេ ដ្បិតយើងបានធ្វើត្រឹមតែការដែលយើងត្រូវធ្វើប៉ុណ្ណោះ។" លូកា 17:10**

ជាមួយមនុស្សដូចនេះជាច្រើនទៀត។ ចាប់ពីពេលដែលខ្ញុំចាប់ផ្តើមរកហេតុផលជាមួយខ្លួនឯងនោះថា ប្រសិនបើសេចក្តីសុចរិតរបស់ខ្ញុំដូចជាកន្ទបកខ្វក់នោះ ប្រសិនបើតាមកិច្ចការខាងក្រឹត្យវិន័យគ្មានមនុស្សណាបានរាប់ជាសុចរិតនោះ ហើយប្រសិនបើបន្ទាប់ពីយើងបានធ្វើការគ្រប់សព្វហើយនោះយើងនៅតែមិនទទួលបានផលប្រយោជន៍អ្វីទៀត អីចឹងមានតែល្ងីល្ងើហើយដែលគិតពីស្ថានសួគ៌ដោយក្រឹត្យវិន័យនោះ។ ខ្ញុំបានគិតបន្ថែមទៀតដូចនេះថា ប្រសិនបើមនុស្សម្នាក់ជំពាក់ ១០០ដោនស៍ទៅក្នុងបំណុលរបស់អ្នកមើលថែហាងមួយ ហើយបន្ទាប់ពីគាត់បានបង់គ្រប់ចំនួនទាំងអស់រួចហើយ តែប្រសិនបើបំណុលចាស់របស់គាត់នៅតែមាននៅក្នុងបញ្ជីរមិនទាន់គូស

ចោលដដែល នោះអ្នកមើលហាងនឹងប្ដឹងគាត់ ហើយបោះគាត់ចូលទៅក្នុងគុករហូតដល់គាត់នឹងសងបំណុលរួច។

គ្រីស្ទាន៖ អ៊ីចឹង តើអ្នកយកការនេះមកដាក់លើខ្លួនអ្នកយ៉ាងមិចដែរ?

សង្ឃឹម៖ ខ្ញុំបានគិតមកខ្លួនខ្ញុំដូច្នេះ ខ្ញុំមានអំពើបាបដ៏ធំនៅក្នុងបញ្ជីររបស់ព្រះ ហើយថាពេលនេះការផ្លាស់ប្រែរបស់ខ្ញុំនឹងមិនអាចសងគ្រប់ពិន្ទុដែរ។ ដូច្នេះខ្ញុំគួរតែគិតដដែល នៅក្រោមការកែប្រែរបស់ខ្ញុំពេលនេះ តែតើខ្ញុំអាចមានសេរីភាពចេញពីការដាក់ទោសដែលខ្ញុំបានយកខ្លួនទៅដាក់នៅក្នុងគ្រោះថ្នាក់ដោយសារការបះបោរពីមុនរបស់ខ្ញុំដោយរបៀបណាទៅ?

គ្រីស្ទាន៖ ធ្វើការអនុវត្តមកជីវិតបានល្អ តែសូមនិយាយបន្តទៀតមក។

សង្ឃឹម៖ ការមួយទៀតដែលធ្វើឱ្យខ្ញុំលំបាកនោះគឺ ចាប់តាំងពីការកែប្រែពីមុនរបស់ខ្ញុំមក ប្រសិនបើខ្ញុំមើលទៅលើការល្អបំផុតនូវអ្វីដែលខ្ញុំធ្វើពេលនេះ ខ្ញុំនៅតែឃើញអំពើបាប ដែលលាយឡំខ្លួនរបស់វាជាមួយនឹងការល្អបំផុតដែលខ្ញុំធ្វើ។ ដូច្នេះពេលនេះខ្ញុំត្រូវបង្ខមខ្លួនឱ្យសរុបមកថា ក្រៅពីចំណងពីដើមរបស់ខ្ញុំការបញ្ឆោតខ្លួនរបស់ខ្ញុំ និងតួនាទី នោះខ្ញុំបានធ្វើបាបមួយថ្ងៃគ្រប់គាត់នឹងបញ្ជូនខ្ញុំទៅស្ថាននរកហើយ បើទោះជាជីវិតពីដើមរបស់ខ្ញុំមិនមានកំហុសក៏ដោយ។

គ្រីស្ទាន៖ ហើយតើអ្នកធ្វើអ្វីទៅ?

សង្ឃឹម៖ ធ្វើ! ខ្ញុំមិនអាចប្រាប់បានថានឹងធ្វើអ្វីទេ រហូតដល់ខ្ញុំបានគំនិតរបស់ខ្ញុំបានគិតដល់ស្មោះត្រង់។ ដោយសារគាត់និងខ្ញុំជាអ្នកស្គាល់គ្នាច្បាស់ ហើយគាត់បានប្រាប់ខ្ញុំថា "ថាទាល់តែខ្ញុំអាចធ្វើបាននូវសេចក្ដីសុចរិតរបស់មនុស្សដែលមិនដែលធ្វើបាបសោះ នោះសេចក្ដីសុចរិតរបស់ខ្ញុំឬសេចក្ដីសុចរិតណានៅលើលោកដែលអាចសង្គ្រោះខ្ញុំបានឡើយ។"

គ្រីស្ទាន៖ តើអ្នកគិតថាអ្វីដែលគាត់និយាយត្រូវទេ?

សង្ឃឹម៖ បើគាត់បានប្រាប់ខ្ញុំដូច្នេះ នៅពេលដែលខ្ញុំពេញចិត្តនិងស្កប់ស្កល់ជាមួយនឹងការផ្លាស់ប្រែរបស់ខ្ញុំ នោះខ្ញុំបានហៅគាត់ថាជាមនុស្សល្ងង់ដោយសារតែការឈឺចាប់របស់គាត់។ តែពេលនេះ ក្នុងកាលដែលខ្ញុំបានឃើញនូវជំងឺរបស់ខ្ញុំ និងអំពើបាបដែលជ្រែកចូលនៅក្នុងការប្រព្រឹត្តដ៏ល្អបំផុតរបស់ខ្ញុំ ខ្ញុំត្រូវបានបង្ខំឱ្យគិតដូចជាគំនិតរបស់គាត់ដែរ។

គ្រីស្ទាន៖ តែតើអ្នកគិតថា ពីដំបូងដែលគាត់ប្រាប់ការនោះដល់អ្នក ថាមានមនុស្សណាដែលនឹងរកឃើញថាគាត់ជាមនុស្សដែលគេនិយាយថាសុចរិតដែលគាត់មិនដែលធ្វើបាបសោះដែរទេ?

សង្ឃឹម៖ ខ្ញុំត្រូវសារភាពថាពាក្យនោះស្ដាប់ទៅដូចជាចម្លែកពីដំបូងឡើយ តែបន្ទាប់ពីនិយាយគ្នាបន្តិតមកហើយបានដើរជាមួយគាត់ ខ្ញុំក៏បានជឿលើការនោះដែរ។

គ្រីស្ទាន៖ ហើយតើអ្នកបានសួរថាបុរសនោះជានរណា ហើយតើអ្នកអាចរាប់ជាសុចរិតដោយសារគាត់បានដោយរបៀបណាទៅ?

សង្ឃឹមៈ បាទបាន។ គាត់បានប្រាប់ខ្ញុំថា នោះគឺព្រះអម្ចាស់ព្រះយេស៊ូវ ដែលទ្រង់គង់នៅខាងស្តាំដៃរបស់ព្រះដ៏ខ្ពស់បំផុត។

"" ហេព្រើរ 10:11-18

""បើដូច្នេះ យើងនឹងថា លោកអ័ប្រាហាំ ជាអយ្យកោយើង បានអ្វីខ្លះ ខាងឯសាច់ឈាម។ ដ្បិតបើសិនណាជាលោកអ័ប្រាហាំបានរាប់ជាសុចរិត ដោយការដែលលោកប្រព្រឹត្ត នោះលោកមានកន្លែងនឹងអួតខ្លួនហើយ តែមិនមែនចំពោះព្រះទេ។ តើគម្ពីរថាដូចម្តេច គម្ពីរថា "អ័ប្រាហាំបានជឿដល់ព្រះ ហើយសេចក្តីជំនឿនោះ បានរាប់ជាសេចក្តីសុចរិតដល់លោក"។ រីឯអ្នកណាដែលធ្វើការ នោះរង្វាន់មិនរាប់ជាគុណរបស់ថៅហ្វាយទេ គឺទុកជាថ្លៃឈ្នួលវិញទេតើ។ តែចំណែកអ្នកដែលមិនធ្វើការសោះ គឺគ្រាន់តែជឿដល់ព្រះអង្គ ដែលទ្រង់ប្រោសឱ្យមនុស្សទមិឡល្មើសបានសុចរិត នោះសេចក្តីជំនឿរបស់អ្នកនោះ បានរាប់ទុកជាសេចក្តីសុចរិតវិញ។ ដូចជាហ្លួងដាវីឌបានសម្តែងពីសណ្ឋានដ៏មានពរនៃមនុស្ស ដែលព្រះទ្រង់រាប់ជាសុចរិតក្រៅពីការប្រព្រឹត្តថា "មានពរហើយ អ្នកណាដែលការទទឹងច្បាប់របស់ខ្លួនបានអត់ទោសឱ្យ និងបាបខ្លួនបានគ្របបាំង"។ មានពរហើយ មនុស្សណាដែលព្រះអម្ចាស់មិនរាប់ជាមានបាបឡើយ។ដូច្នេះ តើបានពរនោះ ចំពោះតែពួកកាត់ស្បែកតែប៉ុណ្ណោះ ឬពួកមិនកាត់ស្បែកក៏បានដែរ ដ្បិតយើងថាសេចក្តីជំនឿ បានរាប់ទុកជាសេចក្តីសុចរិត ដល់លោកអ័ប្រាហាំ។ ចុះសេចក្តីនោះបានរាប់ដូចម្តេច តើពីកាលលោកបានកាត់ស្បែករួចហើយ ឬនៅឡើយ មិនមែនពីកាលលោកបានកាត់ស្បែកហើយនោះទេ គឺក្នុងកាលដែលមិនទាន់កាត់ស្បែកនៅឡើយវិញ។ ហើយលោកបានទទួលពិធីកាត់ស្បែកនេះ ទុកជាទីសម្គាល់ ជាត្រានៃសេចក្តី

សុចរិត ដែលមកដោយសេចក្ដីជំនឿនោះឯង គឺជាសេចក្ដីជំនឿដែលលោក មានពីកាលមិនទាន់កាត់ស្បែកនៅឡើយ ដើម្បីឱ្យបានធ្វើជាឪពុក ដល់អស់អ្នកដែលជឿ ឥតកាត់ស្បែកផង ប្រយោជន៍ឱ្យបានរាប់សេចក្ដីសុចរិតនេះដល់អ្នកទាំងនោះ។ ហើយឱ្យបានធ្វើជាឪពុក ដល់ពួកដែលមិនគ្រាន់តែកាត់ស្បែកប៉ុណ្ណោះ គឺដែលដើរតាមដាននៃសេចក្ដីជំនឿរបស់លោកអ័ប្រាហាំ ជាអយ្យកោយើងផង ជាសេចក្ដីជំនឿដែលលោកមាន ពីកាលមិនទាន់កាត់ស្បែកនៅឡើយ។ ដ្បិតសេចក្ដីសន្យាដល់លោកអ័ប្រាហាំ និងពូជលោក ឱ្យបានលោកីយ៍ជាមរដក នោះមិនមែនដោយសារក្រឹត្យវិន័យទេ គឺដោយសារសេចក្ដីសុចរិតដែលមកដោយសេចក្ដីជំនឿវិញ។ ពីព្រោះបើសិនជាពួកអ្នកដែលអាងក្រឹត្យវិន័យបានគ្រងមរដក នោះសេចក្ដីជំនឿបានទៅជាឥតអំពើវិញ ហើយសេចក្ដីសន្យាក៏ឥតប្រយោជន៍ដែរ។ ឯក្រឹត្យវិន័យ នោះបង្កើតសេចក្ដីក្រោធ ដ្បិតកន្លែងណាដែលគ្មានក្រឹត្យវិន័យ នោះក៏ឥតមានសេចក្ដីរំលងដែរ។ ដូច្នេះ សេចក្ដីសន្យាបានមកដោយសេចក្ដីជំនឿ ដើម្បីឱ្យបានត្រូវខាងព្រះគុណ ប្រយោជន៍ឱ្យសេចក្ដីសន្យាបានខ្ជាប់ខ្ជួន ដល់ពូជលោកតទៅ មិនមែនត្រឹមតែពូជដែលអាងក្រឹត្យវិន័យប៉ុណ្ណោះ គឺដល់ទាំងពូជដែលអាងសេចក្ដីជំនឿរបស់លោកអ័ប្រាហាំ ដែលជាអយ្យកោនៃយើងទាំងអស់គ្នាថែមទៀតផង។ ដូចមានសេចក្ដីចែងទុកមកថា អញបានតាំងឯងឱ្យធ្វើជាឪពុកដល់សាសន៍ជាច្រើន រីឯនៅចំពោះព្រះ ជាទីជឿរបស់លោក ដែលទ្រង់ប្រោសមនុស្សស្លាប់ឱ្យរស់ឡើងវិញ ទាំងមានព្រះបន្ទូលពីរបស់ដែលគ្មាន ទុកដូចជាមានហើយ នោះលោកជាឪពុករបស់យើងមែន។ ដ្បិតកាលលោកអស់ទីសង្ឃឹមហើយ នោះក៏ចេះតែជឿដោយសង្ឃឹមវិញ ដើម្បីឱ្យបានត្រឡប់ជាឪពុកដល់សាសន៍ជាច្រើន ដូចសេចក្ដីដែលមានព្រះបន្ទូលទុកមកថា «ពូជ

ឯងនឹងបានដូច្នោះ។ ហើយដោយព្រោះលោកមិនខ្សោយខាងសេចក្តីជំនឿ បានជាលោកមិនគិតពីរូបកាយលោក ដែលរាប់ដូចជាស្លាប់ ដោយមានអាយុប្រហែលជា១០០ឆ្នាំហើយ ឬពីផ្ទៃសារ៉ា ដែលរាប់ដូចជាស្លាប់ដែរនោះទេ។ លោកក៏មិនបានសង្ស័យចំពោះសេចក្តីសន្យារបស់ព្រះ ដោយចិត្តមិនជឿឡើយ គឺរឹតតែមានសេចក្តីជំនឿខ្លាំងឡើង ទាំងសរសើរតម្កើងដល់ព្រះវិញ។ ហើយក៏ជឿជាក់អស់ពីចិត្តថា សេចក្តីអ្វីដែលទ្រង់សន្យា នោះអាចនឹងធ្វើឱ្យសម្រេចបាន។ ហេតុនោះបានជារាប់សេចក្តីជំនឿរបស់លោក ទុកជាសេចក្តីសុចរិតដល់លោក។ ប៉ុន្តែ ដែលថា បានរាប់ដល់លោក។ ដូច្នេះ នោះមិនចែងទុកមកសម្រាប់លោកតែឯងទេ"

"រ៉ូម 4:1-23

"ហេតុនោះ ចាប់តាំងពីថ្ងៃ ដែលយើងខ្ញុំឮនិយាយ នោះយើងខ្ញុំក៏អធិស្ឋានឱ្យអ្នករាល់គ្នាឥតឈប់ឈរ ហើយទូលសូម ឱ្យអ្នករាល់គ្នាបានស្គាល់ព្រះហឫទ័យទ្រង់សព្វគ្រប់ ដោយគ្រប់ទាំងប្រាជ្ញា និងចំណេះខាងវិញ្ញាណ។ ដើម្បីឱ្យបានដើរបែបគួរនឹងព្រះអម្ចាស់ ទាំងគាប់ចិត្តដល់មនុស្សទាំងអស់ ឱ្យបានបង្កើតផលក្នុងគ្រប់ទាំងការល្អ ហើយឱ្យស្គាល់ព្រះកាន់តែច្បាស់ឡើង។ ដោយបានគ្រប់ទាំងព្រះចេស្តាចម្រើនកម្លាំង តាមឫទ្ធិបារមីដ៏ឧត្តមរបស់ទ្រង់ ដើម្បីឱ្យបានចេះទ្រាំទ្រ ហើយអត់ធន់គ្រប់យ៉ាងដោយអំណរ។ ព្រមទាំងអរព្រះគុណ ដល់ព្រះវរបិតាដែលទ្រង់បានប្រោស ឱ្យយើងបានគួរនឹងទទួលចំណែកកេរអាករ ក្នុងពួកបរិសុទ្ធនៅទីភ្លឺផង។ ទ្រង់បានប្រោសឱ្យយើងរួចពីអំណាចនៃសេចក្តីងងឹត ហើយផ្លាស់យើងមកក្នុងនគររបស់ព្រះរាជបុត្រាស្ងួនភ្ងានៃទ្រង់។ យើងរាល់គ្នាមានសេចក្តីប្រោសលោះក្នុងព្រះរាជ

បុត្រានោះ គឺជាសេចក្តីផ្តាច់បាប ដោយសារព្រះលោហិតទ្រង់។ ដែលទ្រង់ជារូបអង្គ នៃព្រះដ៏មើលមិនឃើញ ជាបងច្បងនៃគ្រប់ទាំងអស់ ដែលព្រះបានបង្កើតមក។ ដ្បិតគឺទ្រង់ហើយ ដែលបង្កើតគ្រប់ទាំងអស់ ទាំងរបស់នៅស្ថានសួគ៌ និងនៅផែនដី ទាំងរបស់ដែលមើលឃើញ ហើយដែលមើលមិនឃើញផង ទោះបើជារាជ្យ ឬអំណាចជាព្រះអម្ចាស់ ឬអំណាចគ្រប់គ្រង ឬអំណាចណាក៏ដោយ នោះសុទ្ធតែកើតមកដោយសារទ្រង់ ហើយសម្រាប់ទ្រង់ទាំងអស់ផង។ ទ្រង់គង់នៅមុនទាំងអស់ ហើយរបស់ទាំងអស់ក៏ស្ថិតស្ថេរ ដោយសារទ្រង។ ទ្រង់ជាសិរសារបស់រូបកាយ គឺជាពួកជំនុំ ទ្រង់ជាដើម ក៏បានរស់ពីស្លាប់ឡើងវិញមុនគេបង្អស់ ដើម្បីឱ្យទ្រង់បានជាប្រធានក្នុងគ្រប់ទាំងអស់។ ដ្បិតព្រះបានសព្វព្រះហឫទ័យ ឱ្យគ្រប់ទាំងសេចក្តីពោរពេញបានស្ថិតនៅក្នុងទ្រង់។ ហើយឱ្យបានផ្សះផ្សាគ្រប់ទាំងអស់ ឱ្យជានឹងអង្គទ្រង់ ដោយសារព្រះរាជបុត្រានោះ ទោះបើរបស់នៅស្ថានសួគ៌ ឬនៅផែនដីក្តី ទាំងតាំងស្ពានមេត្រី ដោយសារព្រះលោហិតនៃឈើឆ្កាងទ្រង់។ រីឯអ្នករាល់គ្នា ដែលពីដើមត្រូវពង្រាត់ចេញ ហើយជាខ្មាំងសត្រូវក្នុងគំនិត ដោយអំពើអាក្រក់នោះ។ ឥឡូវនេះវិញ ទ្រង់បានផ្សះផ្សាក្នុងរូបសាច់ទ្រង់ ដោយបានទទួលសុគត ដើម្បីនឹងថ្វាយអ្នករាល់គ្នាជាតង្វាយបរិសុទ្ធ ឥតសៅហ្មង ហើយឥតកន្លែងបន្ទោសបាន នៅចំពោះទ្រង់។ នោះគឺបើតិចណាស់ អ្នករាល់គ្នាបានតាំងនៅជាប់លាប់ ហើយមាំមួន ក្នុងសេចក្តីជំនឿដែរ ឥតងាកបែរចេញពីសេចក្តីសង្ឃឹមរបស់ដំណឹងល្អ ដែលអ្នករាល់គ្នាបានឮ ជាដំណឹងដែលបានផ្សាយ ទៅដល់គ្រប់ទាំងមនុស្ស ដែលកើតក្រោមមេឃផង ឯប៉ុលខ្ញុំ ជាអ្នកបម្រើចំពោះដំណឹងល្អនោះដែរ។៉ កូឡុស 1:9-23

"សូមសរសើរដល់ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ដែលទ្រង់បានបង្កើតយើងឡើងជាថ្មី តាមសេចក្ដីមេត្តាករុណាដ៏ធំរបស់ទ្រង់ ដើម្បីឱ្យយើងរាល់គ្នាបានសេចក្ដីសង្ឃឹមដ៏រស់ ដោយសារព្រះយេស៊ូវគ្រីស្ទ ទ្រង់រស់ពីស្លាប់ឡើងវិញ។ ហើយឱ្យយើងបានមរដក ដែលមិនចេះពុករលួយ ក៏ឥតសៅហ្មង ហើយមិនដែលស្រពោនឡើយ ជាមរដកដែលបម្រុងទុកឱ្យយើងរាល់គ្នានៅស្ថានសួគ៌។ គឺឱ្យយើងរាល់គ្នា ដែលព្រះចេស្ដានៃព្រះកំពុងតែថែរក្សា ដោយសារសេចក្ដីជំនឿ សម្រាប់ឱ្យបានសេចក្ដីសង្គ្រោះ ដែលប្រុងប្រៀបនឹងសម្ដែងមកនៅជាន់ក្រោយបង្អស់នោះ។ អ្នករាល់គ្នាក៏មានសេចក្ដីអំណរជាខ្លាំង ក្នុងសេចក្ដីសង្គ្រោះនោះ ទោះបើសព្វថ្ងៃនេះត្រូវរងទុក្ខព្រួយជាយូរបន្តិច ដោយកើតមានសេចក្ដីល្បួងផ្សេងៗក៏ដោយ" ពេត្រុសទី១ 1:3-6

"ហើយដូច្នេះ" គាត់បាននិយាយថា "អ្នកនឹងត្រូវរាប់ជាសុចរិតដោយសារទ្រង់ទាំងដោយការទុកចិត្តលើអ្វីដែលទ្រង់បានធ្វើដោយអង្គទ្រង់ផ្ទាល់កាលទ្រង់នៅជាសាច់ឈាម ហើយត្រូវបានរងទុក្ខនៅពេលដែលទ្រង់ត្រូវបានគេព្យួរនៅលើដើមឈើផង។" ខ្ញុំបានសួរគាត់បន្តទៀតថា "តើសេចក្ដីសុចរិតរបស់បុរសនោះមានឥទ្ធិពលអ្វីមករាប់អ្នកផ្សេងទៀតឱ្យបានសុចរិតនៅចំពោះព្រះបានដោយរបៀបណាទៅ?" ហើយគាត់ប្រាប់ថា "ទ្រង់ជាព្រះដែលមានគ្រប់ចេស្ដា ហើយទ្រង់បានធ្វើអ្វីដែលទ្រង់ធ្វើនោះហើយ ហើយទ្រង់បានសុគតផងមិនមែនសម្រាប់អង្គទ្រង់ផ្ទាល់ទេ តែសម្រាប់ខ្ញុំ ដែលកិច្ចការដែលទ្រង់ធ្វើ

និងគុណសម្បត្តិទាំងអស់របស់ទ្រង់ នឹងត្រូវផ្តល់មកក្នុងខ្ញុំ ប្រសិនបើខ្ញុំជឿដល់ទ្រង់។"

គ្រីស្ទាន៖ តើអ្នកបានធ្វើអ្វីទៅចឹង?

សង្ឃឹម៖ ខ្ញុំធ្វើការជំទាស់នឹងការជឿរបស់ខ្ញុំ ដោយសារខ្ញុំគិតថាទ្រង់នឹងមិនសង្គ្រោះនោះឡើយ។

គ្រីស្ទាន៖ ហើយតើស្មោះត្រង់បាននិយាយអ្វីមកកាន់អ្នក?

សង្ឃឹម៖ គាត់ប្រាប់ខ្ញុំឱ្យទៅរកទ្រង់ ហើយមើលទៅ។ បន្ទាប់មកខ្ញុំនិយាយថា "វាជាការសន្មត់" តែគាត់និយាយថា "ទេ ដោយសារខ្ញុំត្រូវបានអញ្ជើញឱ្យមក។"

**"អស់អ្នកដែលនឿយព្រួយ ហើយផ្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឱ្យអ្នករាល់គ្នាឈប់សម្រាក" ម៉ាថាយ 11:28**

បន្ទាប់មកគាត់បានឱ្យសៀវភៅនៃការបញ្ចុះបញ្ចូលរបស់ព្រះយេស៊ូវ ដើម្បីជម្រុញខ្ញុំឱ្យមកដោយសេរី ហើយគាត់បាននិយាយទាក់ទងនឹងសៀវភៅនោះថាគ្រប់ទាំងចំណុចតូចមួយនិងចំណាងជើងវានៅតែឈរមាំមួនជាងផ្ទៃមេឃនិងផែនដីផង។

"ផ្ទៃមេឃ ហើយផែនដីនឹងកន្លងបាត់ទៅ តែពាក្យខ្ញុំមិនដែលបាត់ឡើយ។" **ម៉ាថាយ 24:35**

បន្ទាប់មកខ្ញុំបានសួរគាត់ នូវអ្វីដែលខ្ញុំត្រូវធ្វើនៅពេលដែលខ្ញុំមក ហើយគាត់បានប្រាប់ខ្ញុំថា ខ្ញុំត្រូវទូលអង្វរដោយលត់ជង្គង់ជាមួយចិត្តនិងព្រលឹងរបស់ខ្ញុំទៅកាន់ព្រះវរបិតាឱ្យបានបើកសម្តែងដល់ខ្ញុំ។

"មកចុះ ចូរយើងឱនកាយថ្វាយបង្គំទាំងអស់គ្នា ចូរយើងលុតជង្គង់នៅចំពោះព្រះយេហូវ៉ា ជាព្រះដ៏បង្កើតយើងខ្ញុំ" **ទំនុកដំកើង 95:6**

"កាលដានីយ៉ែលបានដឹងថា សំបុត្រនោះបានចុះហត្ថលេខាហើយ នោះលោកក៏ចូលទៅក្នុងផ្ទះរបស់លោក (រីឯបង្អួចនៃបន្ទប់របស់លោក ខាងក្រុងយេរូសាឡឹម ក៏នៅចំហ) លោកលុតជង្គង់ចុះអធិស្ឋាន ហើយអរព្រះគុណដល់ព្រះរបស់លោក១ថ្ងៃ៣ដង ដូចជាកាលពីមុន" **ដានីយ៉ែល 6:10**

"នោះឯងរាល់គ្នានឹងអំពាវនាវដល់អញ ហើយនិងទៅអធិស្ឋានដល់អញ រួចអញនឹងយល់ព្រមតាម។ ឯងរាល់គ្នានឹងស្វែងរកអញ ហើយនិងឃើញផង គឺកាលណាឯងស្វែងរកអញឱ្យអស់អំពីចិត្ត" **យេរេមា 29:12, 13**

បន្ទាប់មកខ្ញុំបានសួរគាត់ថែមទៀតថា "តើខ្ញុំត្រូវធ្វើការទូលអង្វរដល់ទ្រង់យ៉ាងដូចម្តេច?" ហើយគាត់និយាយថា "ចូរទៅ នោះអ្នកនឹងរកឃើញទ្រង់

នៅលើបល័ង្កនៃសេចមេត្តា ដែលទ្រង់បានអង្គុយរាប់ឆ្នាំដើម្បីនឹងផ្តល់ការលើកលែងនិងការអត់ទោសដល់អស់អ្នកដែលមករកទ្រង់។”

“គឺនៅទីនោះហើយដែលអញនឹងមកជួបនឹងឯង ហើយនិងនិយាយនឹងឯងពីលើទីសន្តោសប្រោស នៅកណ្តាលចេរូប៊ីនទាំង២ដែលនៅលើហឹបនៃទីបន្ទាល់ ដើម្បីប្រាប់ឯងពីអស់ទាំងសេចក្តីដែលអញនឹងបង្គាប់ដល់ពួកកូនចៅអ៊ីស្រាអែល។” និក្ខមនំ 25:22

“គឺទ្រង់មានព្រះបន្ទូលនឹងម៉ូសេថា ចូរហាមដល់អើរ៉ុនបងឯង កុំឱ្យចូលជារាល់ពេលមកក្នុងទីបរិសុទ្ធខាងក្នុងវាំងនន នៅមុខទីសន្តោសប្រោសដែលនៅលើហឹបនោះឡើយ ក្រែងលោត្រូវស្លាប់ ដ្បិតអញនឹងលេចមកក្នុងពពកនៅលើទីសន្តោសប្រោស” លេវីវិន័យ 16:2

“រួចកាលម៉ូសេបានចូលទៅទូលនឹងព្រះ ក្នុងត្រសាលជំនុំ នោះលោកឮសំឡេងមានព្រះបន្ទូលមកពីលើទីសន្តោសប្រោស ដែលនៅលើហឹបនៃសេចក្តីបន្ទាល់ គឺពីកណ្តាលចេរូប៊ីនទាំង២ ហើយលោកក៏ទូលតបនឹងទ្រង់។” ជនគណនា 7:89

“ដូច្នេះ ត្រូវឱ្យយើងរាល់គ្នាមកដល់បល្ល័ង្កនៃព្រះគុណ ដោយក្លាហាន ដើម្បីនឹងទទួលសេចក្តីមេត្តា ហើយរកបានព្រះគុណសម្រាប់នឹងជួយដល់ពេលត្រូវការចុះ។” ហេព្រើរ 4:16

ខ្ញុំបានប្រាប់គាត់ថា ខ្ញុំមិនដឹងនិយាយអ្វីទេនៅពេលដែលខ្ញុំមក ហើយគាត់

បានប្រាប់ខ្ញុំឱ្យនិយាយបែបនេះថា "សូមឱ្យព្រះបានមេត្តាដល់ខ្ញុំជាមនុស្ស មានបាបម្នាក់ ហើយសូមធ្វើឱ្យខ្ញុំបានដឹងនិងជឿដល់ព្រះយេស៊ូវគ្រីស្ទ ដោយសារខ្ញុំឃើញថា ប្រសិនបើគ្មានសេចក្ដីសុចរិតរបស់ទ្រង់ទេ ឬថាបើខ្ញុំ មិនមានសេចក្ដីជំនឿនៅក្នុងសេចក្ដីសុចរិតនោះទេ ខ្ញុំនឹងត្រូវបោះបង់ចោល ជាមិនខាន។ ព្រះអម្ចាស់អើយ ខ្ញុំបានឮថាទ្រង់ជាព្រះពេញដោយសេចក្ដី មេត្តាករុណា ហើយដែលទ្រង់បានតាំងបុត្រារបស់ទ្រង់ព្រះយេស៊ូវគ្រីស្ទជា ព្រះអង្គសង្គ្រោះនៃលោកិយនេះទាំងមូល ហើយលើសពីនោះទៀតថា ទ្រង់ នឹងថ្វាយដោយពេញចិត្តដល់មនុស្សមានបាបកំសត់នេះដូចជាខ្ញុំ (ហើយខ្ញុំ ជាមនុស្សមានបាបពិត)។ ព្រះអម្ចាស់អើយ សូមយកឱកាសនេះ ហើយ បង្ហាញព្រះគុណរបស់ទ្រង់នៅក្នុងសេចក្ដីសង្គ្រោះនៃព្រលឹងរបស់ទូលបង្គំ តាមរយៈបុត្រារបស់ទ្រង់ព្រះយេស៊ូវគ្រីស្ទ។ អាម៉ែន។"

គ្រីស្ទាន៖ ហើយតើអ្នកបានធ្វើដូចដែលអ្វីដែលអ្នកបានប្រាប់មកទេ?

សង្ឃឹម៖ បាទបាន ធ្វើហើយធ្វើទៀត។

គ្រីស្ទាន៖ ហើយតើព្រះវរបិតាបានបង្ហាញព្រះរាជបុត្រាដល់អ្នកទេ?

សង្ឃឹម៖ ទេ ពីដំបូងអត់ទេ ក៏មិនមែនទីពីរ មិនមែនទីបី មិនមែនទីបួន មិន មែនទីប្រាំ មិនមែនទីប្រាំមួយដូចគ្នា។

គ្រីស្ទាន៖ តើអ្នកធ្វើអ្វីទៅអីចឹង?

សង្ឃឹម៖ អ្វី? ខ្ញុំមិនអាចប្រាប់ថានឹងធ្វើអ្វីនោះឡើយ។

គ្រីស្ទាន៖ តើអ្នកមិនមានគំនិតនឹងបោះបង់ចោលការអធិស្ឋានទេឬអី?

សង្ឃឹម៖ បាទ ហើយបានប្រាប់មួយរយដងទ្វេផង។

គ្រីស្ទាន៖ ហើយតើអ្វីទៅជាហេតុផលដែលអ្នកមិនបោះបង់ចោលនោះ?

សង្ឃឹម៖ ខ្ញុំបានជឿថាវាជាការពិតដូចដែលគេបានប្រាប់ខ្ញុំមកមែន។ ថាក្រៅពីសេចក្ដីសុចរិតរបស់ព្រះគ្រីស្ទនេះ នោះលោកិយទាំងមូលមិនអាចសង្គ្រោះខ្ញុំបានឡើយ។ ហើយដូច្នេះ ខ្ញុំគិតមកខ្លួនខ្ញុំថា ប្រសិនបើខ្ញុំមិនធ្វើ ខ្ញុំនឹងស្លាប់។ ហើយខ្ញុំអាចស្លាប់បានតែនៅនឹងបល្ល័ង្កនៃព្រះគុណប៉ុណ្ណោះ។ ដោយការទាំងអស់នេះមកដល់គំនិតរបស់ខ្ញុំថា "ប្រសិនបើខ្ញុំរង់ចាំ រងចាំវា ពីព្រោះវានឹងមកមែនពិត និងមិនរងចាំឡើយ។"

**"ដ្បិតការជាក់ស្ដែងនេះ ទុកសម្រាប់ដល់វេលាកំណត់ ក៏កំពុងស្រូតឱ្យដល់ពេលនោះហើយ នៅគ្រានោះ នឹងមិនកុហកទេ បើសិនជាបង្អង់យូរ ក៏ចូររង់ចាំចុះ ដ្បិតនឹងមកជាពិត ឥតរារង់ឡើយ។" ហាបាគុក 2:3**

ដូច្នេះខ្ញុំបន្តអធិស្ឋានរហូតដល់ព្រះវរបិតាបង្ហាញព្រះរាជបុត្រាដល់ខ្ញុំ។

គ្រីស្ទាន៖ ហើយតើត្រូវបានបង្ហាញមកអ្នកយ៉ាងម៉េចទៅ?

សង្ឃឹម៖ ខ្ញុំមិនបានឃើញទ្រង់ដោយភ្នែកខាងរូបកាយរបស់ខ្ញុំឡើយ តែដោយភ្នែកនៃការយល់ដឹងរបស់ខ្ញុំវិញ។

"ដើម្បីឱ្យភ្នែកចិត្តរបស់អ្នករាល់គ្នាបានភ្លឺឡើង ប្រយោជន៍ឱ្យបានដឹងថា ដែលទ្រង់ហៅអ្នករាល់គ្នា នោះមានសេចក្ដីសង្ឃឹមជាយ៉ាងណា ហើយថា សិរីល្អដ៏ប្រសើរក្រៃលែងនៃមរដកទ្រង់ ក្នុងពួកបរិសុទ្ធជាយ៉ាងណាផង។ ហើយថា ព្រះចេស្ដាដ៏ខ្លាំងលើសលន់របស់ទ្រង់ ដល់យើងរាល់គ្នាដែលជឿជាយ៉ាងណាដែរ តាមដែលកម្លាំងទ្រង់ដ៏មានឫទ្ធិបានពូកែនឹងធ្វើ" **អេភេសូ 1:18, 19**

ហើយវាដូច្នោះឯង។ ថ្ងៃមួយខ្ញុំសោកសៅពេក ខ្ញុំគិតថាសោកសៅជាងពេលណាទាំងអស់នៅក្នុងជីវិតរបស់ខ្ញុំ ហើយសេចក្ដីសោកសៅនេះតាមរយៈ ការដែលឃើញថ្មីៗនៃភាពសម្បើមនិងភាពអប្រិយនៃបាបរបស់ខ្ញុំ។ ហើយកាលដែលខ្ញុំមិនឃើញអ្វីទាំងអស់ក្រៅពីស្ថាននរក និងការដាក់ទោសអស់កល្បជានិច្ចនៃព្រលឹងរបស់ខ្ញុំភ្លាមនោះក្នុងកាលដែលខ្ញុំគិតនោះ ខ្ញុំបានឃើញព្រះអម្ចាស់យេស៊ូវបានមើលមកក្រោមពីស្ថានសួគ៌មើលមកខ្ញុំហើយនិយាយថា "ចូរជឿដល់ព្រះយេស៊ូវគ្រីស្ទ នោះអ្នកនឹងបានសង្គ្រោះ។"

"គេក៏ប្រាប់គាត់ថា ចូរជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទទៅ នោះនឹងបានសង្គ្រោះហើយ ព្រមទាំងពួកគ្រួសារលោកផង" **កិច្ចការ 16:31**

តែខ្ញុំបានឆ្លើយថា "ព្រះអម្ចាស់អើយ ខ្ញុំជាមនុស្សដ៏មានបាបខ្លាំងណាស់" ហើយទ្រង់ឆ្លើយថា "ព្រះគុណរបស់ខ្ញុំគ្រប់គ្រាន់ដល់ឯងហើយ។"

"តែទ្រង់មានព្រះបន្ទូលមកខ្ញុំថា គុណរបស់អញល្មមដល់ឯងហើយ ដ្បិតកម្លាំងអញបានពេញខ្នាត ដោយសេចក្តីកំសោយ ដូច្នេះ ខ្ញុំនឹងស៊ូអួតពីសេចក្តីកំសោយរបស់ខ្ញុំ ដោយអំណរជាខ្លាំង ដើម្បីឱ្យព្រះចេស្តានៃព្រះគ្រីស្ទបានសណ្ឋិតនៅនឹងខ្ញុំ" **កូរិនថូសទី២ 12:9**

បន្ទាប់មកខ្ញុំនិយាយថា "តែព្រះអម្ចាស់អើយ តើជឿអ្វីទៅ" ហើយបន្ទាប់មកខ្ញុំបានឃើញថានិយាយដូច្នេះ "អ្នកណាដែលមកឯខ្ញុំនឹងមិនត្រូវឃ្លានឡើយ ហើយអ្នកណាដែលជឿដល់ខ្ញុំនិងមិនត្រូវស្រេកឡើយ។"

"ព្រះយេស៊ូវមានព្រះបន្ទូលថា ខ្ញុំជានំបុ័ងជីវិត អ្នកណាដែលមកឯខ្ញុំ នោះនឹងមិនឃ្លានទៀតឡើយ ហើយអ្នកណាដែលជឿដល់ខ្ញុំ ក៏មិនត្រូវស្រេកដែរ" **យ៉ូហាន 6:35**

ថាការជឿនិងមកតែមួយទេ ហើយអ្នកដែលមក នោះគឺរត់ចេញនៅក្នុងចិត្តនិងសេចក្តីស្រឡាញ់របស់គាត់នូវសេចក្តីសង្គ្រោះដោយព្រះគ្រីស្ទ នោះគាត់ជាអ្នកជឿដល់ព្រះគ្រីស្ទពិត។ បន្ទាប់មកទឹលបានបញ្ឈរនៅក្នុងភ្នែករបស់ខ្ញុំ ហើយខ្ញុំបានសួរថែមទៀតថា "តែ ព្រះអម្ចាស់អើយ តើមនុស្សមានបាបខ្លាំងដូចជាខ្ញុំនឹងត្រូវបានទទួលនៅចំពោះទ្រង់ និងបានសង្គ្រោះដែរទេ?" ហើយខ្ញុំបានឮទ្រង់មានបន្ទូលថា "ហើយអ្នកណាដែលមករកខ្ញុំ ខ្ញុំនឹងមិនបោះបង់ចោលឡើយ។"

**"អស់អ្នកណាដែលព្រះវរបិតាប្រទានមកខ្ញុំ នោះនឹងមកឯខ្ញុំ ហើយអ្នកណាដែលមកឯខ្ញុំ ខ្ញុំក៏មិនដែលចោលទៅក្រៅឡើយ" យ៉ូហាន 6:37**

បន្ទាប់មកខ្ញុំនិយាយថា "ព្រះអម្ចាស់អើយ តើខ្ញុំត្រូវគិតដល់ទ្រង់ពេលដែលខ្ញុំមករកទ្រង់ដូចម្តេច ថាសេចក្តីជំនឿខ្ញុំនឹងនៅកន្លែងដែលត្រឹមត្រូវចំពោះទ្រង់នោះ?" បន្ទាប់មកទ្រង់មានបន្ទូលថា "ព្រះយេស៊ូវគ្រីស្ទយាងមកលើលោកិយនេះដើម្បីសង្គ្រោះមនុស្សមានបាប។"

**"ពាក្យនេះគួរជឿ ហើយគួរទទួលគ្រប់យ៉ាង គឺថា ព្រះគ្រីស្ទយេស៊ូវទ្រង់បានយាងមកក្នុងលោកីយ៍ ដើម្បីនឹងជួយសង្គ្រោះមនុស្សមានបាប ដែលខ្ញុំនេះជាលេខ១ក្នុងពួកគេ" ធីម៉ូថេទី១ 1:15**

"ទ្រង់ជាចុងបញ្ចប់នៃក្រិត្យវិន័យសម្រាប់សេចក្តីសុចរិតដល់គ្រប់គ្នាដែលជឿ។"

**"បើដូច្នេះ យើងនឹងថា លោកអ័ប្រាហាំ ជាអយ្យកោយើង បានអ្វីខ្លះ ខាងឯសាច់ឈាម។ ដ្បិតបើសិនណាជាលោកអ័ប្រាហាំបានរាប់ជាសុចរិត ដោយការដែលលោកប្រព្រឹត្ត នោះលោកមានកន្លែងនឹងអួតខ្លួនហើយ តែមិនមែនចំពោះព្រះទេ។ តើគម្ពីរថាដូចម្តេច គម្ពីរថា "អ័ប្រាហាំបានជឿដល់ព្រះ ហើយសេចក្តីជំនឿនោះ បានរាប់ជាសេចក្តីសុចរិតដល់លោក"។ រីឯអ្នកណាដែលធ្វើការ នោះរង្វាន់មិនរាប់ជាគុណរបស់ថៅហ្វាយទេ គឺទុកជាថ្លៃឈ្នួលវិញទេ**

តើ។ តែចំណែកអ្នកដែលមិនធ្វើការសោះ គឺគ្រាន់តែជឿដល់ព្រះអង្គ ដែលទ្រង់ប្រោសឱ្យមនុស្សទមិឡល្មើសបានសុចរិត នោះសេចក្តីជំនឿរបស់អ្នកនោះ បានរាប់ទុកជាសេចក្តីសុចរិតវិញ។ ដូចជាហ្លួងដាវីឌបានសម្តែងពីសណ្ឋានដ៏មានពរនៃមនុស្ស ដែលព្រះទ្រង់រាប់ជាសុចរិតក្រៅពីការប្រព្រឹត្តថា "មានពរហើយ អ្នកណាដែលការទទឹងច្បាប់របស់ខ្លួនបានអត់ទោសឱ្យ និងបាបខ្លួនបានគ្របបាំង"។ មានពរហើយ មនុស្សណាដែលព្រះអម្ចាស់មិនរាប់ជាមានបាបឡើយ។ដូច្នេះ តើបានពរនោះ ចំពោះតែពួកកាត់ស្បែកតែប៉ុណ្ណោះ ឬពួកមិនកាត់ស្បែកក៏បានដែរ ដ្បិតយើងថាសេចក្តីជំនឿ បានរាប់ទុកជាសេចក្តីសុចរិត ដល់លោកអ័ប្រាហាំ។ ចុះសេចក្តីនោះបានរាប់ដូចម្តេច តើពីកាលលោកបានកាត់ស្បែករួចហើយ ឬនៅឡើយ មិនមែនពីកាលលោកបានកាត់ស្បែកហើយនោះទេ គឺក្នុងកាលដែលមិនទាន់កាត់ស្បែកនៅឡើយវិញ។ ហើយលោកបានទទួលពិធីកាត់ស្បែកនេះ ទុកជាទីសម្គាល់ ជាត្រានៃសេចក្តីសុចរិត ដែលមកដោយសេចក្តីជំនឿនោះឯង គឺជាសេចក្តីជំនឿដែលលោកមានពីកាលមិនទាន់កាត់ស្បែកនៅឡើយ ដើម្បីឱ្យបានធ្វើជាឪពុក ដល់អស់អ្នកដែលជឿ ឥតកាត់ស្បែកផង ប្រយោជន៍ឱ្យបានរាប់សេចក្តីសុចរិតនេះដល់អ្នកទាំងនោះ។ ហើយឱ្យបានធ្វើជាឪពុក ដល់ពួកដែលមិនគ្រាន់តែកាត់ស្បែកប៉ុណ្ណោះ គឺដែលដើរតាមដាននៃសេចក្តីជំនឿរបស់លោកអ័ប្រាហាំ ជាអយ្យកោយើងផង ជាសេចក្តីជំនឿដែលលោកមាន ពីកាលមិនទាន់កាត់ស្បែកនៅឡើយ។ ដ្បិតសេចក្តីសន្យាដល់លោកអ័ប្រាហាំ និងពូជលោក ឱ្យបានលោកីយ៍ជាមរដក នោះមិនមែនដោយសារក្រឹត្យវិន័យទេ គឺដោយសារសេចក្តីសុចរិតដែលមកដោយសេចក្តីជំនឿវិញ។ ពីព្រោះបើសិនជាពួកអ្នកដែលអាងក្រឹត្យវិន័យបានគ្រងមរដក នោះសេចក្តីជំនឿបានទៅជាឥតអំពើ

វិញ ហើយសេចក្តីសន្យាក៏ឥតប្រយោជន៍ដែរ។ ឯក្រឹត្យវិន័យ នោះបង្កើតសេចក្តីក្រោធ ដ្បិតកន្លែងណាដែលគ្មានក្រឹត្យវិន័យ នោះក៏ឥតមានសេចក្តីរំលងដែរ។ ដូច្នេះ សេចក្តីសន្យាបានមកដោយសេចក្តីជំនឿ ដើម្បីឱ្យបានត្រូវខាងព្រះគុណ ប្រយោជន៍ឱ្យសេចក្តីសន្យាបានខ្ជាប់ខ្ជួន ដល់ពូជលោកតទៅ មិនមែនត្រឹមតែពូជដែលអាងក្រឹត្យវិន័យប៉ុណ្ណោះ គឺដល់ទាំងពូជដែលអាងសេចក្តីជំនឿរបស់លោកអ័ប្រាហាំ ដែលជាអយ្យកោនៃយើងទាំងអស់គ្នាថែមទៀតផង។ ដូចមានសេចក្តីចែងទុកមកថា អញបានតាំងឯងឱ្យធ្វើជាឪពុកដល់សាសន៍ជាច្រើន រីឯនៅចំពោះព្រះ ជាទីជឿរបស់លោក ដែលទ្រង់ប្រោសមនុស្សស្លាប់ឱ្យរស់ឡើងវិញ ទាំងមានព្រះបន្ទូលពីរបស់ដែលគ្មាន ទុកដូចជាមានហើយ នោះលោកជាឪពុករបស់យើងមែន” រ៉ូម 4:1-17

“ទ្រង់បានសុគតសម្រាប់អំពើបាបរបស់យើង ហើយរស់ឡើងវិញសម្រាប់ការរាប់ជាសុចរិតរបស់យើង។”

“ដែលទ្រង់ត្រូវគេបញ្ជូនទៅឱ្យមានទោស ដោយព្រោះអំពើរំលងរបស់យើងរាល់គ្នា ហើយបានប្រោសឱ្យមានព្រះជន្មរស់ឡើងវិញ ប្រយោជន៍ឱ្យយើងរាល់គ្នាបានរាប់ជាសុចរិត។” រ៉ូម 4:25

“ទ្រង់ស្រឡាញ់យើង និងបានលាងសម្អាតយើងចេញពីបាបរបស់យើងដោយព្រះលោហិតរបស់ទ្រង់ផ្ទាល់។”

“ហើយអំពីព្រះយេស៊ូវគ្រីស្ទជាស្មរបន្ទាល់ស្មោះត្រង់ ដែលកើតពីពួកស្លាប់មក មុនគេបង្អស់ ជាអធិបតីលើអស់ទាំងស្តេចនៅផែនដី រីឯព្រះអង្គដែលទ្រង់ស្រឡាញ់យើងរាល់គ្នា ហើយបានលាងយើងដោយព្រះលោហិតទ្រង់ ឱ្យបានរួចពីបាប” **វិវរណៈ 1:5**

“ទ្រង់ជាអង្គផ្សះផ្សារវាងព្រះនិងយើង។”

“ពីព្រោះមានព្រះតែ១ ហើយមានអ្នកសង្រ្គបសង្រួមតែ១ នៅកណ្តាលព្រះ និងមនុស្ស គឺជាមនុស្សដ៏ជាព្រះគ្រីស្ទយេស៊ូវនោះ” **ធីម៉ូថេទី១ 2:5**

“ទ្រង់រស់នៅដើម្បីនឹងធ្វើការទូលអង្វរជំនួសយើង។”

“ដោយហេតុនោះបានជាទ្រង់អាចនឹងជួយសង្គ្រោះសព្វគ្រប់បាន ដល់មនុស្សទាំងអស់ ដែលចូលទៅឯព្រះ ដោយសារទ្រង់ ដ្បិតទ្រង់មានព្រះជន្មរស់នៅជានិច្ច ដើម្បីនឹងជួយអង្វរជំនួសគេ។” **ហេព្រើរ 7:25**

ចេញពីអ្វីដែលខ្ញុំបានប្រមូលមក ខ្ញុំត្រូវតែរកសេចក្តីសុចរិតនៅក្នុងព្រះអង្គមួយអង្គនេះ សម្រាប់ជាការស្កប់ស្កល់ដល់អំពើបាបរបស់ខ្ញុំដោយសារលោហិតរបស់ទ្រង់ ដែលអ្វីដែលទ្រង់បានធ្វើនៅក្នុងការស្តាប់បង្គាប់ ទៅកាន់ក្រិត្យវិន័យរបស់ព្រះវរបិតារបស់ទ្រង់ ហើយការដែលបានចុះចូលនៅក្នុងការដាក់ទោសផង មិនមែនសម្រាប់ខ្លួនទ្រង់ឡើយ តែសម្រាប់អស់អ្នកណាដែលនឹងទទួលយកសម្រាប់សេចក្តីសង្គ្រោះរបស់គេ ហើយចេះអរគុណ

។ ហើយពេលនេះចិត្តរបស់ខ្ញុំពេញដោយអំណរ ភ្នែករបស់ខ្ញុំពេលដោយទឹកភ្នែក ហើយសេចក្ដីស្រឡាញ់របស់ខ្ញុំបានរត់បែរមកស្រឡាញ់ព្រះនាម រាស្រ្ដ និងផ្លូវរបស់ព្រះយេស៊ូវគ្រីស្ទ។

គ្រីស្ទាន៖ នេះជាការបើកសម្ដែងរបស់ព្រះគ្រីស្ទដល់ព្រលឹងអ្នកពិតមែន។ តែសូមប្រាប់ខ្ញុំប្រាកដមកថាតើការនេះមានឥទ្ធិពលអ្វីដល់ព្រលឹងរបស់អ្នកវិញ។

សង្ឃឹម៖ វាធ្វើឱ្យខ្ញុំឃើញថា លោកិយទាំងមូល មានទាំងសេចក្ដីសុចរិតទាំងនោះ កំពុងតែនៅក្នុងភាពនៃការដាក់ទោសពិត។ វាបានធ្វើឱ្យខ្ញុំឃើញថាព្រះវរបិតា ដោយសារទ្រង់សុចរិត នោះទ្រង់អាចរាប់ជាសុចរិតដល់អ្នកមានបាបណាដែលមកបានដោយត្រឹមត្រូវ។ វាបានធ្វើឱ្យខ្ញុំខ្មាសពីអំពើអាក្រក់នៃជីវិតពីដើមរបស់ខ្ញុំណាស់ ហើយបានធ្វើឱ្យខ្ញុំដឹងពីភាពល្ងង់ខ្លៅរបស់ខ្ញុំផ្ទាល់ ដោយសារមិនដែលមានគំនិតណាមកក្នុងចិត្តខ្ញុំមុននេះ ដែលបង្ហាញខ្ញុំដូចនេះ ពីសម្រស់របស់ព្រះយេស៊ូវគ្រីស្ទឡើយ។ វាបានធ្វើឱ្យខ្ញុំស្រឡាញ់ជីវិតបរិសុទ្ធ និងប្រាថ្នាចង់ធ្វើអ្វីដែលគួរឱ្យគោរព និងសិរីល្អដល់ព្រះនាមព្រះយេស៊ូវគ្រីស្ទ។ បាទ ហើយខ្ញុំគិតថាពេលនេះខ្ញុំមានឈាមរាប់លីត្រនៅក្នុងខ្លួន ដែលខ្ញុំអាចនឹងបង្ហូរវាទាំងអស់ដោយយល់ដល់ព្រះនាមព្រះអម្ចាស់យេស៊ូវ។

## ល្ងង់ខ្លៅបង្ហាញភាពល្ងង់ខ្លៅរបស់ខ្លួន

បន្ទាប់មកខ្ញុំបានឃើញថាពេញដោយសង្ឃឹមបានមើលមកក្រោយហើយបានឃើញល្ងង់ខ្លៅ ជាម្នាក់ដែលពួកគេទុកចោលពីក្រោយ គាត់បានមកតាម។ "មើលទៅ" គាត់បាននិយាយទៅកាន់គ្រីស្ទានថា "មើលទៅក្មេងដែលនៅពីចម្ងាយនោះនឹងនៅតែដើរតាមពីក្រោយដល់ណាទៀត។"

គ្រីស្ទាន៖ អេ អេ ខ្ញុំឃើញគាត់ហើយ។ គាត់មិនខ្វល់ពីបក្សពួកដូចយើងទេ។

សង្ឃឹម៖តែខ្ញុំគិតថាវាមិនធ្វើឱ្យគាត់មានគ្រោះថ្នាក់ទេ បើគាត់ដើរមកដំណាលយើងដល់ទីនេះដែរ។

គ្រីស្ទាន៖ ពិតហើយ តែខ្ញុំធានាថាគាត់គិតដូច្នោះមែន។

សង្ឃឹម៖ "ខ្ញុំគិតថាគាត់អីចឹងមែន តែយ៉ាងណាក៏ដោយ ចូរយើងចាំគាត់ផង។" ដូច្នេះពួកគេក៏បានរងចាំមែន។

គ្រីស្ទាន៖ បន្ទាប់មកគ្រីស្ទាននិយាយទៅគាត់ថា "មកនេះមក ហេតុអ្វីបានជានៅក្រោយខ្លាំងម្ល៉េះ?"

ល្ងង់ខ្លៅ៖ ខ្ញុំសប្បាយដែលដើរម្នាក់ឯង ប្រសើរជាងមានគ្នាឆ្ងាយណាស់ លើកលែងតែខ្ញុំចូលចិត្តវាជាងប៉ុណ្ណោះ។

គ្រីស្ទាន៖ បន្ទាប់មកគ្រីស្ទាននិយាយទៅកាន់ពេញដោយសង្ឃឹម (និយាយតិចៗ)ថា "តើខ្ញុំមិនបានប្រាប់ទេថាគាត់មិនខ្វល់ពីយើងបានជាគ្នាទេ? តែយ៉ាងណាក៏ដោយ គាត់និយាយថា "មក ហើយចូរយើងនិយាយគ្នាក្នុងកាលដែលមកកន្លែងដាច់ស្រយាលនេះ។" រួចបានបង្វែនិយាយទៅរកល្ងង់ខ្លៅវិញ គាត់បាននិយាយថា "ចូរមក អ្នកយ៉ាងម៉េចហើយ? តើជំហាររវាងព្រះនិងព្រលឹងរបស់អ្នកពេលនេះយ៉ាងម៉េចហើយ?"

ល្ងង់៖ ខ្ញុំសង្ឃឹមថាល្អ។ ដោយសារខ្ញុំតែងតែមានអារម្មណ៍ល្អ ដែលចូលក្នុងគំនិតរបស់ខ្ញុំ ដែលមកកំសាន្តចិត្តខ្ញុំពេលដែលខ្ញុំដើរ។

គ្រីស្ទាន៖ តើអារម្មណ៍ល្អអីទៅ? សូមប្រាប់ពួកយើងមើល។

ល្ងង់៖ គឺខ្ញុំបានគិតពីព្រះនិងស្ថានសួគ៌។

គ្រីស្ទាន៖ អារក្សនិងវិញ្ញាណដែលត្រូវទទួលទោសក៏គិតដូចតែគ្នាហ្នឹង។

ល្ងង់៖ តែខ្ញុំបានគិត ហើយខ្ញុំប្រាថ្នាចង់បានផង។

គ្រីស្ទាន៖ មនុស្សជាច្រើនដែលដូចជាមិនមកទីនោះក៏គិតដូចគ្នា។ ព្រលឹងរបស់មនុស្សកំជិលប្រាថ្នាចង់បាន ហើយតែមិនមានអ្វីទាំងអស់។

**"ព្រលឹងនៃមនុស្សខ្ជិលច្រអូសប្រាថ្នាចង់បាន តែមិនបានអ្វីសោះ ឯព្រលឹងនៃមនុស្សព្យាយាម នោះនឹងបានជាបរិបូរវិញ។" សុភាសិត 13:4**

លង្ង់៖ តែខ្ញុំបានគិត ហើយបានបោះបង់ចោលរបស់ទាំងអស់។

គ្រីស្ទាន៖ នោះខ្ញុំសង្ស័យថា ការចាកចេញពីរបស់អស់ទាំងនោះជាការលំបាកមួយ។ ពិតណាស់ ជាបញ្ហាលំបាកជាងគេដែលមនុស្សជាច្រើនបានដឹង។ តែហេតុអ្វី ឬដោយសារអ្វី ដែលអ្នកត្រូវបានអូសទាញថាអ្នកបានបោះបង់គ្រប់ទាំងអស់សម្រាប់ព្រះនិងស្ថានសួគ៌នោះ?

លង្ង់៖ ចិត្តរបស់ខ្ញុំប្រាប់ខ្ញុំដូច្នោះ។

គ្រីស្ទាន៖ មនុស្សឆ្លាតនិយាយថា "អ្នកដែលទុកចិត្តលើចិត្តរបស់ខ្លួនជាមនុស្សល្ងង់។"

**"អ្នកណាដែលទីពឹងតែចិត្តខ្លួនឯង នោះជាអ្នកល្ងីល្ងើហើយ តែអ្នកណាដែលប្រព្រឹត្តដោយប្រាជ្ញាវិញ នោះនឹងបានប្រោសឱ្យរួច។" សុភាសិត 28:26**

លង្ង់៖ និយាយពីចិត្តដែលទុច្ចរិតទេតើ តែចិត្តខ្ញុំវិញល្អហ្នឹង។

គ្រីស្ទាន៖ តែតើអ្នកមានអ្វីមកអះអាងដែរ?

លង្ង់៖ វាបានកំសាន្តចិត្តខ្ញុំនៅក្នុងសង្ឃឹមពីស្ថានសួគ៌។

គ្រីស្ទាន៖ មានតែតាមរយៈសេចក្ដីបោកបញ្ឆោតប៉ុណ្ណោះ ដោយសារចិត្តរបស់មនុស្សអាចនឹងផ្ដល់ការកំសាន្តចិត្តដល់ម្នាក់នៅក្នុងសង្ឃឹមពីការដែលគាត់មានមិនមានហេតុដែលសង្ឃឹមសោះ។

ល្ងង់៖ តែចិត្តនិងជីវិតរបស់ខ្ញុំយល់ស្របជាមួយគ្នា ហើយដូច្នេះសេចក្ដីសង្ឃឹមរបស់ខ្ញុំជាគ្រឹះល្អហើយ។

គ្រីស្ទាន៖ តើអ្នកណាប្រាប់អ្នកថាចិត្តនិងជីវិតរបស់អ្នកយល់ស្របគ្នានោះ?

ល្ងង់៖ ចិត្តរបស់ខ្ញុំប្រាប់មកអីចឹង។

គ្រីស្ទាន៖ "ចូរសួរគ្នារបស់ខ្ញុំចុះថាខ្ញុំជាចោរទេ។" ចិត្តរបស់អ្នកប្រាប់អ្នកអញ្ចឹង! ក្រៅពីព្រះបន្ទូលរបស់ព្រះធ្វើបន្ទាល់ពីការនោះ នោះទីបន្ទាល់ណាផ្សេងទៀតមិនមានតម្លៃអ្វីឡើយ។

ល្ងង់៖ តែតើមិនមែនជាចិត្តដែលល្អទេឬ ដែលមានគំនិតល្អៗនោះ? ហើយតើមិនមែនជាជីវិតល្អទេឬ ដែលជាជីវិតមួយតាមបញ្ញាត្តិរបស់ព្រះនោះ?

គ្រីស្ទាន៖ បាត ចិត្តដែលល្អនោះហើយដែលមានគំនិតល្អ ហើយជីវិតល្អនោះហើយដែលតាមបញ្ញាត្តិរបស់ព្រះ តែវាជាការមួយដែលមានការទាំងនេះ ហើយការមួយទៀតដែលគ្រាន់តែគិតអីចឹងប៉ុណ្ណោះ។

ល្ងង់៖ សូមអ្នកប្រាប់មកថា តើអ្វីដែលអ្នករាប់ថាគំនិតល្អៗ ហើយជីវិតអ្វីដែលតាមបញ្ញាត្តិរបស់ព្រះនោះ?

គ្រីស្ទាន៖ មានគំនិតល្អៗដែលជាប្រភេទអ្នកមុជទៅ ខ្លះពាក់ព័ន្ធនឹងខ្លួនយើង ខ្លះពីព្រះ ខ្លះទៀតពីព្រះគ្រីស្ទ និងខ្លះទៀតពីការផ្សេងៗ។

លូង់៖ តើអ្វីទៅជាគំនិតល្អៗទាក់ទងនឹងខ្លួនយើង?

គ្រីស្ទាន៖ ដូចជាការដែលស្របនឹងព្រះបន្ទូលរបស់ព្រះ។

លូង់៖ នៅពេលណាដែលគំនិតរបស់យើងយល់ស្របនឹងព្រះបន្ទូលរបស់ព្រះនោះ?

គ្រីស្ទាន៖ នៅពេលដែលយើងធ្វើការកាត់ទោសដូចគ្នានោះមកលើខ្លួនយើង ដែលព្រះបន្ទូលផ្តល់មក។ ឱ្យខ្ញុំពន្យល់ថា ព្រះបន្ទូលរបស់ព្រះនិយាយពីមនុស្សនៅក្នុងស្ថានភាពទូទៅថា "មិនមានអ្នកណាដែលសុចរិតឡើយ មិនមានអ្នកណាដែលធ្វើល្អឡើយ" ព្រះបន្ទូលក៏និយាយទៀតថា "គ្រប់ទាំងការស្រមើស្រម៉ៃរបស់ចិត្តមនុស្សមានតែការអាក្រក់ និងវានៅបន្តជានិច្ច។"

**"ដូច្នេះ តើដូចម្តេច យើងល្អជាគេឬទេ មិនមែនទេ ដ្បិតយើងខ្ញុំបានចោទប្រកាន់រួចហើយថា ទោះទាំងសាសន៍យូដា និងសាសន៍ក្រេកផង សុទ្ធតែនៅក្រោមអំពើបាប។ ដូចមានសេចក្តីចែងទុកមកថា គ្មានអ្នកណាសុចរិតសោះ សូម្បីតែម្នាក់ក៏គ្មានផង។ គ្មានអ្នកណាដែលយល់ គ្មានអ្នកណាដែលស្វែងរកព្រះ។ គ្រប់គ្នាបានបែរចេញ ហើយត្រឡប់ជាឥតប្រយោជន៍ទាំងអស់គ្នា គ្មានអ្នកណាដែលប្រព្រឹត្តតាមសេចក្តីសប្បុរសសោះ តែម្នាក់ក៏គ្មានផង។ បំពង់កគេជាផ្នូរខ្មោចនៅចំហ គេប្រើអណ្តាតគេសម្រាប់នឹងបញ្ឆោត ឯនៅបបូរមាត់គេមានសុទ្ធតែពិសពស់ហានុមាន ហើយមាត់គេមានពេញដោយសេចក្តីបណ្តា**

**សា និងសេចក្តីជូរចត់ ជើងគេរហ័សនឹងកំចាយឈាម នៅអស់ទាំងផ្លូវរបស់គេមានសុទ្ធតែសេចក្តីវិនាស និងសេចក្តីទុក្ខលំបាក។ គេមិនបានស្គាល់ផ្លូវសុខសាន្តសោះ ក៏គ្មានសេចក្តីកោតខ្លាចចំពោះព្រះ នៅភ្នែកគេឡើយ។" រ៉ូម 3:9-18**

**"ពីព្រោះគ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ។" រ៉ូម 3:23**

**"ព្រះយេហូវ៉ាឃើញថា ការអាក្រក់របស់មនុស្សបានចំរើនជាច្រើនឡើងនៅផែនដី ហើយអស់ទាំងគំនិតក្នុងចិត្តគេក៏សុទ្ធតែអាក្រក់ជានិច្ចដូច្នោះ។" លោកុប្បត្តិ 6:5**

ហើយម្តងទៀត "ការស្រមើស្រម៉ៃនៃចិត្តរបស់មនុស្សម្នាក់គឺវាអាក្រក់តាំងពីតូចមក។" បន្ទាប់មកពេលនេះ ពេលណាដែលយើងគិតដូច្នោះពីខ្លួនយើងមានអារម្មណ៍ដូច្នោះ បន្ទាប់មកនោះគំនិតរបស់យើងបានល្អហើយ ពីព្រោះវាស្របតាមព្រះបន្ទូលរបស់ព្រះ។

លូង់៖ ខ្ញុំនឹងមិនជឿថាចិត្តរបស់ខ្ញុំអាក្រក់អីចឹងទេ។

គ្រីស្ទាន៖ ដូច្នោះអ្នកមិនដែលមានគំនិតល្អណាមួយទាក់ទងនឹងខ្លួនអ្នកនៅក្នុងជីវិតរបស់អ្នកទេ។ តែសូមឱ្យខ្ញុំបាននិយាយតទៀត។ កាលដែលព្រះបន្ទូលផ្តល់ការជំនុំជំរះដល់ចិត្តរបស់យើង នោះព្រះបន្ទូលក៏ផ្តល់ការកាត់ទោសដល់ផ្លូវរបស់យើងដូចគ្នា។ ហើយនៅពេលដែលគំនិតនៃចិត្តរបស់យើងនិងផ្លូវប្រព្រឹត្តស្របគ្នានឹងការការទោសដែលព្រះបន្ទូលផ្តល់ឱ្យទាំងពីរ

នោះ នោះការទាំងពីរនោះល្អហើយ ដោយសារយល់ស្របទៅនឹងព្រះបន្ទូលរបស់ព្រះ។

លូង់៖ ចូរបង្ហាញអត្ថន័យរបស់អ្នកមើល។

គ្រីស្ទាន៖ ដោយសារព្រះបន្ទូលរបស់ព្រះមានបន្ទូលថាផ្លូវរបស់មនុស្សជាផ្លូវដែលវៀចវេរ មិនល្អ តែខូចអាក្រក់។ ព្រះបន្ទូលថា វាពីធម្មជាតិមកគឺនៅក្រៅពីផ្លូវល្អ ដែលពួកគេមិនបានដឹងសោះ។

"តែចំណែកមនុស្សដែលបែរទៅតាមផ្លូវខ្វិចខ្វៀនរបស់ខ្លួនវិញ នោះព្រះយេហូវ៉ាទ្រង់នឹងនាំគេចេញទៅ ជាមួយនឹងពួកអ្នកដែលប្រព្រឹត្តអំពើទុច្ចរិត។ សូមឱ្យសេចក្ដីសុខគ្របលើសាសន៍អ៊ីស្រាអែលផង។" ទំនុកដំកើង 125:5

"ផ្លូវគេសុទ្ធតែក្ងិកក្ងក់ ហើយផ្លូវច្រករបស់គេក៏ទាសចេញ។" សុភាសិត 2:15

"ដូច្នេះ តើដូចម្ដេច យើងល្អជាគេឬទេ មិនមែនទេ ដ្បិតយើងខ្ញុំបានចោទប្រកាន់រួចហើយថា ទោះទាំងសាសន៍យូដា និងសាសន៍ក្រេកផង សុទ្ធតែនៅក្រោមអំពើបាប។ ដូចមានសេចក្ដីចែងទុកមកថា គ្មានអ្នកណាសុចរិតសោះ សូម្បីតែម្នាក់ក៏គ្មានផង។ គ្មានអ្នកណាដែលយល់ គ្មានអ្នកណាដែលស្វែងរកព្រះ។ គ្រប់គ្នាបានបែរចេញ ហើយត្រឡប់ជាឥតប្រយោជន៍ទាំងអស់គ្នា គ្មានអ្នកណាដែលប្រព្រឹត្តតាមសេចក្ដីសប្បុរសសោះ តែម្នាក់ក៏គ្មានផង។ បំពង់កគេជាផ្នូរខ្មោចនៅចំហ គេប្រើអណ្ដាតគេសម្រាប់នឹងបញ្ឆោត ឯនៅបបូរមាត់គេមានសុទ្ធតែពិសពស់ហានុមាន ហើយមាត់គេមានពេញដោយសេចក្ដីបណ្ដាសា និងសេចក្ដីជូរចត់ ជើងគេរហ័សនឹងកំចាយឈាម នៅអស់ទាំងផ្លូវរបស់

**គេមានសុទ្ធតែសេចក្តីវិនាស និងសេចក្តីទុក្ខលំបាក។ គេមិនបានស្គាល់ផ្លូវសុខសាន្តសោះ ក៏គ្មានសេចក្តីកោតខ្លាចចំពោះព្រះ នៅភ្នែកគេឡើយ។" រ៉ូម 3:9-18**

ពេលនេះ នៅពេលបុរសម្នាក់នោះគិតដូច្នេះ ខ្ញុំនិយាយថា នៅពេលដែលគាត់ធ្វើត្រូវ ហើយដោយចិត្តបន្ទាបចុះក៏គិតដូច្នេះ បន្ទាប់មកគាត់មានគំនិតល្អពីផ្លូវរបស់គាត់ផ្ទាល់ ពីព្រោះគំនិតរបស់គាត់ពេលនេះយល់ស្របជាមួយនឹងការកាត់ទោសរបស់ព្រះបន្ទូលរបស់ព្រះ។

លូង់៖ តើអ្វីជាគំនិតល្អអំពីព្រះនោះ?

គ្រីស្ទាន៖ ទោះបីជា (ដូចដែលខ្ញុំនិយាយពាក់ព័ន្ធនឹងខ្លួនយើង) នៅពេលដែលគំនិតរបស់យើងពីព្រះស្របជាមួយនឹងអ្វីដែលព្រះបន្ទូលថាពីគាត់ ហើយនោះជាពេលដែលយើងគិតពីរូបអង្គទ្រង់និងលក្ខណៈរបស់ទ្រង់ ដូចដែលព្រះបន្ទូលបានបង្រៀន តែខ្ញុំមិនអាចនិយាយបានទូលំទូលាយទេពេលនេះ។ តែដើម្បីនិយាយពីទ្រង់ដោយទាក់ទងនឹងយើងថា នោះយើងមានគំនិតដែលត្រឹមត្រូវពីព្រះ នៅពេលដែលយើងគិតថាទ្រង់ស្គាល់យើងជាងដែលយើងស្គាល់ខ្លួនឯង ហើយអាចឃើញអំពើបាបនៅក្នុងយើង នៅពេលនិងកន្លែងណាដែលយើងមិនអាចឃើញនៅក្នុងខ្លួងយើងសោះ។ នៅពេលដែលយើងគិតថាទ្រង់ស្គាល់គំនិតដ៏ជ្រៅរបស់យើង និងជម្រៅចិត្តរបស់យើងទាំងអស់តែងតែបើកចំហរនៅចំពោះព្រះនេត្រទ្រង់។ ហើយនៅពេលដែលយើងគិតថាគ្រប់ទាំងសេចក្តីសុចរិតរបស់យើងនោះស្អុយរលួយ

នៅក្នុងរន្ធច្រមុះ ហើយដូច្នេះទ្រង់មិនអាចទ្រាំនឹងមើលឃើញឈរនៅចំពោះទ្រង់នៅក្នុងទំនុកចិត្តណាឡើយបើទោះជាយើងសម្ដែងមកយ៉ាងល្អបំផុតក៏ដោយ។

ល្ងង់៖ តើអ្នកគិតថាខ្ញុំល្ងង់បែបហ្នឹងដែលគិតថាព្រះមិនអាចមើលឃើញវែងឆ្ងាយជាងខ្លួនឬ? ឬថាខ្ញុំនឹងមករកព្រះដោយកិច្ចការដែលសម្ដែងយ៉ាងល្អបំផុតឬ?

គ្រីស្ទាន៖ អ្នកគិតយ៉ាងណាអំពីបញ្ហានេះ?

ល្ងង់៖ ហេតុផលនោះគឺ បើនិយាយឱ្យខ្លីទៅ ខ្ញុំគិតថាខ្ញុំត្រូវជឿដល់ព្រះគ្រីស្ទសម្រាប់ការរាប់ជាសុចរិតវិញ។

គ្រីស្ទាន៖ អ្នកគិតថាត្រូវជឿដល់ព្រះគ្រីស្ទយ៉ាងម៉េចកើត កាលដែលអ្នកមិនឃើញមានអ្វីដែលត្រូវការទ្រង់ផងនោះ! អ្នកមើលមិនឃើញជម្ងឺរបស់អ្នកទាំងដើមនិងការដែលប្រព្រឹត្តផងនោះ តែបែជាមានគំនិតបែបនេះពីខ្លួនអ្នកដែលអ្នកបានធ្វើដែលបង្ហាញយ៉ាងច្បាស់ថាអ្នកជាម្នាក់ ដែលមិនដែលមើលឃើញពីការចាំបាច់នៃសេចក្ដីសុចរិតផ្ទាល់របស់ព្រះគ្រីស្ទ ដើម្បីនឹងរាប់អ្នកជាសុចរិតនៅចំពោះព្រះឡើយ។ តើអ្នកនិយាយថា "ខ្ញុំជឿព្រះគ្រីស្ទ" បានយ៉ាងដូចម្ដេចទៅ?

ល្ងង់៖ ខ្ញុំជឿដល់ការទាំងនោះគ្រប់គ្រាន់ហើយ។

គ្រីស្ទាន៖ តើអ្នកជឿយ៉ាងម៉េចដែរ?

ល្ងង់៖ ខ្ញុំជឿថាព្រះគ្រីស្ទសុគតសម្រាប់អ្នកមានបាប ហើយថា ខ្ញុំនឹងបានរាប់ជាសុចរិតនៅចំពោះព្រះចេញពីបណ្ដាសា តាមរយៈការទទួលដោយព្រះគុណរបស់ទ្រង់នូវការស្ដាប់បង្គាប់ដល់ក្រិត្យវិន័យរបស់ទ្រង់។ ឬដូច្នេះ ព្រះគ្រីស្ទធ្វើឱ្យតួនាទីបែបសាសនារបស់ខ្ញុំឱ្យបានទទួលយកនៅចំពោះព្រះវរបិតាទ្រង់ដោយសារគុណតម្លៃនៃសេចក្ដីមេត្តារបស់ទ្រង់ នោះខ្ញុំនឹងបានរាប់ជាសុចរិត។

គ្រីស្ទាន៖ ចូរឱ្យខ្ញុំបានឆ្លើយនឹងការសារភាពនៃសេចក្ដីជំនឿរបស់អ្នកនេះ។
1. អ្នកជឿដោយសេចក្ដីជំនឿដែលនឹកស្មាន ដោយសារសេចក្ដីជំនឿនេះមិនមានរៀបរាប់នៅក្នុងព្រះបន្ទូលឡើយ។

2. អ្នកជឿដោយសេចក្ដីជំនឿខុសឆ្គង ពីព្រោះវាបានដកការរាប់ជាសុចរិតចេញពីសេចក្ដីសុចរិតផ្ទាល់របស់ព្រះគ្រីស្ទ ហើយបានលើកវាមកដាក់ជារបស់អ្នកវិញ។

3. សេចក្ដីជំនឿនេះមិនបានធ្វើឱ្យព្រះគ្រីស្ទាជាអ្នករាប់ជាសុចរិតរបស់អ្នកទេ តែដោយសារកិច្ចការរបស់អ្នកវិញ និងដោយសារខ្លួនអ្នកដោយសារកិច្ចការរបស់អ្នកធ្វើ ហើយវាជាការខុសឆ្គងហើយ។

4. ដូច្នេះ សេចក្ដីជំនឿនេះគឺបោកបញ្ឆោតទេ ហើយការនេះហើយដែលនឹងទុកឱ្យអ្នកនៅក្រោមសេចក្ដិក្រោធរបស់ព្រះនៅក្នុងថ្ងៃរបស់ព្រះដ៏មានគ្រប់អំណាចចេស្ដាផង។ ដោយសារសេចក្ដីជំនឿដែលរាប់ជាសុចរិតដាក់ព្រលឹង

(ដែលមានញាញនៃការសភាពនៃបាត់បង់របស់វាដោយសារក្រឹត្យវិន័យ) នៅលើហោះទៅរកទីជំរកនៃសេចក្ដីសុចរិតរបស់ព្រះគ្រីស្ទ ដែលសេចក្ដីសុចរិតរបស់ទ្រង់មិនមានជាកិច្ចការនៃព្រះគុណ ដែលកាត់ធ្វើសម្រាប់ការរាប់ជាសុចរិតនូវការស្ដាប់បង្គាប់របស់អ្នកឱ្យបានទទួលនៅចំពោះព្រះ។ តែការស្ដាប់បង្គាប់ផ្ទាល់ខ្លួនទៅកាន់ក្រឹត្យវិន័យនៅក្នុងការប្រព្រឹត្តនិងការរងទុក្ខសម្រាប់យើងជាអ្វីដែលទាមទារពីដៃរបស់យើង។ សេចក្ដីសុចរិតនេះ ខ្ញុំនិយាយថា ជាសេចក្ដីជំនឿពិតទទួលយក នៅក្រោមសំពត់ដែលរុំព្រលឹង ហើយដោយវាបានបង្ហាញថាមិនមានស្នាមនៅចំពោះព្រះសោះ វាត្រូវបានទទួលយក ហើយគ្មានកំហុសចេញពីការដាក់ទោសរបស់ព្រះ។

ល្ងង់៖ អ្វីហ្នឹង! តើអ្នកចង់ឱ្យយើងទុកចិត្តលើអ្វីដែលព្រះគ្រីស្ទនៅក្នុងអង្គទ្រង់បានធ្វើដោយគ្មានយើងឬយ៉ាងណា? ការយល់ស្របនេះនឹងបន្ធូបង្ហៀរនៃតណ្ហារបស់យើង ហើយបន្ទូរបន្ថយយើងឱ្យរស់នៅតាមដែលយើងចង់បាន។ ដោយសារ តើវាជាបញ្ហាអ្វីទៅថាយើងរស់យ៉ាងម៉េចនោះ ប្រសិនបើយើងនឹងបានរាប់ជាសុចរិត ដោយសារសេចក្ដីសុចរិតរបស់ព្រះគ្រីស្ទផ្ទាល់ នៅពេលដែលយើងជឿនោះ?

គ្រីស្ទាន៖ ល្ងង់ខ្លៅជាឈ្មោះរបស់អ្នកពិត ហើយអ្នកល្ងង់ដូចជាឈ្មោះរបស់អ្នកមែន។ សូម្បីតែចម្លើយរបស់អ្នកបង្ហាញនូវអ្វីដែលខ្ញុំថានេះ។ អ្នកមិនស្គាល់ថាសេចក្ដីសុចរិតដែលរាប់ជាសុចរិតថាជាអ្វី ហើយមិនដឹងពីរបៀបរក្សានូវព្រលឹងរបស់អ្នក តាមរយៈជំនឿនោះ ចេញពីសេចក្ដីក្រោធដ៏ធ្ងន់របស់ព្រះនោះ។ ហើយអ្នកមិនដឹងពីឥទ្ធិពលនៃសេចក្ដីជំនឿដែលបានសង្គ្រោះនៅក្នុងសេចក្ដីសុចរិតនេះរបស់ព្រះគ្រីស្ទ ដែលជាការឱនចុះនិងយក

ឈ្នះលើចិត្តទៅកាន់ព្រះនៅក្នុងព្រះគ្រីស្ទ ដែលស្រឡាញ់ព្រះនាមទ្រង់ ព្រះបន្ទូលទ្រង់ ផ្លូវ និងរាស្រ្តរបស់ទ្រង់ ហើយមិនដូចអ្វីអ្នកមនុស្សល្ងង់ដូចអ្នកស្រមើស្រម៉ៃឡើយ។

សង្ឃឹម៖ ចូរសួរគាត់ទៅមើល ថាតើព្រះគ្រីស្ទធ្លាប់បើសម្តែងពីស្ថានសួគ៌មកដល់គាត់ទេ។

ល្ងង់៖ អ្វីហ្នឹង! អ្នកជាមនុស្សនៃការបើកសម្តែង! ខ្ញុំជឿថាអ្នកដែលអ្នកទាំងពីរ និងអ្នកផ្សេងទៀតនិយាយអំពីបញ្ហានេះ គឺគ្រាន់តែជាផលផ្លែនៃខួរក្បាលដែលបែករាយមាយប៉ុណ្ណោះ។

សង្ឃឹម៖ ព្រះគ្រីស្ទត្រូវបានលាក់នៅក្នុងព្រះពីការយល់ដឹងពីធម្មជាតិរបស់សាច់ឈាមនោះ គឺថាទ្រង់មិនស្គាល់បានដោយមនុស្សណាដោយបានសង្គ្រោះឡើយ លើកលែងតែព្រះវរបិតាបង្ហាញទ្រង់ដល់ពួកគេ។

ល្ងង់៖ នោះជាសេចក្តីជំនឿរបស់អ្នក តែមិនមែនខ្ញុំឡើយ។ របស់ខ្ញុំវិញគឺ ខ្ញុំមិនបានសង្ស័យទេ ថាវាល្អដូចជាអ្នកឬអត់ បើទោះជាខ្ញុំមាននៅក្នុងក្បាលរបស់ខ្ញុំពីការចម្លែកៗជាច្រើនដូចអ្នកដែរ។

គ្រីស្ទាន៖ សូមឱ្យខ្ញុំបាននិយាយបន្តិច។ អ្នកមិនគួរនិយាយពីបញ្ហានេះដោយធូរៗឡើយ ដោយខ្ញុំនឹងអះអាងដោយរឹងប៉ឹងថា (សូម្បីតែគ្នាខ្ញុំក៏បានធ្វើដែរ) ថាគ្មានអ្នកណាអាចស្គាល់ព្រះគ្រីស្ទយេស៊ូវបានឡើយ តែមានតែដោយការបើកសម្តែងរបស់ព្រះវរបិតាប៉ុណ្ណោះ។ បាទ គឺសេចក្តីជំនឿផង ដែលព្រលឹង

នឹងកាន់ជាប់នឹងព្រះគ្រីស្ទ (បើវាត្រឹមត្រូវ) ត្រូវតែបាននាំមកដោយភាពអស្ចារ្យបំផុតនៃអំណាចដ៏មានគ្រប់ចេស្តារបស់ទ្រង់។

"គ្រប់សេចក្តីទាំងអស់បានប្រគល់មកខ្ញុំពីព្រះវរបិតានៃខ្ញុំ ហើយគ្មានអ្នកណាស្គាល់ព្រះរាជបុត្រាទេ មានតែព្រះវរបិតាតែ១ ក៏គ្មានអ្នកណាស្គាល់ព្រះវរបិតាដែរ មានតែព្រះរាជបុត្រាហើយនឹងអ្នកណា ដែលព្រះរាជបុត្រាសព្វព្រះហឫទ័យចង់បើកឱ្យស្គាល់ទ្រង់ផងប៉ុណ្ណោះ។" ម៉ាថាយ 11:27

"ហេតុនោះបានជាខ្ញុំប្រាប់ឱ្យអ្នករាល់គ្នាដឹងថា មិនដែលមានអ្នកណានិយាយដោយនូវព្រះវិញ្ញាណនៃព្រះថាព្រះយេស៊ូវត្រូវបណ្តាសានោះឡើយ ក៏គ្មានអ្នកណាអាចនឹងថា ព្រះយេស៊ូវទ្រង់ជាព្រះអម្ចាស់ដែរ លើកតែដោយនូវព្រះវិញ្ញាណបរិសុទ្ធប៉ុណ្ណោះ។" កូរិនថូសទី១ 12:3

"ដើម្បីឱ្យភ្នែកចិត្តរបស់អ្នករាល់គ្នាបានភ្លឺឡើង ប្រយោជន៍ឱ្យបានដឹងថា ដែលទ្រង់ហៅអ្នករាល់គ្នា នោះមានសេចក្តីសង្ឃឹមជាយ៉ាងណា ហើយថា សិរីល្អដ៏ប្រសើរក្រៃលែងនៃមរដកទ្រង់ ក្នុងពួកបរិសុទ្ធជាយ៉ាងណាផង។" អេភេសូ 1:18

កិច្ចការនៃជំនឿដែលខ្ញុំយល់ថាវាល្ងីល្ងើ អ្នកមិនដែលដឹងសោះ។ ចូរភ្ញាក់ខ្លួនឡើង ហើយមើលទៅកាន់សេចក្តីអាក្រក់វេទនារបស់អ្នកទៅ ហើយបោះទៅកាន់ព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ហើយដោយសេចក្តីសុចរិតរបស់ទ្រង់

ដែលជាសេចក្តីសុចរិតរបស់ព្រះ (ដោយសារទ្រង់ផ្ទាល់ជាព្រះ) នោះអ្នកនឹងត្រូវបានដោះឱ្យរួចពីការដាក់ទោសបាប។

ល្ងង់៖ អ្នកទៅដូចជាលឿនពេកហើយ ខ្ញុំមិនអាចតាមទាន់អ្នកទេ។ អ្នកបន្តទៅមុនទៀតចុះ ហើយខ្ញុំនឹងសម្រាកមួយភ្លែតនៅក្រោយ។

បន្ទាប់មកពួកគេនិយាយថា៖

‶ពិតណាស់ ល្ងង់អើយ តើអ្នកនៅតែល្ងង់ដដែលឬយ៉ាងណា ដែលអ្នកបានមើលស្រាលដល់យោបល់ល្អៗដែលផ្តល់មកអ្នកដប់ដងរួចទៅហើយនោះ? ហើយប្រសិនបើអ្នកមិនព្រមទទួលយកវា អ្នកត្រូវដឹងថាការអាក្រក់អ្វីដែលអ្នកបានធ្វើដូច្នេះ។ ចូរចង់ចាំចុះមនុស្សអើយ ឱ្យទាន់ពេល អឺតមើល កុំភ័យខ្លាចឡើយ។ បើដើរតាមយោបល់ល្អបានត្រឹមត្រូវនឹងបានសង្គ្រោះ ដូច្នេះចូរស្តាប់ចុះ តែប្រសិនបើអ្នកមើលស្រាលវា អ្នកនឹងក្លាយជាមនុស្សបរាជ័យ ឱល្ងង់អើយ ខ្ញុំហានធានាជាមួយអ្នក។″

ដូច្នេះគ្រីស្ទានបានណែនាំខ្លួនរបស់គាត់ដល់គ្នារបស់គាត់ដូច្នេះ៖

គ្រីស្ទាន៖ អីចឹង ចូរមកមិត្តពេញដោយសង្ឃឹមល្អរបស់ខ្ញុំអើយ ខ្ញុំយល់ថាអ្នកនិងខ្ញុំត្រូវតែដើរទៅតែពីរនាក់យើងម្តងទៀតហើយ។

## សេចក្ដីកោតខ្លាចដែលត្រឹមត្រូវ

ដូច្នេះខ្ញុំបានឃើញនៅក្នុងសុបិនរបស់ខ្ញុំថាពួកគេបានដើរទៅមុខ ហើយល្ងង់បានដើរមកដោយលោតកញ្ឆែងតាមក្រោយ។ បន្ទាប់មកគ្រីស្ទាននិយាយទៅកាន់គ្នារបស់គាត់ថា "វាបានធ្វើឱ្យខ្ញុំអាណិតដល់បុរសកំសត់ម្នាក់នេះណាស់ វាពិតជាអាក្រក់ដល់គាត់ហើយដល់ទីបំផុត។"

សង្ឃឹម៖ មានមនុស្សដូច្នេះយ៉ាងសម្បូរបែបនៅក្នុងក្រុងរបស់យើង ទាំងគ្រួសារ ពិតណាស់ គ្រប់ពេញតាមផ្លូវទាំងអស់ (ហើយទាំងពួកអ្នកធ្វើធម្មយាត្រាផងដែរ)។ ហើយប្រសិនបើមានច្រើននៅចំណោករបស់យើង តើអ្នកគិតថានឹងមានប៉ុន្មាននៅកន្លែងដែលគាត់កើតនោះ?

គ្រីស្ទាន៖ ពិតណាស់ព្រះបន្ទូលនិយាយដូច្នេះថា "គេបានធ្វើឱ្យភ្នែករបស់ពួកគេខ្វាក់ ដើម្បីកុំឱ្យពួកគេមើលឃើញ។" តែពេលនេះពួកគេមានតែពីរនាក់ តើអ្នកគិតដូចម្ដេចពីមនុស្សបែបនោះ? តើអ្នកគិតថាពួកគេពេលខ្លះដឹងពីអំពើបាបអីដូច្នោះ ចុងក្រោយ ក៏ភ័យខ្លាចដល់សភាពគ្រោះថ្នាក់របស់ពួកគេទេឬអី?

សង្ឃឹម៖ ទេ សូមអ្នកឆ្លើយសំណួរនេះដោយខ្លួនអ្នកទៅ ព្រោះអ្នកជាមនុស្សមានវ័យចាស់ជាង។

គ្រីស្ទាន៖ បន្ទាប់មកខ្ញុំនិយាយថាជួនកាល (តាមដែលខ្ញុំគិត) ពួកគេអាចគិតបាន តែពួកគេធ្វើជាមិនដឹងពីធម្មជាតិមក មិនយល់ថាការយល់ដឹងបែបនោះសំដៅដល់ការល្អដល់ពួកគេនោះទេ។ ហើយដូច្នេះពួកគេខំស្វែងរកដើម្បីនឹង

គ្របបាំងការទាំងនោះយ៉ាងខ្លាំង ហើយបន្ទបញ្ចោរខ្លួនពួកគេតាមផ្លូវនៃចិត្ត របស់ពួកគេដោយសន្ទត់។

សង្ឃឹមៈ ខ្ញុំពិតជាជឿដូចអ្វីដែលអ្នកនិយាយមែន ថាសេចក្តីភ័យខ្លាចសំដៅដល់ការល្អដល់មនុស្សមែន ហើយដែលធ្វើឱ្យពួកគេបានត្រឹមត្រូវនៅពេលចាប់ផ្តើមរបស់ពួកគេដែលមកកាន់ការធ្វើធម្មយាត្រា។

គ្រីស្ទានៈ គ្មានការអ្វីដែលត្រូវសង្ស័យនោះទេថាវាពិតជាត្រឹមឬអត់នោះទេ។ ដោយសារព្រះបន្ទូលថា "សេចក្តីកោតខ្លាចដល់ព្រះអម្ចាស់ជាដើមចមនៃប្រាជ្ញា។"

**"រួចមានបន្ទូលដល់មនុស្សយើងថា មើល សេចក្តីកោតខ្លាចដល់ព្រះអម្ចាស់ នោះហើយជាប្រាជ្ញា ហើយដែលថយឆ្ងាយពីការអាក្រក់នោះឯងជាយោបល់។" យ៉ូប 28:28**

**"ឯសេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា នោះជាដើមចមនៃប្រាជ្ញា អស់អ្នកដែលកាន់តាម នោះមានយោបល់ល្អ សេចក្តីសរសើរនៃទ្រង់ជាប់នៅអស់កល្បជានិច្ច។" ទំនុកដំកើង 111:10**

**"សេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា នោះជាដើមចមនៃដំរិះ តែមនុស្សឥតបើគិត គេមើលងាយប្រាជ្ញា និងសេចក្តីប្រៀនប្រដៅវិញ។" សុភាសិត 1:7**

**"សេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ាជាដើមចមនៃប្រាជ្ញា ហើយការដែលស្គាល់ដល់ព្រះដ៏បរិសុទ្ធ នោះគឺជាយោបល់។" សុភាសិត 9:10**

សង្ឃឹមៈ តើអ្នកនឹងបកស្រាយបីសេចក្ដីកោតខ្លាចដែលត្រឹមត្រូវយ៉ាងដូចម្ដេចទៅ?

គ្រីស្ទានៈ សេចក្ដីភ័យខ្លាចដែលពិតឬត្រឹមត្រូវ ត្រូវបានបង្ហាញមកដោយការបីយ៉ាង

1. ដោយការលេចមករបស់វា។ វាបង្កើតឱ្យមានការយល់ដឹងដែលសង្គ្រោះពីអំពើបាប។

2. វាបណ្ដេញព្រលឹងឱ្យកាន់ជាប់ទៅនឹងព្រះគ្រីស្ទដើម្បីទទួលបានការសង្គ្រោះ។

3. វាបង្កើតនិងនៅបន្តនៅក្នុងព្រលឹងនូវការគោរពដល់ព្រះយ៉ាងខ្លាំង ដល់ព្រះបន្ទូលទ្រង់ និងផ្លូវរបស់ទ្រង់ផង។ រក្សាវាឱ្យបានល្អ ហើយធ្វើឱ្យវាខ្លាចនឹងបែរចេញពីការនោះ ការបែរទៅខាងស្ដាំឬខាងឆ្វេង ទៅកាន់ការណាមួយដែលនឹងមិនសរសើរដល់ព្រះ ដែលបំបែកសេចក្ដីសុខសាន្ដរបស់វា ដែលធ្វើឱ្យព្រះវិញ្ញាណពិបាកព្រះទ័យ ឬការដែលធ្វើឱ្យសត្រូវនិយាយដោយរិះគន់នោះឡើយ។

សង្ឃឹមៈ និយាយបានល្អណាស់។ ខ្ញុំជឿថាអ្នកបាននិយាយការពិត។ តើយើងពេលនេះស្ទើរតែឆ្លងផុតទឹកដីដែលមានមន្ដអាគមន៍ហើយមែនទេ?

គ្រីស្ទានៈ ហេតុអ្វីទៅ តើអ្នកមិនការនឿយណាយនឹងការជជែកគ្នានេះហើយមែនទេ?

សង្ឃឹមៈ ទេ តែខ្ញុំចង់ដឹងថាយើងកំពុងនៅទីណា។

គ្រីស្នានៈ យើងត្រូវទៅមិនលើសពីពីរយោជន៍ទៀតទេ។ តែចូរយើងត្រឡប់មករឿងរបស់យើងវិញ។ ពេលនេះល្ងង់មិនបានដឹងថាការញុះញង់ដូចនេះមានបំណងនឹងធ្វើឱ្យគេភ័យខ្លាច ហើយជាការល្អសម្រាប់គេនោះទេ ហើយដូច្នេះគេស្វែងរកនឹងបំបាត់វាចេញ។

សង្ឃឹមៈ តើពួកគេរកនឹងបំបាត់ការទាំងនោះដោយរបៀបណាទៅ?

គ្រីស្នានៈ 1. ពួកគេគិតថាសេចក្ដីកោតខ្លាចទាំងនោះត្រូវបាននាំមកដោយអារក្ស (បើទោះជាការពិតទៅវាមកពីព្រះទេ)។ ហើយដោយគិតដូច្នេះ ពួកគេបានបដិសេធការនោះ ដូចជាការដែលនាំឱ្យពួកគេបរាជ័យអីចឹង។
2. ពួកគេក៏គិតថាសេចក្ដីកោតខ្លាចទាំងនេះមានបំណងបង្ខូចដល់សេចក្ដីជំនឿរបស់ពួកគេ (នៅពេលដែលមនុស្សកំសត់ដូចជាពួកគេ ថាពួកគេមិនមានអ្វីទាំងអស់) ហើយដូច្នេះពួកគេបានធ្វើឱ្យចិត្តរបស់ពួកគេរឹងឡើងទាស់នឹងការភ័យខ្លាចនោះ។
3. ពួកគេសន្មត់ថាពួកគេមិនត្រូវខ្លាចនោះទេ ហើយដូច្នេះជំនួសឱ្យការភ័យខ្លាច បំភ្លៃដោយទំនុកចិត្តតាមការសន្មត់។

4. ពួកគេឃើញថាសេចក្ដីកោតខ្លាចទាំងនេះមានបំណងយកចេញពីពួកគេនូវ សេចក្ដីបរិសុទ្ធផ្ទាល់ខ្លួនចាស់ដែលគួរអាណិតរបស់ពួកគេ ហើយដូច្នេះពួកគេក៏បដិសេធការភ័យខ្លាចទាំងនោះដោយកម្លាំងរបស់ពួកគេ។ សង្ឃឹមៈ ខ្ញុំដឹងការអ្វីមួយពីការនោះដោយខ្លួនខ្ញុំផ្ទាល់ ដោយសារពីមុនខ្ញុំបានដឹងខ្លួនខ្ញុំ ខ្ញុំក៏ធ្លាប់បែបនោះដែរ។

គ្រឡប់ក្រោយ

គ្រីស្ទាន៖ អឺចឹង យើងនឹងចាកចេញពីអ្នកជិតខាងល្ងង់របស់យើងពេលនេះ ឱ្យគាត់នៅតែឯងចុះ ហើយនឹងនិយាយពីសំណួរដែលមានប្រយោជន៍មួយទៀតវិញ។

សង្ឃឹម៖ ចេញពីចិត្តរបស់ខ្ញុំ នោះអ្នកគួរតែចាប់ផ្តើមចុះ។

គ្រីស្ទាន៖ អឺចឹង តើអ្នកមិនបានដឹងទេឬ កាលពីប្រហែលជាដប់ឆ្នាំមុន ម្នាក់ឈ្មោះបណ្តោះអាសន្ននៅបំបន់របស់អ្នក ជាម្នាក់ដែលខ្លាំងពូកែនៅក្នុងសាសនានៅក្នុងតំបន់នោះ?

សង្ឃឹម៖ ស្គាល់គាត់? បាទ គាត់ស្នាក់នៅក្នុងទីខ្វះព្រះគុណ ជាក្រុងមួយដែលនៅប្រហែលពីរយោជន៍ចេញពីទីស្មោះត្រង់ ហើយគាត់ស្នាក់នៅក្បែរម្នាក់ឈ្មោះថាបែរក្រោយ។

គ្រីស្ទាន៖ ត្រូវហើយ គាត់បានស្នាក់នៅក្រោមដំបូលផ្ទះតែមួយជាមួយគាត់។ ដូច្នេះបុរសនោះមានការភ្ញាក់ដឹងខ្លួនយ៉ាងខ្លាំងម្តងដែរ។ ខ្ញុំជឿថាពេលនោះគាត់មានការមើលឃើញខ្លះនូវអំពើបាបរបស់គាត់ ហើយព្រមទាំងឈ្នួលរបស់វាផង។

សង្ឃឹម៖ ខ្ញុំគិតដូចជាអ្នកដែរ ដោយសារ (ផ្ទះរបស់ខ្ញុំនៅមិនឆ្ងាយជាងបីយោជន៍ពីគាត់ទេ) ជាញឹកញាប់គាត់តែងតែមករកខ្ញុំ ហើយមកដោយទឹកភ្នែកយ៉ាងខ្លាំងផង។ ពិតណាស់ ខ្ញុំពិតជាអាណិតបុរសនោះណាស់ ហើយ

មិនមែនគ្មានសង្ឃឹមសោះដល់គាត់នោះឡើយ តែគេនឹងដឹងថា មិនមែនគ្រប់គ្នាដែលស្រែកថា "ព្រះអម្ចាស់ ព្រះអម្ចាស់!"

គ្រីស្ទាន៖ គាត់បានប្រាប់ខ្ញុំម្តង ថាគាត់បានសម្រេចនឹងធ្វើធម្មយាត្រាដូចដែលយើងធ្វើនៅពេលនេះដែរ។ តែរំពេចនោះគាត់បានស្គាល់ម្នាក់ឈ្មោះថាសង្គ្រោះខ្លួនឯង ហើយបន្ទាប់មកគាត់បានក្លាយជាមនុស្សចម្លែកដល់ខ្ញុំ។

សង្ឃឹម៖ ពេលនេះ ក្នុងកាលដែលយើងជជែកពីគាត់ ចូរយើងសួររកហេតុផលដែលគាត់បានបែរចេញភ្លាមៗនិងអ្វីផ្សេងទៀតនោះ។

គ្រីស្ទាន៖ វាពិតជាមានប្រយោជន៍ណាស់ តែសូមអ្នកធ្វើការចាប់ផ្តើមចុះ។

សង្ឃឹម៖ អីចឹង មានហេតុផលបួនយ៉ាងនៅក្នុងការកាត់ស្រាយរបស់ខ្ញុំពីការនោះ

1. បើទោះជាសតិរបស់បុរសនោះមានការភ្ញាក់ដឹងខ្លួនក៏ដោយ តែគំនិតរបស់គេមិនបានផ្លាស់ប្រែឡើយ។ ដូច្នេះ នៅពេលដែលអំណាចនៃកំហុសត្រូវរសាយបាត់ទៅ ដែលជាអ្វីធ្វើឱ្យគេថយចេញពីសាសនា។ ដូច្នេះពួកគេក៏ត្រឡប់ទៅរកផ្លូវរបស់គេម្តងទៀតដោយខ្លួនឯង។ យើងទាំងបានឃើញថាឆ្កែក៏ធុញនឹងអ្វីដែលវាស៊ីដែរ កាលណាដែលជម្ងឺរបស់គាត់បានឈ្នះនោះ វានឹងក្អួតនិងបោះចោលទាំងអស់ ហើយមិនមែនគេធ្វើដូច្នេះដោយគំនិតដែលមានសិរីភាពនោះទេ (ប្រសិនបើយើងនឹងនិយាយថាឆ្កែមានគំនិត) តែដោយសារ

វាធ្វើឱ្យមានបញ្ហាដល់ក្រពះរបស់វា។ តែពេលនេះ នៅពេលដែលក្រពះរបស់វាលែងឈឺ ហើយវាស្រួលបួលឡើងនោះ សេចក្តីប៉ងប្រាថ្នារបស់វាមិនដាច់ចេញពីកំអួតរបស់វាឡើយ វាក៏ត្រឡប់ក្រោយរួចលិឌកំអួតនោះវិញ។ ហើយដូច្នេះវាត្រូវបានសរសេរមកពិតមែនថា "ឆ្កែត្រឡប់ទៅរកកំអួតរបស់វាម្តងទៀត"។

**"តែមានការកើតមកដល់គេ ដូចជាពាក្យទំនៀមពិតដែលថា ឆ្កែបានត្រឡប់ទៅស៊ីកំអួតវា ឯជ្រូកញីដែលគេលាងស្អាតហើយ បានទៅននៀលនៅក្នុងខ្លាចវិញ។" ពេត្រុសទី២ 2:22**

ការនេះ ខ្ញុំនិយាយថា ពិតជាក្តៅណាស់សម្រាប់ស្ថានសួគ៌ ដោយសីលធម៌នៃញាណតែមួយមុខនិងសេចក្តីភ័យខ្លាចនៃការធ្វើទុក្ខនៃស្ថាននរក ដូចជាញាណនៃស្ថាននរករបស់ពួកគេនមិងសេចក្តីកោតខ្លាចនៃការកាត់ទោសធ្វើឱ្យបារម្ភនិងត្រជាក់ទៅ ដូច្នេះសេចក្តីប៉ងប្រាថ្នារបស់ពួកគេដែលចង់បានស្ថានសួគ៌និងសេចក្តីសង្គ្រោះក៏ទៅជាត្រជាក់ដែរ។ ដូច្នេះវាក៏កន្លងបាត់ទៅថានៅពេលដែលកំហុសរបស់ពួកគេនិងភាពភ័យខ្លាចបានកន្លងបាត់ទៅសេចក្តីប៉ងប្រាថ្នារបស់ពួកគេដែលចង់បានស្ថានសួគ៌និងសុភមង្គលក៏ស្លាប់ហើយពួកគេត្រឡប់ទៅរកផ្លូវរបស់ពួកគេវិញម្តងទៀត។

2. ហេតុផលមួយទៀតគឺ ពួកគេមានការភ័យខ្លាចតាមគេតាមឯងដោយគ្មានការពិចារណាដែលធ្វើជាមេលើពួកគេ។ ពេលនេះខ្ញុំនិយាយពីសេចក្តីកោត

ខ្លាចដែលពួកគេមានពីមនុស្ស "សេចក្ដីភ័យខ្លាចដល់មនុស្សនោះជាអន្ទាក់។
"

**"ការដែលខ្លាចចំពោះមនុស្ស នោះនាំឱ្យជាប់អន្ទាក់ តែអ្នកណាដែលទុកចិត្ត ដល់ព្រះយេហូវ៉ាពិត នោះនឹងបានសុខវិញ។" សុភាសិត 29:25**

ដូច្នេះ បើទោះជាពួកគេហាក់ដូចជាក្តៅចង់បានស្ថានសួគ៌ ដរាបណាដែលអណ្តាតភ្លើងនៃស្ថាននរកនៅក្បែរត្រចៀករបស់ពួកគេ តែនៅពេលដែលសេចក្តីភ័យខ្លាចនោះបានកន្លងផុតទៅបន្តិចទៅ ពួកគេក៏បាននាំខ្លួនទៅរកគំនិតទីពីរ។ និយាយទៅថា វាល្អដែលឆ្លាតវៃ ហើយមិនរត់នោះ (ដោយសារពួកគេមិនដឹងថាជាអ្វី) ការប្រថុយប្រថាននឹងការបាត់បង់ទាំងអស់ ឬយ៉ាងហោចណាស់ពីការដែលនាំខ្លួនរបស់ពួកគេទៅក្នុងបញ្ហាដែលគេមិនផុតនិងមិនចាំបាច់នោះ ហើយដូច្នេះពួកគេបានធ្លាក់ចូលទៅជាមួយនឹងលោកិយម្តងទៀតទៅ។

3. សេចក្តីអាម៉ាសដែលចូលទៅក្នុងសេចក្តីកុហករបស់សាសនាក៏ជាការរារាំងនៅផ្លូវរបស់ពួកគេដែរ។ ពួកគេពេញដោយអំណួតនិងឆ្មើងឆ្មៃ ហើយសាសនានៅក្នុងភ្នែករបស់ពួកគេវាទាបថោកនិងគួរឱ្យអាម៉ាស់ណាស់។ ដូច្នេះ នៅពេលដែលពួកគេបាត់នូវអារម្មណ៍ពីស្ថាននរកនិងសេចក្តីក្រោធដែលនឹងត្រូវមក ពួកគេក៏ត្រឡប់ទៅរកផ្លូវពីដើមរបស់ពួកគេវិញ។

4. កំហុស និងការដែលសញ្ជឹងគិតពីសេចក្តីភ័យខ្លាចធ្វើឱ្យពួកគេមានទុក្ខ

លំបាកជាខ្លាំង។ ពួកគេមិនចូលចិត្តមើលឃើញនូវសេចក្តីលំបាកវេទនារបស់ពួកគេមុនពេលដែលវាមកដល់នោះឡើយ។ បើទោះជានូវរូបភាពដំបូងរបស់វាក៏ដោយ ប្រសិនបើពួកគេចូលចិត្តរូបភាពដូច្នោះ នោះពួកគេនឹងបានហោះទៅកន្លែងដែលពួកសុចរិតនឹងហោះទៅដែរហើយនឹងមានសុវត្ថិភាព។ តែដោយសារតែពួកគេធ្វើដូចដែលអ្វីដែលខ្ញុំបានលើកមកពីមុននោះ ទាំងបានបដិសេធនូវគំនិតដែលមានកំហុសនិងការភ័យខ្លាចផង។ ដូច្នេះ នៅរំពេចណាដែលពួកគេរួចផុតពីការភ្ញាក់ខ្លួនអំពីសេចក្តីភ័យខ្លាចនិងសេចក្តីក្រោធរបស់ព្រះនោះ ពួកគេក៏ធ្វើឱ្យចិត្តរបស់ពួកគេរឹងឡើងដោយអំណរផង ហើយក៏ជ្រើសរើសយកផ្លូវណាដែលនឹងធ្វើឱ្យចិត្តរបស់ពួកគេកាន់តែរឹងឡើងផង។

គ្រីស្ទាន៖ អ្នកទៅជិតដល់នូវជំនួញនោះហើយ ដោយសារបាតនៃការទាំងអស់នោះគឺជា ការចង់បានការផ្លាស់ប្តូរនៅក្នុងគំនិតនិងបំណងរបស់ពួកគេ។ ហើយដូច្នេះពួកគេប្រៀបដូចជាអ្នកទោសដែលឈរនៅចំពោះចៅក្រមដែរ។ គាត់រំជើបរំជួលហើយភ័យញ័រ ហើយមើលទៅដូចជាធ្វើការលន់តួបាបចេញពីចិត្តផង។ តែបាតនៃការទាំងអស់នោះគឺ សេចក្តីភ័យខ្លាចដល់បង្ហៀរ មិនមែនដល់ទិសដៅនៃទោសកំហុសនោះឡើយ ដូចជាបង្ហាញមកច្បាស់ហើយដោយសារ ចូរឱ្យមនុស្សនេះមានសេរីភាព ហើយគាត់នឹងក្លាយជាចោរហើយជាមនុស្សចង្រៃដដែល តែបើសិនជាគំនិតរបស់គាត់បានផ្លាស់ប្តូរវិញនោះគាត់មិនមិនដូច្នោះឡើយ។

សង្ឃឹម៖ ពេលនេះខ្ញុំបានបង្ហាញអ្នកពីហេតុផលនៃការបែរត្រឡប់ទៅវិញដែលអ្នកបានបង្ហាញពីបែបបទនោះប្រាប់ដល់ខ្ញុំ

គ្រីស្ទានៈ ដូច្នេះខ្ញុំនឹងបង្ហាញប្រាប់អ្នកដោយពេញចិត្ត
1. ពួកគេបានទាញយកគំនិតទាំងអស់របស់ពួកគេចេញមក ពីការដែកពួកគេអាចចងចាំពីព្រះ ពីសេចក្តីស្លាប់ និងការកាត់ទោសដែលនឹងត្រូវមកដល់។

2. បន្ទាប់មកពួកគេបានបោះចោលដោយកម្រិតនៃតួនាទីផ្ទាល់ខ្លួន ដូចជាការអធិស្ឋាននៅក្នុងបន្ទប់បិទជិត ការដាក់កំហិតដល់តណ្ហារបស់ពួកគេ ការមើល សេចក្តីទុក្ខសោកដោយបាប និងការបែបនោះ។

3. បន្ទាប់មកពួកគេបានគេចចេញពីបក្សពួករបស់គ្រីស្ទានដែលរស់រវើកនិងកក់ក្តៅ។

4. បន្ទាប់មកទៀតពួកគេចាប់ផ្តើមទៅជាត្រជាក់នៅក្នុងតួនាទីជាសាធារណៈ ដូចជា ការស្តាប់ ការអាន ការជួបជុំដែលគោរពកោតខ្លាចដល់ព្រះ និងការបែបដូចនោះ។

5. បន្ទាប់មកពួកគេចាប់ផ្តើមបង្កើតប្រហោង ដូចដែលយើងនិយាយថា វាមាននៅក្នុងអាវក្រៅរបស់អ្នកគោរពកោតខ្លាចព្រះមួយចំនួន ហើយដោយបែបអាក្រក់ផង ដែលពួកគេអាចនឹងមានពណ៌ស្រដៀងនោះ ដើម្បីបោះបង់ចោលនូវសាសនា (ដោយសារភាពកំសោយមួយចំនួនដែលពួកគេផ្តុំឡើងនៅក្នុងពួកគេ) នៅខាងក្រោយខ្នងរបស់ពួកគេ។

6. បន្ទាប់មកពួកគេចាប់ផ្តើមស្តាប់តាម និងចូលខ្លួនជាមួយមនុស្សខាងសាច់ឈាម ធូររលុង និងព្រៃផ្សៃ។

7. បន្ទាប់មកពួកគេទុកឱកាសដល់គំនិតខាងសាច់ឈាមនិងឃោឃៅដោយសំងាត់។ ហើយពួកគេរីករាយប្រសិនបើពួកគេអាចឃើញការដូច្នេះនៅក្នុងអ្នកដែលត្រូវបានរាប់ថាស្មោះត្រង់ នោះពួកគេអាចនឹងធ្វើវាដោយក្លាហានតាមរយៈគំរូរបស់ពួកគេ។

8. បន្ទាប់ពីនេះពួកគេចាប់ផ្តើមប្រឡែងលេងជាមួយនឹងបាបបន្តិចបន្តួចដោយបើកចំហរ។

9. ហើយបន្ទាប់មក ក៏ត្រូវធ្វើចិត្តឱ្យរឹងឡើង ពួកគេក៏បង្ហាញរូបរាងពិតរបស់ពួកគេចេញមក។ ដូច្នេះ ដោយត្រូវបានបោះទម្លាក់ម្តងទៀតចូលទៅក្នុងជង្ហុកនៃសេចក្តីវេទនា លើកលែងតែការអស្ចារ្យនៃព្រះគុណទប់ស្កាត់វា នោះពួកគេនឹងត្រូវវិនាសអស់កល្បជានិច្ចនៅក្នុងសេចក្តីបញ្ឆោតរបស់ពួកគេផ្ទាល់។

## ប្រទេសនៃអ្នកដែលមានប្ដី

ពេលនេះ ខ្ញុំបានឃើញនៅក្នុងសុបិនរបស់ខ្ញុំថា មកដល់ពេលនេះ អ្នកធ្វើធម្មយាត្រាបានចេញផុតពីទឹកដីដែលមានមន្តអាគមន៍ ហើយកំពុងតែចូលទៅក្នុងប្រទេសនៃអ្នកមានប្ដី។

**"ឯងមិនត្រូវគេហៅថា ទីក្រុងចោលបង់ ហើយដីឯងក៏មិនត្រូវហៅថា ទីស្ងាត់ជ្រងំទៀតឡើយ គឺឯងនឹងត្រូវហៅថា ទីស្រឡាញ់ ហើយដីរបស់ឯងថាជាអ្នកមានប្ដីវិញ ពីព្រោះព្រះយេហូវ៉ាទ្រង់មានសេចក្ដីរីករាយចំពោះឯង ហើយដីឯងនឹងបានរៀបការ" អេសាយ 62:4**

ដែលខ្យល់របស់ពួកគេផ្អែមនិងគួរជាទីពេញចិត្តណាស់។ ហើយផ្លូវដម្រង់កាត់តាមនោះតែម្ដង នោះពួកគេក៏បានកំសាន្តចិត្តរបស់ពួកគេនៅទីនោះមួយគ្រាផងដែរ។ ហើយនៅទីនេះ ពួកគេបានឮសម្លេងបក្សីយំបន្តរហូត ហើយបានឃើញផ្ការាល់ថ្ងៃលេចមកនៅក្នុងផែនដី ហើយបានឮសម្លេងរបស់សត្វអណ្ដើកនៅក្នុងទឹកដីនោះផងដែរ។

**"ស្ងួនសំឡាញ់របស់ខ្ញុំបានមានព្រះបន្ទូលនឹងខ្ញុំថា មាសសំឡាញ់អើយ ចូរក្រោកឡើង ស្រស់ប្រិមប្រិយអើយ ចូរចេញមក។ ដ្បិតមើល រដូវរងាកន្លងទៅហើយ ភ្លៀងក៏រាំងស្រឡះហើយដែរ។ ផ្កាទាំងប៉ុន្មានកំពុងតែលេចឡើងនៅផែនដី ពេលដែលសត្វហើរយំកញ្ជ្រៀវបានមកដល់ ក៏ឮសំឡេងលលកនៅក្នុងស្រុកយើងហើយ" ចំរៀងសាឡូម៉ូន 2:10-12**

នៅប្រទេសនេះ ព្រះអាទិត្យចែងចាំងទាំងយប់ទាំងថ្ងៃ ដោយសារវានៅខាងលើជ្រលងនៃម្លប់នៃសេចក្ដីស្លាប់ ហើយវាចេញផុតពីកណ្ដាប់ដៃរបស់យក្សនៃសេចក្ដីអស់សង្ឃឹម ហើយពួកគេមិនអាចមើលឃើញវិមាននៃការសង្ស័យពីកន្លែងនេះឃើញឡើយ។ នៅទីនេះពួកគេមើលឃើញទីក្រុងដែលពួកគេកំពុងតែធ្វើដំណើរទៅ ហើយទីនេះពួកគេក៏បានជួបជាមួយនឹងអ្នកស្រុកមួយចំនួននៃទីក្រុងនោះ ដោយសារនៅលើទឹកដីនេះមានមនុស្សដែលភ្លឺចែងចាំងតែងតែដើរកាត់ ដោយសារវានៅក្នុងព្រំប្រទល់នៃស្ថានសួគ៌។ នៅក្នុងទឹកដីនេះហើយ ដែលកិច្ចសន្យារវាងកូនក្រមុំនិងកូនកំលោះត្រូវបានធ្វើជាថ្មីឡើងវិញ។ ហើយនៅទីនេះ "កាលដែលកូនកម្លោះរីករាយនឹងកូនក្រមុំរបស់ខ្លួនដូចដែលព្រះរបស់ពួកគេរីករាយនឹងពួកគេដែរ។" នៅទីនេះពួកគេមិនត្រូវការពោតនិងស្រាទំពាំងបាយជូរទៀតឡើយ ដោយសារនៅលើទឹកដីនេះពួកគេបានជួបនឹងការបរិបូរទៅដោយរបស់ដែលពួកគេបានស្វែងរកហើយក្នុងការធ្វើធម្មយាត្រា។ នៅទីនេះពួកគេបានឮសម្លេងចេញពីទីក្រុងមក សម្លេងឮៗនិយាយថា "ចូរនិយាយទៅកាន់កូនស្រីរបស់ស៊ីយ៉ូន មើលទៅ សេចក្ដីសង្គ្រោះរបស់អ្នកមកដល់ហើយ មើលទៅរង្វាន់របស់គាត់នៅក្នុងជាមួយគាត់ហើយ។" នៅទីនេះ គ្រប់ទាំងអ្នកស្រុកទាំងអស់នៃប្រទេសនោះហៅពួកគេថា "រាស្ត្របរិសុទ្ធ ពួកដែលត្រូវបានរំដោះរួចរបស់ព្រះអម្ចាស់។" និងការផ្សេងៗទៀត។

"ឯងមិនត្រូវគេហៅថា ទីក្រុងចោលបង់ ហើយដីឯងក៏មិនត្រូវហៅថា ទីស្ងាត់ជ្រងំទៀតឡើយ គឺឯងនឹងត្រូវហៅថា ទីស្រឡាញ់ ហើយដីរបស់ឯងថាជាអ្នក

មានប្ដីវិញ ពីព្រោះព្រះយេហូវ៉ាទ្រង់មានសេចក្ដីរីករាយចំពោះឯង ហើយដីឯង នឹងបានរៀបការ។ ដ្បិតដែលមនុស្សកំលោះយកស្រីក្រមុំធ្វើជាប្រពន្ធយ៉ាង ណា នោះពួកកូនប្រុសៗរបស់ឯងនឹងមករួមនឹងឯងយ៉ាងនោះដែរ ហើយ ដែលប្ដីថ្មោងថ្មីមានចិត្តរីករាយចំពោះប្រពន្ធយ៉ាងណា នោះព្រះនៃឯងនឹងមាន សេចក្ដីរីករាយចំពោះឯងយ៉ាងនោះដែរ។ ឱក្រុងយេរូសាឡឹមអើយ អញបាន ដាក់ពួកយាមល្បាតនៅលើកំផែងឯងហើយ គេនឹងមិននៅមាត់ស្ងៀម ទោះ យប់ ឬថ្ងៃផង ឯងរាល់គ្នាដែលជាអ្នករំឭកព្រះយេហូវ៉ាអើយ កុំឲ្យនៅស្ងៀម ឡើយ។ ហើយកុំឲ្យទ្រង់នៅទំនេរឲ្យសោះ ដរាបដល់ទ្រង់បានតាំងក្រុងយេរូ សាឡឹមឡើង ឲ្យជាទីសរសើរនៅលើផែនដី។ ព្រះយេហូវ៉ាទ្រង់បានស្បថ ដោយព្រះហស្តស្តាំទ្រង់ ហើយដោយព្រះពាហុដ៏មានឥទ្ធិឫទ្ធិរបស់ទ្រង់ថា ពិតប្រាកដជាអញនឹងមិនឲ្យស្រូវរបស់ឯងទៅធ្វើជាអាហារដល់ពួកខ្មាំងសត្រូវ ឯងទៀត ហើយពួកសាសន៍ដទៃនឹងមិនផឹកទឹកទំពាំងបាយជូរដែលឯងបានខំ ធ្វើទៀតឡើយ។ គឺពួកអ្នកដែលបានច្រូតផលនោះនឹងស៊ីវិញ ហើយគេនឹង សរសើរដល់ព្រះយេហូវ៉ា ឯពួកអ្នកដែលបានប្រមូលផ្លែនោះ គេនឹងផឹកនៅ ក្នុងទីលាននៃទីបរិសុទ្ធរបស់អញ។ ចូរចូលទៅ ចូរចូលទៅតាមទ្វារចុះ ចូររៀប ផ្លូវសម្រាប់ប្រជាជន ចូរលើក ចូរលើកថ្នល់ឡើង ចូរប្រមូលយកថ្មចេញ ហើយបង្ហូតទង់ជ័យ១សម្រាប់សាសន៍ទាំងឡាយ។ មើល ព្រះយេហូវ៉ាទ្រង់ បានប្រកាសប្រាប់រហូតដល់ចុងផែនដីបំផុត ឲ្យប្រាប់ដល់កូនស្រីស៊ីយ៉ូនថា មើលសេចក្ដីសង្គ្រោះរបស់ឯងបានមកដល់ហើយ មើល ទ្រង់យករង្វាន់មកជា មួយ ហើយសំណងរបស់ទ្រង់ក៏នាំមុខទៅ។ គេនឹងហៅពួកនោះថា ជា សាសន៍បរិសុទ្ធ គឺជាពួកដែលព្រះយេហូវ៉ាទ្រង់ប្រោសលោះ នោះឯងនឹងបាន

ហៅថា ទីក្រុងដែលគេស្វែងរក ជាទីក្រុងដែលមិនត្រូវបង់ចោលឡើយ។" អេសាយ 62:4-12

ពេលនេះ នៅពេលដែលពួកគេដើរនៅក្នុងទឹកដីនេះ ពួកគេមានអំណរច្រើនជាងនៅតំបន់ដែលដាច់ឆ្ងាយចេញពីនគរដែលគេទៅនោះ ហើយការដែលទៅជិតដល់ទីក្រុង ពួកគេក៏បានឃើញទេសភាពយ៉ាងល្អឥតខ្ចោះថែមទៀត។ វាត្រូវបានសាងសង់ឡើងដោយត្បូងនិងថ្មមានតម្លៃ ហើយផ្លូវនៅទីនោះត្រូវបានសង់ចេញពីមាស។ ដូច្នេះដោយសារតែសិរីល្អពីធម្មជាតិរបស់ទីក្រុងនិងពន្លឺចែងចាំងផ្លាតដោយសារពន្លឺព្រះអាទិត្យទៅលើទីក្រុងនោះផង ហើយដោយសារមានបំណងចង់បាននោះគ្រីស្ទានក៏ធ្លាក់ខ្លួនឈឺ ពេញដោយសង្ឃឹមក៏មានជម្ងឺពីរបីមុខដែរ។ ដូច្នេះ នៅទីនេះពួកគេបានសម្រាកក្បែរទីនោះមួយរយៈ ដោយស្រែកចេញមកដោយសារតែការឈឺចាប់តាំងប៉ុន្មានរបស់ពួកគេថា "ប្រសិនបើអ្នកឃើញមនុស្សជាទីស្រឡាញ់របស់ខ្ញុំ សូមប្រាប់ទ្រង់ថាខ្ញុំមានជម្ងឺស្នេហា។"

ប៉ុន្តែបន្ទាប់ពីបានកម្លាំងចម្រើនឡើងបន្តិចមក ហើយបានប្រសើរឡើងដែលអាចនឹងទ្រាំទ្រជម្ងឺរបស់ពួកគេបាន នោះពួកគេបានដើរតាមផ្លូវរបស់ពួកគេទៀត ហើយមកកាន់តែជិតទៅៗ មានដើមផ្លែឈើ ចម្ការទំពាំងបាយជូរ និងសួនច្បារ ហើយឃ្លោងទ្វាររបស់ពួកគេបានបើកទៅកាន់ផ្លូវធំ។ ពេលនេះ នៅពេលដែលពួកគេបានមកដល់កន្លែងទាំងនេះ មើលទៅអ្នករក្សាសួនបានឈរនៅផ្លូវ ហើយអ្នកធ្វើធម្មយាត្រានិយាយទៅគាត់ថា "តើចម្ការទំពាំងបាយជូរនិងសួនច្បារយ៉ាងល្អនេះជារបស់អ្នកណាដែរ?" គាត់បានឆ្លើយថា "ទាំងអស់នោះជារបស់ស្តេច ហើយត្រូវបានដាំនៅទីនេះតាមការគាប់ចិត្តដល់ទ្រង់

ហើយក៏សម្រាប់ជាការកំសាន្តដល់អ្នកធ្វើធម្មយាត្រាដែរ។" ដូច្នេះអ្នករក្សាសួនបាននាំពួកគេចូលទៅក្នុងចម្ការទំពាំងបាយជូរ ហើយបានប្រាប់ពួកគេឱ្យបរិភោគផល្លាទាំងនោះផង។

**"កាលណាឯងចូលទៅក្នុងចម្ការទំពាំងបាយជូររបស់អ្នកជិតខាងណា នោះនឹងបរិភោគផលចម្អែតតាមចិត្តបាន ប៉ុន្តែ មិនត្រូវបេះដាក់ក្នុងកញ្ជ្រែងឯងទេ" ចោទិយកថា 23:24**

គាត់ក៏បានបង្ហាញពួកគេនូវដំណើររបស់សម្រាប់នៅទីនោះដែរ ហើយនឹងកន្លែងស្នាក់ដែលទ្រង់ចូលចិត្តនៅ ហើយនៅទីនេះពួកគេបានស្នាក់នៅនិងដេកផង។

ពេលនេះខ្ញុំមើលទៅក្នុងសុបិនរបស់ខ្ញុំឃើញថា ពួកគេបាននិយាយច្រើនទៀតក្នុងកាលដែលដេកលក់នៅពេលនេះច្រើនជាងពេលណាទាំងអស់ក្នុងការធ្វើដំណើររបស់ពួកគេ។ ហើយដោយបានកំសាន្តចិត្តនៅទីនោះ អ្នករក្សាសួនបានទាំងនិយាយមកខ្ញុំថា "ដូច្នេះតើអ្នកបានរីករាយនឹងការនេះដែរទេ? វាជាធម្មជាតិរបស់ទំពាំងបាយជូរនៃចម្ការទំពាំងបាយជូរនេះ ដែលវាចូលទៅយ៉ាងផ្អែមល្ហែម ដែលធ្វើឱ្យបបូរមាត់របស់ពួកគេដែលដេកលង់លក់និយាយឡើងផង។"

ដូច្នេះខ្ញុំបានឃើញថា នៅពេលដែលពួកគេភ្ញាក់ឡើង ពួកគេបានរៀបចំខ្លួនដើម្បីនឹងទៅកាន់ទីក្រុងតែម្តង តែដូចដែលខ្ញុំនិយាយអីចឹងថា ការដែលពន្លឺ

ព្រះអាទិត្យចែងចាំងទៅលើទីក្រុង (ដោយសារទីក្រុងធ្វើពីមានសុទ្ធ) នោះវាធ្វើឱ្យមានសិរីល្អចែងចាំងយ៉ាងខ្លាំង ដែលពួកគេមិនអាចនឹងមើលទៅកាន់ទីនោះដោយមុនទទេរផ្ទាល់បាននូវឡើយ តែមានតែតាមរយៈឧបករណ៍ម្យ៉ាងដែលត្រូវបានបង្កើតមកសម្រាប់គោលបំណងនោះ។

**"កំផែងនោះបានធ្វើពីត្បូងមណីជោតិ ហើយទីក្រុងក៏ធ្វើពីមាសសុទ្ធ ដូចជាកែវថ្លាល្អ" វិវរណៈ 21:18**

**"ហើយយើងរាល់គ្នាទាំងអស់ ដែលកំពុងតែរំពឹងមើលសិរីល្អព្រះអម្ចាស់ ទាំងមុខទទេ ដូចជាឆ្លុះមើលទ្រង់ក្នុងកញ្ចក់ យើងកំពុងតែផ្លាស់ប្រែទៅ ឲ្យដូចជារូបឆ្លុះនោះឯង ពីសិរីល្អទៅដល់សិរីល្អ គឺដោយសារព្រះអម្ចាស់ដ៏ជាព្រះវិញ្ញាណ ។" កូរិនថូសទី២ 3:18**

ដូច្នេះខ្ញុំបានឃើញថា ពួកគេបានបន្តទៅមុខទៀត ទីនោះពួកគេបានជួបបុរសពីនាក់នៅក្នុងពន្លឺរស្មីចែងចាំងមកដូចជាមាស ហើយមុខរបស់ពួកគេក៏ចែងចាំងដូចពន្លឺដែរ។

សេចក្ដីលំបាកចុងក្រោយ

បុរសពីរនាក់នេះបានសួរទៅកាន់អ្នកធ្វើធម្មយាត្រាថាពួកគេមកពីណា ហើយពួកគេក៏បានប្រាប់ទៅ។ ពួកគេក៏បានសួរថាតើពួកគេបានស្នាក់នៅទីណា តើមានការលំបាកនិងគ្រោះថ្នាក់អ្វីខ្លះ មានការកំសាន្តនិងសេចក្តីអំណរ

អ្វីខ្លះដែលពួកគេបានជួបនៅតាមផ្លូវ។ ហើយពួកគេក៏បានប្រាប់ទៅ។ បន្ទាប់មកបុរសទាំងពីនោះនិយាយថា "អ្នកមានការលំបាកពីរទៀតដែលអ្នកត្រូវជួបប្រទះ ហើយបន្ទាប់មកអ្នកនឹងដល់ទីក្រុងហើយ។"

បន្ទាប់មកគ្រីស្ទាននិងគ្នារបស់គាត់បានសូមឱ្យបុរសទាំងពីរទៅជាមួយពួកគេ ដូច្នេះពួកគេបានប្រាប់ថានឹងទៅជាមួយ។ "តែ" ពួកគេនិយាយថា "តែអ្នកត្រូវតែយកវាបានដោយជំនឿរបស់អ្នកផ្ទាល់។" ដូច្នេះខ្ញុំបានឃើញនៅក្នុងសុបិនរបស់ខ្ញុំបានពួកគេបានទៅជាមួយគ្នា រហូតដល់កន្លែងដែលពួកគេមើលឃើញឃ្លោងទ្វារ។

ពេលនេះខ្ញុំក៏ឃើញទៀតថានៅចន្លោះពួកគេនិងឃ្លោងទ្វារមានទន្លេមួយ តែមិនមានស្ពានឆ្លងទេ។ ទន្លេក៏ជ្រៅខ្លាំង។ ដូច្នេះដោយឃើញបែបនោះ អ្នកធ្វើធម្មយាត្រាបានស្រឡាំងកាំង ប៉ុន្តែបុរសដែលទៅជាមួយពួកគេនិយាយថា "អ្នកត្រូវតែឆ្លងកាត់វា មិនដូច្នោះអ្នកមិនអាចទៅដល់ឃ្លោងទ្វារឡើយ។"

អ្នកធ្វើធម្មយាត្រាក៏ចាប់ផ្តើមសួរថាតើមានផ្លូវណាផ្សេងទៀតទេដើម្បីទៅដល់ឃ្លោងទ្វារ ពួកគេក៏តបថា "មាន តែមិនមានមនុស្សណាម្នាក់ក្រៅពីមនុស្សពីរនាក់គឺ អេណុកនិងអេលីយ៉ា ដែលត្រូវបានអនុញ្ញាតឱ្យដើរឆ្លងកាត់តាមផ្លូវនោះតាំងតែពីការករកើតនៃពិភពលោកនេះម្ល៉េះ ក៏មិនមានអ្នកណាម្នាក់ទៀតរហូតដល់សូរត្រែត្រូវបន្លឺឡើង។"

"នែ ខ្ញុំប្រាប់អ្នករាល់គ្នាពីសេចក្តីអាថ៌កំបាំង គឺថាយើងទាំងអស់គ្នានឹងមិនដេកលក់ទៅទេ។ តែទាំងអស់គ្នានឹងបានផ្លាស់ប្រែទៅក្នុង១រំពេចវិញ គឺក្នុង១

**ប៉ប្រិចភ្នែកប៉ុណ្ណោះ ក្នុងកាលដែលឮស្នូរត្រែក្រោយបង្អស់ ដ្បិតត្រែនឹងឮឡើង មែន នោះពួកស្លាប់នឹងរស់ឡើងវិញ មិនពុករលួយទៀតឡើយ រួចយើងរាល់គ្នានឹងបានផ្លាស់ប្រែទៅ″ កូរិនថូសទី១ 15:51, 52**

បន្ទាប់មកអ្នកធ្វើធម្មយាត្រា ជាពិសេសគ្រីស្ទាន ចាប់ផ្តើមខូចចិត្តនៅក្នុងគំនិតរបស់ពួកគេ ហើយបានមើលទៅផ្លូវនេះផ្លូវនោះ តែមិនមានឃើញផ្លូវណាសោះ ដែលពួកគេនឹងអាចគេចផុតពីទន្លេ។ បន្ទាប់មកពួកគេបានបុរសទាំងពីរថា តើទឹកនេះមានជម្រៅប៉ុន្មាន? ពួកគេនិយាយថា "ទេ" តែពួកគេមិនអាចជួយបាននៅក្នុងបញ្ហានេះបានឡើយ ដោយពួកគេនិយាយថា ‶អ្នកនឹងរកឃើញថាវាកាន់តែជ្រៅ ឬកាន់តែរាក់អាស្រ័យលើការដែលអ្នកជឿដល់ស្តេចនៃទីនោះ។″

បន្ទាប់មកពួកគេបានរៀបខ្លួនរបស់ពួកគេចូលទៅក្នុងទឹក ហើយកាលដែលចូលទៅគ្រីស្ទានក៏បានលិចចូលទៅ។ ហើយបានស្រែកទៅកាន់មិត្តសំឡាញ់របស់គាត់ពេញដោយសង្ឃឹមថា ‶ខ្ញុំលិចចូលទៅក្នុងទឹកជ្រៅ រលកធំបានគ្របពីលើក្បាលរបស់ខ្ញុំហើយ ហើយរលកទាំងអស់បានគ្របមកលើខ្ញុំ។″

បន្ទាប់មកនិយាយទៀតថា "ចូរមានអំណរចុះបងប្រុសខ្ញុំអើយ ខ្ញុំប៉ះបាតដើយ ហើយវាល្អទេ។" បន្ទាប់មកគ្រីស្ទាននិយាយថា ‶អាហ៍!″ សំឡាញ់ខ្ញុំអើយទុក្ខសោកនៃសេចក្តីស្លាប់បានព័ទ្ធជុំវិញខ្ញុំ ខ្ញុំនឹងមិនបានឃើញទឹកដីដែល

ពេញដោយទឹកដោះនិងទឹកឃ្មុំឡើយ។ ហើយដោយមានសេចក្ដីងងឹតនិងសេចក្ដីផិតភ័យយ៉ាងខ្លាំងបានមកលើគ្រីស្ទាន ដូច្នេះគាត់មិនអាចមើលឃើញនៅខាងមុខគាត់បាន ហើយនៅទីនេះគាត់បានបាត់បង់ញាណរបស់គាត់យ៉ាងធំ ដូច្នេះគាត់មិនអាចទាំងចង់ចាំឬនិយាយតាមលំដាប់លំដោយពីការកំសាន្តចិត្តដ៏ផ្អែមល្ហែមដែលគាត់បានជួបនៅតាមផ្លូវនៃធម្មយាត្រារបស់គាត់បានឡើយ។ តែគ្រប់ទាំងពាក្យដែលគាត់និយាយនៅតែសំដៅបង្ហាញថា គាត់មានការផិតភ័យនៅក្នុងគំនិត និងសេចក្ដីភ័យខ្លាចនៅក្នុងចិត្តថាគាត់នឹងស្លាប់នៅក្នុងទន្លេ ហើយនឹងមិនអាចបានទៅដល់ផ្លូវចូលទៅឃ្លោងទ្វារនោះទេ។ ហើយនៅទីនេះអ្នកឈរក្បែរបានឃើញថា គាត់មានគំនិតពេលដោយបញ្ហាពីអំពើបាបដែលគាត់បានធ្វើ ទាំងមុននិងក្រោយដែលគាត់មកធ្វើធម្មយាត្រា។ "គេសង្កេតឃើញថាគាត់មានការលំបាកដោយសារព្រលឹងរបស់ពួកយមបាលនិងវិញ្ញាណអាក្រក់ អស់កល្បជានិច្ចនិងនៅពេលនេះគាត់នឹងស្ថិតនៅជាប់ក្នុងចិត្តដោយពាក្យនោះ។" ដូច្នេះពេញដោយសង្ឃឹមបានធ្វើការជាច្រើនដើម្បីនឹងរក្សាក្បាលរបស់បងប្រុសរបស់គាត់ឱ្យងើបផុតពីទឹក។ ហើយពេលខ្លះគាត់ក៏ត្រូវធ្លាក់ចុះទៅក្រោមយ៉ាងខ្លាំង ហើយបន្តិចក្រោយមកគាត់ក៏បានងើបមកវិញស្ទើតែស្លាប់។ ពេញដោយសង្ឃឹមក៏បានព្យាយាមកំសាន្តចិត្តដល់គាត់និយាយថា "បងអើយ ខ្ញុំឃើញឃ្លោងទ្វារនិងមនុស្សឈរនៅក្បែរនោះដើម្បីទទួលយើង។" តែគ្រីស្ទានឆ្លើយងថា "នោះជាអ្នក ពួកគេរងចាំងអ្នកទេ ដោយសារតែអ្នកតែងតែមានសង្ឃឹមតាំងតែពីពេលដែលខ្ញុំបានស្គាល់អ្នកពីដំបូងមកម្ល៉េះ" "ដូច្នេះអ្នកនៅតែមានសង្ឃឹមដដែល" គ្រីស្ទានបាននិយាយ។ "អាហ៍ ប្អូនប្រុសអើយ" គាត់និយាយថា "ពិតណាស់ ប្រសិនបើខ្ញុំនិយាយត្រូវ នោះគាត់នឹងមកជួយខ្ញុំហើយពេល

នេះ។˝ បន្ទាប់មកពេញដោយសង្ឃឹមនិយាយថា ˶បងប្រុសខ្ញុំអើយ បងពិតជាបានភ្លេចពីអត្ថបទមួយដែលនិយាយពីមនុស្សទុច្ចរិតហើយ គឺមិនមានបក្សពួកនៅពេលដែលគេស្លាប់ឡើយ តែកម្លាំងរបស់ពួកគេរឹងមាំ ពួកគេមិននៅក្នុងបញ្ហាដូចមនុស្សដ៏ទៃឡើយ ហើយពួកគេក៏មិនមានគ្រោះដូចមនុស្សដទៃដែរ។˝

**˶ពីព្រោះកាលគេស្លាប់ នោះគ្មានឈឺចាប់អ្វីសោះ គឺកម្លាំងគេនៅតែមាំមួនដដែល**
**គេមិនមានទុក្ខដូចជាមនុស្សធម្មតាឡើយ ក៏មិនត្រូវវេទនាដូចមនុស្សដទៃដែរ˝**
**ទំនុកដំកើង 73:4, 5**

បញ្ហានិងសេចក្ដីវេទនាទាំងនេះដែលអ្នកបានឆ្លងកាត់នៅក្នុងទឹកនេះមិនមែនជាសញ្ញាថា ព្រះបានបដិសេធអ្នកនោះទេ តែវាត្រូវបានបញ្ជូនមកដើម្បីនឹងសាកល្បងអ្នក ថាតើអ្នកនឹងមាននៅក្នុងគំនិតថា ដោយការនេះអ្នកនឹងបានទទួលសេចក្ដីសប្បុរសរបស់ទ្រង់ដែរទេ ហើយនឹងរស់នៅដោយពឹងលើទ្រង់នៅក្នុងសេចក្ដីលំបាកវេទនារបស់អ្នកដែរទេ។"

បន្ទាប់មកខ្ញុំបានឃើញនៅក្នុងសុបិនរបស់ខ្ញុំថា គ្រីស្ទានត្រូវបានកំសាន្តចិត្តមួយរយៈ ពេញដោយសង្ឃឹមក៏និយាយពាក្យនេះទៅគាត់ថែមទៀតថា "ចូរអរសប្បាយឡើង ព្រះយេស៊ូវគ្រីស្ទបានធ្វើឱ្យអ្នកបានបរិសុទ្ធ។" ហើយដោយសារការនោះ គ្រីស្ទានបានស្រែកយំយ៉ាងខ្លាំងថា ˶ឱ ខ្ញុំមើលឃើញ

ទ្រង់ម្តងទៀតហើយ! ហើយទ្រង់ប្រាប់ខ្ញុំថា នៅពេលដែលអ្នកឆ្លងកាត់ទឹក ខ្ញុំនឹងនៅជាមួយអ្នក ហើយឆ្លងកាត់ទន្លេ នោះវានឹងមិនត្រូវពន្លិចអ្នកឡើយ។"

**"កាលណាឯងដើរកាត់ទឹកធំ នោះអញនឹងនៅជាមួយ កាលណាដើរកាត់ទន្លេ នោះទឹកនឹងមិនលិចឯងឡើយ កាលណាឯងលុយកាត់ភ្លើង នោះឯងនឹងមិនត្រូវរលាក ហើយអណ្តាតភ្លើងក៏មិនឆាប់ឆេះឯងដែរ" អេសាយ 43:2**

បន្ទាប់មកពួកគេទាំងពីរបានមានចិត្តក្លាហានឡើយ ហើយសត្រូវបាននៅត្រឹងដូចជាដុំថ្ម រហូតទាល់តែពួកគេបានឆ្លងផុត។ ដូច្នេះគ្រីស្ទានពេលនេះបានរកឃើញដីដើម្បីនឹងឈរ ហើយដូច្នេះវានៅជាប់រហូតដល់ផុតទន្លេនៅតែរាក់ៗដដែល។ ដូច្នេះពួកគេក៏បានឆ្លងផុត។ ពេលនេះនៅមាត់ទន្លេ នៅម្ខាងទៀត ពួកគេបានឃើញបុរសពីរនាក់ដែលចែងចាំងម្តងទៀត ដែលនៅទីនោះរងចាំងពួកគេ។ ដូច្នេះ ដោយបានឡើងចេញពីទន្លេមក ពួកគាត់បានស្វាគមន៍គ្នាថា "ពួកគេជាវិញ្ញាណដែលចាំជួយ ត្រូវបានបញ្ជូនមកដើម្បីនឹងបម្រើដល់អស់អ្នកដែលជាអ្នកស្នងមរតកនៃសេចក្តីសង្គ្រោះ។" ដូច្នេះពួកគេបានបន្តទៅជាមួយគ្នារហូតដល់ឃ្លោងទ្វារ។ ពេលនេះអ្នកត្រូវតែសម្គាល់ថាទីក្រុងឈរនៅលើកំពូលភ្នំដ៏មានអំណាច តែអ្នកធ្វើធម្មយាត្រាបានដើរឡើងទៅលើកំពូលភ្នំដោយងាយ ពីព្រោះពួកគេមានបុរសពីរនេះនាំពួកគេលើងដោយដឹកដៃ ពួកគេក៏បានទុកសំលៀកបំពាក់មនុស្សចោលពីក្រោយនៅក្នុងទន្លេនោះទៅ ដោយសារបើទោះជាពួកគេទៅជាមួយសំលៀកបំពាក់នោះក៏ដោយ ក៏ពួកគេបានមកដោយគ្មានសំលៀកបំពាក់នោះដែរ។ ដូច្នេះពួកគេបានឡើងមកទីនេះដោយវាងវៃនិងល្បឿនលឿនខ្លាំង បើទោះជាគ្រឹះដែលទី

ក្រុងនៅខាងលើនោះមានតែមនៅខ្ពស់ជាងពពកក៏ដោយ។ ដូច្នេះពួកគេបាន លើងទៅដោយឆ្លងកាត់តំបន់នៃខ្យល់ ជជែកគ្នាយ៉ាងផ្អែមល្ហែមក្នុងកាល ដែលទៅ ត្រូវបានកំសាន្តចិត្ត ដោយសារពួកគេបានឆ្លងផុតទន្លេដោយសុវត្ថិភាព ហើយទាំងមានគ្នីគ្នាដែលពេញដោយសិរីល្អទៅជាមួយពួកគេ។

35

## ស្វាគមន៍

ការជជែករបស់ពួកគេជាមួយនឹងអស់អ្នកដែលមានពន្លឺចែងចាំងនោះគឺ ពីសិរីល្អនៃទីកន្លែងនោះ ពួកគេបានប្រាប់ពីសម្រស់និងសិរីល្អរបស់វាដែលត្រូវបានបង្ហាញមកឱ្យឃើញ។ "មាន" ពួកគេនិយាយថា "ជាភ្នំស៊ីយ៉ូន យេរូសាឡិមស្ថានសួគ៌ មានបរិវារទេវតារាប់មិនអស់ និងវិញ្ញាណរបស់មនុស្សសុចរិតដែលត្រូវបានធ្វើឱ្យបានល្អឥតខ្ចោះ។"

"គឺអ្នករាល់គ្នាបានមកដល់ភ្នំស៊ីយ៉ូនវិញ ជាទីក្រុងនៃព្រះដ៏មានព្រះជន្មរស់ គឺក្រុងយេរូសាឡឹមនៃស្ថានសួគ៌ ហើយដល់ពួកទេវតាទាំងសល់សែន។ ដល់ទីប្រជុំរបស់មនុស្សទាំងឡាយ និងជំនុំពួកកូនច្បងដែលកត់ទុកនៅស្ថានសួគ៌ ដល់ព្រះដ៏ជាចៅក្រមនៃមនុស្សទាំងអស់ ដល់អស់ទាំងវិញ្ញាណនៃពួកសុចរិតដែលបានគ្រប់លក្ខណ៍ហើយ។ ដល់ព្រះយេស៊ូវ ដែលជាអ្នកកណ្តាលនៃសេចក្តីសញ្ញាថ្មី ហើយដល់ព្រះលោហិត ដែលសម្រាប់នឹងប្រោះ ជាព្រះលោហិត ដែលសម្តែងពីសេចក្តីប្រសើរ ជាជាងឈាមរបស់អេបិលទៅទៀតផង។" ហេព្រើរ 12:22-24 ~

ពេលនេះអ្នកកំពុងទៅ" ពួកគេនិយាយថា "ទៅកាន់ស្ថានសួគ៌របស់ព្រះជាម្ចាស់ នៅទីនោះអ្នកនឹងឃើញដើមឈើជីវិត និងបានបរិភោគផ្លែឈើដែលមិនចេះសាបសូន្យនៅទីនោះផង។ ហើយពេលដែលអ្នកចូលដល់ទីនោះនឹងមានសំលៀកបំពាក់សឱ្យមកដល់អ្នក ហើយការដើរហើរនិងការនិយាយរាល់ថ្ងៃជាមួយនឹងស្តេច នៅគ្រប់ថ្ងៃនៅអស់កល្បជានិច្ច។"

“អ្នកណាដែលមានត្រចៀក ឲ្យអ្នកនោះស្តាប់សេចក្តី ដែលព្រះវិញ្ញាណមានព្រះបន្ទូល ដល់ពួកជំនុំទាំងប៉ុន្មានចុះ ឯអស់អ្នកណាដែលឈ្នះ នោះអញនឹងឲ្យបរិភោគផ្លែរបស់ដើមជីវិត ដែលនៅស្ថានបរមសុខ របស់ព្រះ។” **វិវរណៈ 2:7**

“ប៉ុន្តែ នៅក្រុងសើដេស ឯងក៏មានអ្នកខ្លះ ដែលមិនបានធ្វើឲ្យសម្លៀកបំពាក់ខ្លួនស្មោកគ្រោកដែរ អ្នកទាំងនោះនឹងស្លៀកពាក់ស ដើរជាមួយនឹងអញ ដ្បិតគេបានគួរហើយ” **វិវរណៈ 3:4**

“កំផែងនៃទីក្រុងក៏មានជើង១២ ដែលមានឆ្លាក់ឈ្មោះ ជាឈ្មោះពួកសាវករបស់ពួកកូនចៀមទាំង១២នាក់។” **វិវរណៈ 21:14**

នៅទីនោះអ្នកនឹងមិនឃើញការអ្វីដែលអ្នកបានឃើញក្នុងកាលដែលអ្នករស់នៅតំបន់ទាបក្នុងផែនដីទៀតឡើយគឺមាន សេចក្តីសោកសង្រេង ជម្ងឺ ការធ្វើទុក្ខ និងសេចក្តីស្លាប់ ដោយសារការពីដើមត្រូវកន្លងផុតទៅ។

“បានជាអ្នកណានៅផែនដីដែលចង់បានពរ នោះនឹងរកពរដោយព្រះនៃសេចក្តីពិត ហើយអ្នកណានៅផែនដីដែលស្បថ នោះនឹងស្បថដោយព្រះនៃសេចក្តីពិតដែរ ពីព្រោះសេចក្តីវេទនាពីជាន់មុនបានភ្លេចទៅហើយ ក៏បានកំបាំងពីភ្នែកអញផង។” **អេសាយ 65:16**

អ្នកកំពុងតែទៅកាន់លោក អ័ប្រាហាំ អ៊ីសាក់ និងយ៉ាកុប និងទៅកាន់ពួកហោរា ពួកមនុស្សដែលព្រះបានយកចេញពីអាអាក្រក់ដែលនឹងត្រូវមក

ហើយថាពួកគេកំពុងតែសម្រាកនៅលើគ្រែរបស់ពួកគេ ម្នាក់ៗកំពុងដើរនៅក្នុងសេចក្តីសុចរិតរបស់ខ្លួន។

**"មនុស្សសុចរិតគេវិនាសទៅ ឥតមានអ្នកណាយកចិត្តទុកដាក់ឡើយ ហើយមនុស្សចិត្តល្អ គេត្រូវយកទៅឥតមានអ្នកណាពិចារណាថា មនុស្សសុចរិតបានដកចេញឲ្យរួចពីចំពោះការអាក្រក់នោះទេ។ អ្នកនោះចូលទៅក្នុងសេចក្តីសុខសាន្ត គេសម្រាកនៅលើដំណេករបស់ខ្លួន គឺគ្រប់ទាំងមនុស្សដែលដើរតាមផ្លូវទៀងត្រង់។" អេសាយ 57:1, 2**

បន្ទាប់មកពួកគេសួរថា "តើយើងត្រូវធ្វើអ្វីនៅទីបរិសុទ្ធ?" ដែលមានចម្លើយមកថា "អ្នកនឹងត្រូវទទួលបានការកំសាន្តបីគ្រប់ទាំងការនឿយហត់ទាំងប៉ុន្មាន ហើយនឹងមានអំណរដោយសារទាំងសេចក្តីសោកសង្រេងទាំងប៉ុន្មានរបស់អ្នក អ្នកនឹងត្រូវប្រមូលផលអ្វីដែលអ្នកបានសាបព្រោះ ទាំងផលផ្លែនៃគ្រប់ទាំងការអធិស្ឋាន និងទឹកភ្នែករបស់អ្នកផង និងទុក្ខវេទនាដោយសារស្តេចនៅតាមផ្លូវផង។"

**"កុំឲ្យច្រឡំឡើយ និងបញ្ឆោតព្រះមិនបានទេ ដ្បិតពូជណាដែលមនុស្សព្រោះចុះ នោះនឹងច្រូតបានពូជនោះឯងវិញ" កាឡាទី 6:7**

នៅទីនោះអ្នកនឹងពាក់មកុដមាស និងរីករាយនឹងទស្សនីយភាពនិងរូបភាព

ដែលមិនសាបសូន្យនៃព្រះអង្គដែលបរិសុទ្ធ ដោយសារនៅទីនោះអ្នកនឹងបានឃើញទ្រង់បែបជាទ្រង់តែម្តង។

**“ពួកស្ងួនភ្ងាអើយ ឥឡូវនេះ យើងរាល់គ្នាជាកូនព្រះហើយ តែដែលយើងរាល់គ្នានឹងបានទៅជាយ៉ាងណាទៀត នោះមិនទាន់សម្តែងមកនៅឡើយ ប៉ុន្តែយើងដឹងថា កាលណាទ្រង់លេចមក នោះយើងនឹងបានដូចជាទ្រង់ ដ្បិតដែលទ្រង់យ៉ាងណា នោះយើងនឹងឃើញទ្រង់យ៉ាងនោះឯង” យ៉ូហានទី១ 3:2**

នៅទីនោះអ្នកនឹងបម្រើទ្រង់ជាបន្តដោយមានការសរសើរ ដោយការស្រែក និងការអរព្រះគុណ ជាមួយអង្គដែលអ្នកប្រាថ្នានឹងបម្រើនៅក្នុងផែនដី បើទោះជាមានការលំបាកខ្លាំងក៏ដោយ ដោយសារភាពមិនរឹងមាំខាងសាច់ឈាមរបស់អ្នក។ នៅទីនោះភ្នែករបស់អ្នកនឹងមានអំណរជាមួយនឹងការមើល ហើយត្រចៀករបស់អ្នកមានអំណរដោយការស្តាប់សម្លេងដែលជាទីគាប់ចិត្តនៃព្រះអង្គដែលមានអំណាចចេស្តា។ នៅទីនោះអ្នកនឹងបានរីករាយនឹងមិត្តសំឡាញ់របស់អ្នកម្តងទៀត ដែលពួកគេបានទៅដល់ទីនោះមុនអ្នក ហើយនៅទីនោះអ្នកនឹងមានអំណរដោយទទួលអ្នកគ្រប់គ្នាដែលមកដល់តាមក្រោយអ្នកផង។ ហើយនៅទីនោះអ្នកនឹងត្រូវបំពាក់ដោយសិរីល្អនិងអំណាចចេស្តា ហើយនឹងត្រូវដាក់ឱ្យជិះនៅយានចេញទៅជាមួយនឹងស្តេចនៃសិរីល្អផង។ នៅពេលដែលទ្រង់នឹងយាងមកជាមួយនឹងសូរត្រែនៅក្នុងពពក ដូចជានៅលើស្លាបខ្យល់ អ្នកនឹងមកជាមួយទ្រង់ ហើយនៅពេលដែលទ្រង់នឹងប្រថាប់នៅលើបល្ល័ង្កនៃការជំនុំជំរះ អ្នកនឹងអង្គុយនៅក្បែរទ្រង់។ ពិតណាស់ ហើយនៅពេលដែលទ្រង់នឹងធ្វើការកាត់ទោសដល់អ្នកបម្រើ

ខាងសេចក្តីទុច្ចរិត មិនថាជាទេវតាឬជាមនុស្សទេ អ្នកនឹងអាចនិយាយនៅក្នុងការជំនុំជំរះនោះដែរ ពីព្រោះពួកគេជាសត្រូវរបស់ទ្រង់និងរបស់អ្នកដែរ។ ហើយនៅពេលដែលទ្រង់នឹងត្រឡប់មកទីក្រុងវិញ អ្នកនឹងទៅដែរ ដោយមានសម្លេងត្រែនិងនៅជាមួយទ្រង់រហូត។"

"បងប្អូនអើយ ខ្ញុំមិនចង់ឲ្យអ្នករាល់គ្នាឥតដឹង ពីពួកអ្នកដែលដេកលក់ ទៅហើយទេ ក្រែងអ្នករាល់គ្នាកើតទុក្ខព្រួយ ដូចជាអ្នកឯទៀត ដែលគ្មានសង្ឃឹម។ ដ្បិតបើយើងជឿថា ព្រះយេស៊ូវបានសុគត ព្រមទាំងរស់ឡើងវិញហើយ នោះត្រូវជឿថា ព្រះទ្រង់នឹងនាំអស់អ្នកដែលដេកលក់ទៅក្នុងព្រះយេស៊ូវ ឲ្យបានមកជាមួយនឹងទ្រង់ដែរ។ ដ្បិតយើងខ្ញុំប្រាប់មកអ្នករាល់គ្នា តាមព្រះបន្ទូលនៃព្រះអម្ចាស់ដូច្នេះថា យើងដែលរស់នៅជាប់ ដរាបដល់ព្រះអម្ចាស់យាងមក នោះយើងមិនទៅមុនពួកអ្នក ដែលបានដេកលក់ទៅហើយនោះទេ។ ព្រោះព្រះអម្ចាស់ទ្រង់នឹងយាងចុះពីស្ថានសួគ៌មក ដោយស្រែកបង្គាប់១ព្រះឱស្ឋ ទាំងមានឮសំឡេងមហាទេវតា និងត្រែរបស់ព្រះផង នោះពួកស្លាប់ក្នុងព្រះគ្រីស្ទនឹងរស់ឡើងវិញជាមុនបង្អស់" ថែស្សាឡូនិចទី១ 4:13-16

"ឯហេណុក ជាជំណទី៧ពីលោកអ័ដាមមក គាត់បានទាយពីមនុស្សទាំងនោះថា មើល ព្រះអម្ចាស់ទ្រង់យាងមក នៅកណ្តាលពួកបរិសុទ្ធទ្រង់ទាំងសល់សែន" យូដាស 14

"ខ្ញុំក៏គន់មើល ទាល់តែមានគេយកបល្ល័ង្កមកតាំង ហើយព្រះដ៏មានព្រះជន្មពីចាស់បុរាណ ទ្រង់ក៏គង់លើ ព្រះពស្ត្រទ្រង់សស្គុសដូចហិមៈ ហើយព្រះកេសនៅព្រះសិរទ្រង់ ក៏សដូចរោមចៀមយ៉ាងស្អាត ឯបល្ល័ង្កទ្រង់ នោះសុទ្ធតែជាអ

**ណ្ដាតភ្លើង ហើយកង់នៃបល្ល័ង្កនោះ ក៏ជាភ្លើងឆេះដែរ។ មានដូចជាភ្លើងហូរចេញពីចំពោះទ្រង់មក មានទាំងពាន់ទាំងពាន់ដែលគោរពដល់ទ្រង់ ហើយទាំង ម៉ឺនទាំងសែនក៏ឈរនៅចំពោះទ្រង់ នោះការវិនិច្ឆ័យបានរៀបចំជាស្រេច ឯបញ្ជីទាំងប៉ុន្មានបានបើកឡើងហើយ" ដានីយ៉ែល 7:9, 10**

**"តើមិនដឹងថា ពួកបរិសុទ្ធនឹងជំនុំជម្រះលោកីយ៍ដែរទេឬ ដូច្នេះ បើអ្នករាល់គ្នានឹងជំនុំជម្រះលោកីយ៍បាន នោះតើមិនគួរនឹងជំនុំជម្រះការណ៍តូចបំផុតនេះបានដែរទេឬអី។ តើមិនដឹងថា យើងរាល់គ្នានឹងជំនុំជម្រះ ដល់ទាំងពួកទេវតាផងទេឬអី ដូច្នេះ ចំណងបើការណ៍នៅជីវិតនេះ តើលើសជាងអម្បាលម៉ានទៅទៀត" កូរិនថូសទី១ 6:2, 3**

ពេលនេះ ក្នុងកាលដែលពួកគេខិតមកជិតឃ្លោងទ្វារ មើលទៅមានបក្សពួកនៃបរិវារស្ថានសួគ៌ចេញមកជួបពួកគេ ដែលត្រូវបាននិយាយទៅកាន់ពួកគេដោយអ្នកដែលភ្លឺចែងចាំងថា "ទាំងនេះជាមនុស្សដែលបានស្រឡាញ់ព្រះអម្ចាស់របស់យើង ក្នុងកាលដែលពួកគេនៅលើផែនដី ហើយបានបោះបង់ចោលទាំងអស់ដោយសារព្រះនាមបរិសុទ្ធរបស់ទ្រង់ ហើយទ្រង់បានបញ្ជូនយើងមកនាំយកពួកគេទៅ ហើយយើងបាននាំពួកគេមកដល់គោលដៅដែលពួកគេប្រាថ្នាហើយ ដែលពួកគេនឹងចូលទៅក្នុង ហើយមើលទៅកាន់ព្រះអង្គសង្គ្រោះរបស់ពួកគេដោយផ្ទាល់មុខដោយអំណរផង។" បន្ទាប់មកពួកបរិវារស្ថានសួគ៌បានស្រែកយ៉ាងខ្លាំងថា "មានពរហើយអស់អ្នកណាដែលត្រូវបានហៅមកកាន់អាហារនៃមង្គលការរបស់កូនចៀម។"

**"ទេវតាក៏ប្រាប់មកខ្ញុំថា ចូរសរសេរថា មានពរហើយ អស់អ្នកដែលព្រះបានហៅមកបរិភោគការកូនចៀម ក៏និយាយមកខ្ញុំទៀតថា នេះជាព្រះបន្ទូលពិត**

របស់ព្រះ" វិវរណៈ 19:9 ~
នៅទីនោះមានអ្នកផ្លុំត្រែមួយចំនួនរបស់ស្តេចបានចេញមកជួបពួកគេ ដែលមានស្លៀកពាក់សនិងរស្មីចែងចាំង ដោយសម្លេងពិរោះរណ្តំរបស់ពួកគេឮៗ ដែលធ្វើឱ្យទាំងស្ថានសួគ៌បានបន្ទរដោយសម្លេងរបស់ពួកគេ។ អ្នកផ្លុំត្រែទាំងនេះស្វាគមន៍ដល់គ្រីស្ទាននិងគ្នារបស់គាត់ដោយការស្វាគមន៍មួយម៉ឺនចេញពីផែនដី ហើយដោយមានការស្រែកហោរនិងសម្លេងនៃត្រែ។

រួចមក ក៏នាំពួកគេទៅក្រឡឹងគ្រប់ជ្រុងជ្រោយ អ្នកខ្លះដើរទៅមុខ ខ្លះទៀតទៅពីក្រោយ ហើយខ្លះនៅខាងស្តាំ ខ្លះនៅខាងឆ្វេង (ដែលនៅទីនោះដើម្បីនឹងដឹកនាំពួកគេកាត់តំបន់ដែលនៅខាងលើ)។ គេនៅតែបន្តបង្កើតសម្លេងក្នុងកាលដែលដើរទៅផង ដោយសម្លេងយ៉ាងរណ្តំ នៅក្នុងខ្ទង់សម្លេងយ៉ាងខ្ពស់ ដូច្នេះគ្រប់ទាំងទស្សនីយភាពពួកគេអាចមើលឃើញ ប្រៀបដូចជាស្ថានសួគ៌ផ្ទាល់ត្រូវបានចុះមកក្រោយជួបនឹងពួកគេអីចឹង។ ដូច្នេះ ពួកគេបន្តដើរជាមួយគ្នា ហើយពេលដែលពួកគេដើរ បន្តិចក្រោយមកអ្នកផ្លុំត្រែទាំងនេះបានលាយសម្លេងអរសប្បាយជាមួយនឹងទឹកមុខនិងកាយវិការតន្ត្រីទៅដល់គ្រីស្ទាននិងបងប្អូនរបស់គាត់ ថាពួកគេស្វាគមន៍ខ្លាំងប៉ុណ្ណាដែលពួកគេបានមកចូលរួម និងដោយសេចក្តីត្រេកអរដែលពួកគេបានមកជួបគ្នា។ ហើយពេលនេះបុរសទាំងពីរបានមកដល់ស្ថានសួគ៌ មុនពេលដែលពួកគេចូលមកដល់ផង ដោយការភ្ញាក់ផ្អើលនឹងទស្សនីយភាពរបស់ទេវតា និងដោយស្តាប់សូរសម្លេងពិរោះរណ្តំផង។ នៅទីនេះពួកគេក៏បានឃើញទេសភាពនៃទីក្រុងផ្ទាល់ផងដែរ ហើយពួកគេគិតថាពួកគេបានឮសម្លេងកណ្តឹងរោទិ៍នៅក្នុងទីនោះផង ដែលស្វាគមន៍ពួកគេចូលទៅ តែលើសពីនោះ

ទៅទៀត គំនិតដែលកក់ក្តៅនិងពេញដោយអំណរដែលពួកគេមានក្នុងកាលដែលត្រូវស្នាក់នៅទីនោះ ជាមួយនឹងមនុស្សម្នាបែបនោះ ហើយត្រូវនៅជានិរន្តន៍ផង។ អូ តើមានអណ្តាតនិងប៊ិចអ្វីដែលនឹងអាចរៀបរាប់បង្ហាញពីសេចក្តីអំណរពេញដោយសិរីល្អរបស់ពួកគេបានទៅ! ហើយដូច្នេះពួកគេក៏មកដល់ឃ្លោងទ្វារ។

ពេលនេះនៅពេលដែលពួកគេមកដល់ឃ្លោងទ្វារ មានពាក្យសរសេរនៅលើនោះដោយតួអក្សរមាសថា "មានពរហើយអស់អ្នកដែលធ្វើតាមបញ្ញាត្តិទ្រង់ដែលពួកគេនឹងមានសិទ្ធិចូលដល់ដើមជីវិត ហើយនឹងចូលទៅក្នុងតាមឃ្លោងទ្វារទៅកាន់ទីក្រុងផង។"

**"មានពរហើយអស់អ្នកណាដែលលាងអាវខ្លួន ដើម្បីឲ្យបានច្បាប់ដល់ដើមជីវិត ហើយឲ្យបានចូលទៅក្នុងក្រុងតាមទ្វារ" វិវរណៈ 22:14**

បន្ទាប់មកខ្ញុំឃើញនៅក្នុងសុបិនរបស់ខ្ញុំថា មនុស្សដែលចែងចាំងប្រាប់ពួកគេឱ្យហៅនៅត្រង់ឃ្លោងទ្វារ ហើយកាលដែលពួកគេធ្វើតាម មានអ្នកខ្លះមើលមកពីលើឃ្លោងទ្វារ ដូចជាលោកអេណុក ម៉ូសេ និងអេលីយ៉ា ដែលត្រូវបាននិយាយទៅកាន់ពួកគេថា "អ្នកធ្វើធម្មយាត្រាទាំងនេះមកបីទីក្រុងនៃសេចក្តីវិនាស ដោយសារសេចក្តីស្រឡាញ់ដែលពួកគេមានដល់ស្តេចនៃទីនេះ។" ហើយបន្ទាប់មកអ្នកធ្វើធម្មយាត្រាផ្តល់សញ្ញាបត្ររបស់ពួកគេផ្ទាល់ខ្លួនម្នាក់ៗទៅ ដែលពួកគេបានទទួលតាំងពីដើមមក។ ហើយសញ្ញាបត្រទាំងនោះត្រូវបានយកទៅកាន់ស្តេច កាលដែលទ្រង់បានអាននោះក៏មានបន្ទូលថា "តើពួកគេនៅទីណា?" ដែលគេបានឆ្លើយដល់ទ្រង់ថា "ពួកគេកំពុងឈរ

នៅក្រៅឃ្លោងទ្វារ។" "ជាពួកសាសន៍ដែលសុចរិត" ទ្រង់មានបន្ទូលថា "ដែលបានរក្សាសេចក្តីពិត នឹងអាចចូលមកបាន។"

**"ចូរបើកទ្វារ ដើម្បីឲ្យសាសន៍សុចរិតដែលរក្សាសេចក្ដីស្មោះត្រង់បានចូលមកចុះ" អេសាយ 26:2**

ពេលនេះខ្ញុំបានឃើញនៅក្នុងសុបិនរបស់ខ្ញុំថា បុរសទាំងពីរបានចូលតាមឃ្លោងទ្វារ ហើយមើលទៅកាលដែលពួកគេចូលទៅ ពួកគេត្រូវបានប្រែរូបរាង ហើយពួកគេមានរស្មីចែងចាំងពាក់ដូចជាមាស។ ក៏មានមនុស្សដែលបានជួបនឹងពួកគេដោយមានចាប់ស៊ុងនិងមកុដផង ហើយបានជូនដល់ពួកគេ។ ចាប់ស៊ុងដើម្បីនឹងសរសើរ ហើយមកុដជាគ្រឿងសម្គាល់នៃកិត្តិយស។ បន្ទាប់មកខ្ញុំបានឮនៅក្នុងសុបិនរបស់ខ្ញុំថា គ្រប់ទាំងកណ្ដឹងនៅក្នុងទីក្រុងបានរោទិ៍ដោយអំណរម្តងទៀត ហើយដែលមាននិយាយទៅកាន់ពួកគេថា "ចូរអ្នកចូលទៅក្នុងសេចក្តីអំណររបស់ព្រះអម្ចាស់របស់អ្នកចុះ។" ខ្ញុំក៏បានឮបុរសទាំងពីរផ្ទាល់ច្រៀងដោយសម្លេងឮៗថា "ព្រះពរ កិត្តិយស សិរីល្អ និងចេស្តា ដល់ទ្រង់ដែលគង់លើបល្ល័ង្គ និងទៅដល់កូនចៀមអស់កល្បជានិច្ចទៅ។"

**"នោះខ្ញុំក៏ឮគ្រប់ទាំងអស់ ដែលមានជីវិត នៅស្ថានសួគ៌នៅផែនដី នៅក្រោមដី ហើយនៅក្នុងសមុទ្រ និងគ្រប់ទាំងអស់ដែលនៅស្ថានទាំងនោះនិយាយថា សូមថ្វាយព្រះពរ កិត្តិនាម សិរីល្អ និងព្រះចេស្តា ដល់ព្រះអង្គដែលគង់លើបល្ល័ង្គ ហើយដល់កូនចៀម នៅអស់កល្បជានិច្ចរៀងរាបតទៅ។ រួចតួមានជីវិតទាំង៤ក៏ទទួលថា អាម៉ែន ហើយពួកចាស់ទុំក៏ទម្លាក់ខ្លួនក្រាបចុះថ្វាយបង្គំ។" វិវរណៈ 5:13, 14**

ពេលនេះ កាលដែលឃ្លោងទ្វារបានបើកឡើងដើម្បីឱ្យបុរសទាំងពីរចូល ខ្ញុំបានមើលទៅពីក្រោយពួកគេ បានឃើញ ទីក្រុងចែងចាំងដូចជាព្រះអាទិត្យ ផ្លូវត្រូវបានសាងដោយមាស ហើយមានមនុស្សដើរជាច្រើន មានមកុដនៅលើក្បាលរបស់ពួកគេ ធាងស្លានៅដៃរបស់ពួកគេ និងចាប់ស៊ុងមាសដើម្បីនឹងច្រៀងសរសើរ។

ក៏មានពួកអ្នកដែលមានស្លាប ហើយឆ្លើយទៅកាន់គ្នាដោយឥតឈប់ឈរថា "បរិសុទ្ធ បរិសុទ្ធ បរិសុទ្ធ ជាព្រះអម្ចាស់!" ហើយបន្ទាប់មកពួកគេបានបិទឃ្លោងទ្វារ ដែលខ្ញុំបានឃើញនោះ ខ្ញុំប្រាថ្នាថាខ្ញុំជាម្នាក់ក្នុងចំណោមពួកគេដែរ។

ភាពល្ងង់ខ្លៅបានមកដល់ទីបញ្ចប់របស់គេ

ពេលនេះ នៅពេលដែលខ្ញុំសម្លឹងមើលទៅលើការទាំងនេះ ខ្ញុំបានបែរក្បាលរបស់ខ្ញុំមើលមកក្រោយ ហើយបានឃើញល្ងង់ខ្លៅមកដល់ក្បែរទន្លេ តែភ្លាមនោះក៏បានចេញផុត ហើយដោយគ្មានការលំបាកស្មើនឹងពាក់កណ្តាលនៃបុរសពីនាក់ទៀតបានជួបនោះឡើយ។ ដោយសារចៃដន្យមានម្នាក់នៅទីនោះឈ្មោះ សង្ឃឹមឥតប្រយោជន៍ ជាអ្នកបើកទុកសន្តោង ដែលបានជួយគាត់ដោយប្រើទូកនោះឆ្លង។ ដូច្នេះគាត់ក៏បានឡើងមកលើកំពូលភ្នំដូចអ្នកផ្សេងទៀតដែរតាមដែលខ្ញុំបានឃើញបានមកកាន់ឃ្លោងទ្វារ តែគាត់មកតែម្នាក់ឯង គ្មាននរណាម្នាក់មកជាមួយគាត់ដោយការលើកទឹកចិត្តឡើយ។ នៅពេលដែលគាត់មកដល់ឃ្លោងទ្វារ គាត់បានមើលទៅកាន់ពាក្យសរសេរដែលនៅខាងលើ ហើយក៏ចាប់ផ្តើមគោះទ្វារ ដោយសង្ឃឹមថានឹងបានបើក

ទ្វារឱ្យគាត់បានចូលភ្លាម តែត្រូវមនុស្សដែលនៅលើឃ្លោងទ្វារសួរមកគាត់ថា "តើអ្នកមកពីណា? ហើយតើអ្នកចង់បានអ្វី?" គាត់បានឆ្លើយថា "ខ្ញុំបានបរិភោគនិងផឹកនៅក្នុងវត្តមានរបស់ស្តេច ហើយទ្រង់បានបង្រៀននៅតាមផ្លូវរបស់យើង។" បន្ទាប់មកពួកគេបានសួររកសញ្ញាបត្ររបស់គាត់ ដែលពួកគេនឹងអាចចូលទៅបង្ហាញដល់ស្តេចបាន។ គាត់ក៏ស្ទាបនៅនឹងទ្រូងរបស់គាត់រកវា ហើយរកមិនឃើញសោះ។ បន្ទាប់មកពួកគេនិយាយថា "តើអ្នកមិនមានទេឬអី?" ប៉ុន្តែបុរសនោះមិនអាចឆ្លើយបានសូម្បីតែមួយម៉ាត់។ ដូច្នេះពួកគេក៏បានប្រាប់ដល់ស្តេច តែទ្រង់មិនបានចុះមកមើលគាត់ឡើយ តែបានបង្គាប់បុរសដែលចែងចាំងពីរនាក់ឱ្យហែរហមគ្រីស្ទាននិងពេញដោយសង្ឃឹមទៅកាន់ទីក្រុង ហើយឱ្យចេញទៅក្រៅនិងនាំយកល្វង់ខ្លៅ ហើយចងដៃជើងគាត់ ហើយយកគាត់ចេញទៅ។ បន្ទាប់មកពួកគេបានលើកគាត់ឡើង ហើយនាំគាត់ឆ្លងកាត់ខ្យល់ទៅកាន់ទ្វារដែលខ្ញុំបានឃើញនៅខាងភ្នំនោះ ហើយបានទុកគាត់នៅទីនោះ។ បន្ទាប់មកខ្ញុំបានឃើញនៅទីនោះមានផ្លូវទៅកាន់ស្ថាននរក ដែលជាផ្លូវចេញពីឃ្លោងទ្វារស្ថានសួគ៌ ក៏ដូចជាចេញពីទីក្រុងនៃសេចក្តីវិនាសអន្តរាយ។ ដូច្នេះខ្ញុំក៏ភ្ញាក់ឡើង ហើយមើលវាគឺជាសុបិនប៉ុណ្ណោះ!

## សេចក្តីសរុប

ពេលនេះ អ្នកអានអើយ ខ្ញុំបានប្រាប់ពីសុបិនរបស់ខ្ញុំដល់អ្នកហើយ។ ចូរមើលតើអ្នកអាចបកស្រាយវាដល់ខ្ញុំទេ ឬទៅដល់ខ្លួនអ្នកផ្ទាល់ ឬអ្នកជិតខាងនោះ។ តែត្រូវប្រយ័ត្ននឹងការបកប្រែខុស ដោយសារ ជំនួសអោយការធ្វើល្អ បែរជាធ្វើដោយបំពានដោយខ្លួនអ្នកវិញ ដោយការបកប្រែខុសដែល

អារក្សវាធ្វើសម្រេច។ ចូរប្រយ័ត្នថានឹងមិនជ្រុលពេកនៅក្នុងការបកស្រាយដោយអ្វីដែលនៅក្រៅពីសុបិនរបស់ខ្ញុំ ក៏មិនត្រូវឱ្យរូបភាព និងរូបតំណាងធ្វើឱ្យអ្នកសើចនិងមានជំលោះនោះឡើយ។ ទុកការនោះឱ្យដល់ក្មេងៗនិងមនុស្សល្ងីល្ងើវិញ តែសម្រាប់អ្នកវិញ សូមអ្នកមើលទៅកាន់ធាតុនៃបញ្ហារបស់ខ្ញុំវិញ។ ចូរដាក់នៅក្បែររាំងនន មើលទៅខាងក្នុងកន្សែងគ្រប ចូរបើកការប្រៀបប្រដូចរបស់ខ្ញុំកុំខានឱ្យសោះ។ ប្រសិនបើអ្នកស្វែងការទាំងនោះ ការទាំងនោះនឹងត្រូវបានរកឃើញ ហើយនឹងមានប្រយោជន៍ដល់គំនិតដែលស្មោះត្រង់ផង។ ការដែលជាសម្រាមដែលអ្នករកឃើញនៅទីនោះ ចូរអ្នកក្លាហាននឹងបោះវាចោលទៅ តែចូររក្សាអ្វីដែលជាមាសទុកវិញ។ ចុះប្រសិនបើមាសត្រូវខ្ញុំត្រូវរុំនឹងថ្មនោះ? គ្មានអ្នកណានឹងបោះផ្លែប៉មចោលហើយទៅយកស្នូលវានោះឡើយ។ តែប្រសិនបើអ្នកនឹងបោះចោលទាំងអស់ជាឥតប្រយោជន៍នោះ  ខ្ញុំមិនដឹងទេ តែវានឹងធ្វើឱ្យខ្ញុំសុបិនម្តងទៀត។

ទីបញ្ចប់នៃផ្នែកទីមួយ

*[ The End of Volume I – 3]*